សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

REMEDIUM PHARMACY
ឱសថស្ថានរ៉េមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
• ផ្ទេរឬផ្លាស់ប្ដូរសេវាកម្ម • ការវេចខ្ចប់ឱសថ
• ការលាយផ្សំឱសថ • បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ
• ជួយធ្វើសំបុត្រទិញថ្នាំ • ផ្លាស់ប្ដូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Blisterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071

## វិចារណកថា

# ទេព នីថា បានជាប់ជាអគ្គលេខា គ.ជ.ប. តើមានន័យយ៉ាងណា?



ពិន សំខុន

**ដោយ ពិន សំខុន**

គួររំលឹកថា ទេព នីថា គឺជាអគ្គលេខាធិការរបស់ "គណកម្មការរៀបចំការបោះឆ្នោត" ពីច្រើនដងពីមុនៗមក ដែលគណបក្សសង្គ្រោះជាតិប៉ងប្រាថ្នាប្ដូរចេញឱ្យបានសម្រេចយ៉ាងប្ដូរផ្ដាច់ក្នុងតម្លៃថ្លៃមួយ គឺសុខចិត្តបោះបង់ការតស៊ូបោះបង់អាណត្តិកាន់អំណាចនិតិ-ប្រតិបត្តិ២០១៣-១៨ ដើម្បីគ.ជ.ប. ថ្មីមួយទៀត

**តទៅទំព័រទី ២៨**

# រាត្រីសម្ពោធអង្គការ "មូលនិធិភ្នំដងរែក" នៅឡូវែល

## Lowell: Inauguration of "Phnom Dangrek Foundation"

**ដោយ ពិន សំខុន**

ភ្ញៀវប្រមាណ៣០០នាក់ បានមកចូលរួមរាត្រីសម្ពោធអង្គការថ្មីមួយនៅឡូវែល គឺ "មូលនិធិភ្នំដងរែក" ដឹកនាំដោយលោក ឈុំ ឈាង អតីតឧត្តមសេនីយនិងជាអតីតជនភៀសខ្លួននៅព្រំប្រទល់ដែនខ្មែរ-ថៃ កាលពីអំឡុងឆ្នាំ១៩៧៥ កាលពីថ្ងៃសៅរ៍ ទី២៣ ខែមករា ឆ្នាំ២០១៦។ ទោះជាធាតុអាកាសត្រជាក់ដល់កំរិតសូន្យក៏ដោយជាមួយគ្នានោះក៏មាន

**តទៅទំព័រទី ០៧**




ការិយាល័យច្បាប់
រ៉ូសា និង តាំង



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ស៊ីស្កូ ជេ.រ៉ូសា



Andrew 'Bunna' Taing, Esq.
មេធាវី អែន ឌ្រូវប៊ុណ្ណា តាំង

Law Office of
Rosa & Taing
ATTORNEY AT LAW

SERVICES
• Auto Accidents/ Personal Injury
• Bankruptcy
• Immigration
• Consumer Protection
• Real Estate Closings/Disputes
• Divorces Child Custody

តំណាងក្ដីដូចខាងក្រោម
• គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
• ក្ស័យធន
• អន្តោប្រវេសន៍
• ការពារអតិថិជន
• ទំនាស់ផ្នែកអចលនវត្ថុ
• លែងលះ និងអាណាព្យាបាលកិច្ច

1550 Middlesex Street Lowell, MA 01851
Phone: 978-458-0934 | at@rosataing.com

CENTURY PHARMACY & OPTICAL
937 Gorham St | ALL MAJOR INSURANCES ACCEPTED | Tel: 978-455-6554

ឱសថស្ថានសេនជូរី : យើងជាអ្នកបំរើលោកអ្នកយ៉ាងប្រសើរ!



‣ ផ្ដល់សេវាដល់ទីលំនៅ
‣ ខ្ចប់ឱសថតាមបំណង
‣ ជាឱសថស្ថានដែលលោកអ្នកអាចជឿជាក់ក្នុងចិត្ត

937 Gorham St Lowell, MA, 01852
លេខទូរស័ព្ទ 978-455-6554 / លេខហ្វាក់ 978-455-9476

ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៍
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្ដីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766


CENTURY PHARMACY & OPTICAL
937 Gorham St
ALL MAJOR INSURANCES ACCEPTED
Tel: 978-455-6554
យើងជា ឱសថ ស្ថានមួយ ដែលអាចផ្តល់ ភាពជឿជាក់ ដល់គ្រួសារ លោកអ្នក
យើងខ្ញុំ សូមជូនពរ មហាប្រសើរ ដល់លោក អ្នក
យើងខ្ញុំមានផ្តល់សេវ៉ាបំរើការជូនឱសថដល់ទីលំនៅ ។
យើងខ្ញុំទទួលកាតម៉ាសហ៊ាវ, និងកាតធានារ៉ាប់រង សុខភាពផ្សេងៗទៀត
សេវ៉ាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
យកចិត្តទុកដាក់លើបញ្ហាផ្ទល់ខ្លួននៃអតិថិជនរាល់រូប ។
វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
យើងខ្ញុំទទួលការផ្សំថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។ ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។
CENTURY PHARMACY
យើងខ្ញុំនិយាយភាសាខ្មែរ ។
លេខទូរស័ព្ទ 978-455-6554
លេខហ្វាក់ 978-455-9476
937 Gorham St Lowell, MA, 01852

# វេទិកាអាជីវកម្មខ្នាតតូចសហគមន៍ខ្មែរ_អាមេរិក

**ដោយ : ណារ៉េត មួង**

**ឡូវែលរដ្ឋម៉ាសាឈូសេត:** កាលពីថ្ងៃ ពុធ ទី២០ ខែមករា ឆ្នាំ២០១៦ សមាគមខ្មែរបាន


សុបិន្ត ពិន


ដារី ត្រាន


រដ្ឋាយ៉ែម


អ្នកស្រី ដេនិស



រៀបចំវេទិកាអាជីវកម្មខ្នាតតូចសហគមន៍ខ្មែរ-អាមេរិក។ សមាគមខ្មែរនៃមហាតំបន់ឡូវែល ឬហៅកាត់ជាភាសាអង់គ្លេសថា CMAA សហការគ្នាជាមួយអង្គការសហគ្រិនភាព ដើម្បីទាំងអស់គ្នា (ឬ EforAll) ដោយទទួលបានមូលនិធិពីគម្រោងអភិវឌ្ឍសហគមន៍ (ឬ CDBG) បង្កើតកម្មវិធីលើកស្ទួយអាជីវកម្មខ្មែរ-អាមេរិក។ គោលបំណងនៃគម្រោងរួមគ្នានេះគឺដើម្បីជួយដល់អាជីវករ ឬអ្នកដែលមានបំណងចង់បង្កើតមុខរបរថ្មី ឬចង់បើកអង្គការមិនរកប្រាក់កម្រៃ ដោយជួយជាការប្រឹក្សាយោបល់ធនធានបច្ចេកទេស និងការបណ្តុះបណ្តាល ដើម្បីឱ្យសេចក្តីប្រាថ្នារបស់ពួកគាត់ក្លាយជាការពិត។ ជំនួយទាំងនេះផ្តល់ជូនដោយឥតគិតថ្លៃ។

វេទិកាកាលពីថ្ងៃ ពុធ កន្លងទៅនេះ គឺជាផ្នែកមួយនៃការជម្រុញទឹកចិត្តផ្សព្វផ្សាយ និងបណ្តុះគំនិតដល់អ្នកដែលមានបំណងចង់បង្កើតមុខរបរថ្មី CMAA និង EforAll។ វាគ្មិនបួនរូបបានចូលរួមចែករម្លែកបទពិសោធន៍ផ្នែកអាជីវកម្ម និងការគ្រប់គ្រប់អង្គការ។ វាគ្មិនទីមួយគឺកញ្ញា ដារី ត្រាន់ ជាខ្មែរ-អារិក ធ្លាប់ជាជនភៀសខ្លួន និងឥឡូវជាប្រធានក្រុមរបាំអង្គរ។ ដារីធ្លាប់មានមានបរិញ្ញាប័ត្រផ្នែកសិល្បៈពីមហាវិទ្យាល័យ Well esley ។ វាគ្មិនទីពីរ គឺលោក ផល រដ្ឋាយ៉ែម ធ្លាប់ជួយសហគមន៍ខ្មែរតាំងពីគាត់មកដល់ទឹកដីសហរដ្ឋអាមេរិកពីដំបូង។ សព្វថ្ងៃគាត់ជាម្ចាស់ក្រុមហ៊ុនអចលនទ្រព្យឈ្មោះ Global Realty Network ។ គាត់ជាសមាជិកសកម្មម្នាក់នៅក្នុងសហគមន៍។ គាត់ធ្លាប់ធ្វើជាលេខាធិការរបស់គណកម្មាធិការក្រុងខ្មែរ។ វាគ្មិនទីបី គឺលោកស្រី ដេនីស បានជាម្ចាស់ភោជនីយដ្ឋាន ស៊ុមភ្លីខ្មែរ។ បទពិសោធន៍ជួយក្រុមគ្រួសារជនភៀសខ្លួន និងជនអន្តោប្រវេសន៍ និងយុវជនជាច្រើន មុននឹងគាត់មកកាន់ការជាប្រធានក្រុមរបាំអង្គរ។ គាត់គាត់មានបរិញ្ញាប័ត្រផ្នែកគណនេយ្យពីមហាវិទ្យាល័យ Bentley ។ វាគ្មិនទីបួន គឺលោកស្រី សុបិន ពិន មានស្រុកកំណើតនៅខេត្តត្រាវិញ កម្ពុជាក្រោម ។ គាត់ នឹងក្រុមគ្រួសារបានមកនៅសហរដ្ឋមេរិកក្នុងឆ្នាំ២000 ។ គាត់រៀនចប់ថ្នាក់បរិញ្ញាប័ត្រនៅមហាវិទ្យាល័យនៅរដ្ឋផិនស៊ីវេញ៉ា។ បន្ទាប់ពីបានជួបគ្នាជាមួយលោក ពិន សំខុន អ្នកទាំងពីរបានបង្កើតកាសែតខ្មែរផុស។ លោកស្រី សុបិនជាម្ចាស់កាសែតផង និងជាអ្នកចាត់ចែងទូទៅផ្នែកអាជីកម្មផង។

វេទិកានេះរៀបចំសម្របសម្រួលដោយលោក សុវណ្ណា ពៅ ជាប្រធានសមាគមខ្មែរ និងលោកស្រី ប្រែ្ហងឃី ដេកូតូ ជានាយិកាប្រតិបត្តិនៃអង្គការ EforAll ប្រចាំទីក្រុងឡូវែល និង Lawrence ។ សំណួរសំខាន់ៗនៅក្នុងវេទិកា គឺផ្តោតលើកត្តាជោគជ័យក្នុងការគ្រប់គ្រងអាជីវកម្ម និងសហគ្រាស។ វាគ្មិននីមួយៗបានចែករម្លែកបទពិសោធន៍ផ្ទាល់ខ្លួនអំពីបញ្ហាប្រឈម និងលក្ខណៈសម្បត្តិនៃសហគ្រិនពូកែ។

អ្នកចូលរួមមានឱកាសបញ្ចេញយោបល់ និងលើកអំពីគំនិតអជីវកម្មរបស់ខ្លួន។ វាគ្មិន និងអ្នកជំនួញដទៃទៀតដែលមានវត្តមាននៅថ្ងៃនោះបានផ្តល់ជាឱវាទល្អៗ ដើម្បីបង្កើតមុខរបរថ្មីមួយ។ ចំពោះអ្នកដែលចង់បើកមុខរបរថ្មីពួកគាត់អាចណាត់ជួបពិគ្រោះយោបល់បន្ថែមជាមួយអ្នកជំនាញពីអង្គការ EforAll និងមន្ត្រីសម្របសម្រួលផ្នែកអាជីវកម្មនៃសមាគមខ្មែរ។ ការពិគ្រោះយោបល់នេះ គឺផ្តល់ជូនដោយឥតគិតថ្លៃ។ **តទៅទំព័រទី ២១**







# សហគមន៍ខ្មែរនៅ"ចាកសិនវិល" រដ្ឋផ្លរីដា

**ដោយ ពិន សំខុន**

យើងបានឮខ្មែរយើងនិយាយពី"ចាកសិនវិល" កាន់តែច្រើនដោយសារខ្យល់ព្យុះបក់កាត់ច្រើនដង ដោយសារមានបង្កើតវត្តថ្មីក្នុងតំបន់ តែមិនដែលមកកាន់តំបន់នេះដើម្បីណែនាំសរសេរបង្ហាញពីតំបន់ដែលកាន់តែសម្បូរខ្មែរមករស់នៅកាន់តែច្រើននៅឡើយទេ។ កាលពីចុងឆ្នាំ២០១៥ យើងបានជួបលោក ថាវី សែម ជាអ្នករស់នៅ"ចាកសិនវិល" ធ្លាប់បានមកលេងនៅឡូវែល លោកបានណែនាំយើងឱ្យទៅមើលតំបន់របស់លោកដែលកំពុងតែរីកចំរើន។ នៅពេលដែលយើងមកដល់ក្រុង"កេសេមី"នៃតំបន់"អូឡិនដូ" ដែលជាតំបន់នៃក្តីស្រម័យរបស់កុមារនៅរដ្ឋ"ផ្លរីដា" នាដើមខែមករា២០១៦ យើងក៏សម្រេចចិត្តឆ្លៀតរកពេលទៅឱ្យដល់"ចាកសិនវិល"ដែលស្ថិតប្រមាណជា៣ម៉ោង នៅខាងជើងបង្អស់នៃរដ្ឋ"ផ្លរីដា"ដើម្បីរាយការណ៍ផ្តើមភ្ជាប់បងប្អូនខ្មែរនៅរដ្ឋ"ម៉ាសាឈូសិត" ឱ្យបានស្គាល់ខ្មែរអ្នករស់នៅ"ផ្លរីដា" ថាតើមានជីវភាពយ៉ាងណាហើយ?

ភូមិសាស្ត្រនៃរដ្ឋ"ផ្លរីដា"ដែលគេស្គាល់ជាទូទៅ គឺជាជ្រោយលយចូលសមុទ្រដ៏ធំមួយដែលនៅខាងចុងនឹងខាងត្បូងបង្អស់នោះមានឈ្មោះថាក្រុង"ម៉ាយ៉ាមី"ដ៏ល្បីល្បាញ រីឯតំបន់ខាងជើងបំផុតវិញ គឺទីក្រុង"ចាកសិនវិល"នេះឯង ដែលជាក្រុងដែលមានវិសាលភាពជាក្រុងធំបំផុតនៃសហរដ្ឋអាមេរិក ឥឡូវមានខ្មែរកាន់តែច្រើនមករស់នៅចាក់ឫសនៅទីនេះ។ សែម អតីតនិស្សិតសាលាពេទ្យមកដល់អាមេរិកមិនបានមកបន្តមុខវិជ្ជាជំនាញរបស់ខ្លួនវិញទេ តែមកធ្វើការធម្មតារស់នៅជាចាស់ទុំជួយណែនាំការដឹកនាំសង្គម តាមតែតម្រូវការនឹងតាមសម្បជញ្ញរបស់ខ្លួន។ សែម បាននិយាយថា ប្រជាពលរដ្ឋខ្មែរនៅទីនេះមាន៣-៤ពាន់នាក់ បើតាមស្ថិតិរដ្ឋចំនួននេះប្រាកដមិនពល្លើសទេ ដោយសារកូនខ្មែរដែលកើតនៅអាមេរិកទៅរៀនសាលាមិនដាក់ថា ខ្លួនជាខ្មែរទេ រីឯខ្មែរមួយចំនួនទៀតមិនទៅចុះឈ្មោះធ្វើជំរឿនទេ ដោយបារម្ភថា លិខិតស្នាមរបស់ខ្លួន





គណៈកម្មការវត្ត


ហាងសូរិយា

មិនគ្រប់គ្រាន់ក៏មិនព្រមបង្ហាញខ្លួន ដូច្នេះចំនួនពិតប្រាកដនោះ អាចគុណឡើងជាពីរដងលើសក៏បាននេះដោយសារចំនួនមនុស្សដ៏ច្រើន ដែលគេបានឃើញទៅធ្វើបុណ្យនៅវត្ត ឬក៏ទៅទិញឥវ៉ាន់ចិញ្ចឹមហាងលក់ទំនិញខ្មែរដែលមានបើកធំៗចំនួន៤ នៅទីនោះ។

យើងបានទៅឃើញហាងលក់ទំនិញជាច្រើនមានខ្មែរកាន់កាប់ដែលលក់បន្លែបង្កាត្រីសាច់គ្រប់មុខសម្រាប់ម្ហូបចំណីគ្រប់មុខនៃជនជាតិអាស៊ី មានខ្មែរ ឡាវ ថៃ វៀតណាម ភូមា ហើយក៏មានភ្ញៀវអាស៊ី ឬអាស៊ីហ្វ្រិកស្បែកខ្មៅ ឬក៏អាហ្វ្រិកាំងផងដែរ រីឯអាមេរិកាំងស្បែកសមានតិចតួចទេ ជាពិសេសអ្នកដែលស្គាល់សង្គ្រាមវៀតណាម។ ម្ចាស់ហាង "យេស៊ីកា"ដែលចេញមករកស៊ីពី"រ៉ូដអាយឡិន"រីករាយនឹងឃើញមានអ្នកកាសែតមកសួរនាំនៅហាង"សូរិយា"របស់ខ្លួន តែមិនចង់ឱ្យគេថតរូបរបស់ខ្លួនទេ ផ្ទុយទៅវិញម្ចាស់ហាងខ្មែរដែលគេស្គាល់ឈ្មោះថា"ដាយណូស័រ" និយាយថា "ចង់ឃើញខ្មែរកាន់តែច្រើនមករកស៊ីនៅទីនេះ តែខ្លាចគេមកយកភ្ញៀវខ្លួនអស់"។ ជនជាតិអាស៊ីឯទៀតៗ ដែលមានវៀតណាមនឹងថៃចូលចិត្តបើកមុខរបរ ជាភោជនីយដ្ឋានធំៗនៅ"ចាកសិនវីល"នេះ។ រាត្រីថ្ងៃទី២មករានៃឆ្នាំ២០១៦នេះ ដូចនៅតំបន់ឯទៀតៗនៃសហរដ្ឋអាមេរិកដែរ បងប្អូនខ្មែរបានមកជួបជុំគ្នាទទួលឆ្នាំថ្មីរាំកំសាន្តយ៉ាងរីករាយមុននឹងបន្តការងារប្រចាំជីវិតពេញមួយឆ្នាំថ្មីតទៅទៀត ។



ហាងដាយណឺស័រ

ក្នុងជំនឿដ៏ជ្រាលជ្រៅលើព្រះពុទ្ធសាសនាខ្មែរយើងបានបរិច្ចាគទ្រព្យធនដ៏ច្រើន ដើម្បីកសាងវត្តធំៗ២ វត្តទី១ដែលបានកើតមុនគេកាលពី២ឆ្នាំមុនឈ្មោះវត្ត...។ បានសម្ពោធយ៉ាងអធិកអធមតែប្រធានវត្តមានមោទនភាពនឹងនិមន្តសម្តេចសង្ឃ ទេព វង់ ពីកម្ពុជាមកជាគណធិបតីនៃពិធីសម្ពោធ ក៏បណ្តាលឱ្យមានបាតុកម្មប្រឆាំងយ៉ាងអធិកអធមដូចគ្នាដែរ ដោយសារប្រជា-ពលរដ្ឋជាជនភៀសខ្លួនពិរបបផ្តាច់ការ រីឯសម្តេចសង្ឃអង្គ ទេព វង់ ជាអង្គការលើនៃរបបនោះ... ក្រោយមករន្ទះបានបាញ់ត្រូវពីរដង ប្រជាជនបាននិយាយថា ជាបាបកម្មដែលបានធ្វើផ្ទុយនឹងវត្តុបំណងពលរដ្ឋម្ចាស់ទាន។ នៅមានវត្តទើបកើតថ្មីមួយទៀត ឈ្មោះ "វត្តខ្មែរសាវីរតនារាម" ដែលឮថា មានការគោរពក្បួនច្បាប់ទម្លាប់ជាងវត្តមុនមានរូបសម្ផស្សល្អស្អាតដូចវត្តនៅស្រុកខ្មែរ កំពុងមានប្រជាប្រិយភាព អាចជាអ្នកណែនាំដល់ជីវិតបរិសុទ្ធពលរដ្ឋដំបន់ខ្លួនបាន។ ឈ្មោះរបស់វត្តមានលក្ខណៈប្លែកមួយដែលគេដាក់ឈ្មោះ "សាវី"សប្បុរសជនខ្មែរ បានបូជាទ្រព្យ១លានដុល្លាសម្រាប់ទិញដីនឹងសង់វិហារឡើងបាននេះជាការរីកចម្រើនមួយដែលសហគមន៍ខ្មែរជំនាន់ក្រោយបានលើកដំកើងឈ្មោះបុគ្គលដែលកន្លងមកមានតែបុគ្គលនរោត្តម សីហនុ ឬ ហ៊ុន សែន តែប៉ុណ្ណោះដែលគេដាក់ឈ្មោះដើម្បីការចងចាំពីគុណបំណាច់។

ថ្វីត្បិតតែ"ផ្លរីដា"មានឈ្មោះល្បីថាជាជាទីប្រជុំនៃអ្នកមាន តែគំនិតនេះមិនប្រាកដជាត្រូវទេ ពីព្រោះតំបន់ដែលសហរដ្ឋអាមេរិកវិនិយោគខ្លាំងជាងគេដើម្បីទេសចរមាន៣-៤កន្លែងធំៗតែប៉ុណ្ណោះ ដូចជា "ម៉ាយ៉ាមី" នៅចុងខាងត្បូង "អ័រឡិនដូ"នៅកណ្តាលខាងកើត "ថមប៉ា" នៅកណ្តាលខាងកើត នឹង"ចាកសិនវិល"ជាទីប្រជុំជននៅខាងជើង"ផ្លរីដា" ដីដែលនៅសល់ដ៏ធំធេងច្រើនកន្លែងទៀត សុទ្ធតែជាដីចំការ ឬចិញ្ចឹមសត្វដាច់ស្រយ៉ាលជាកសិដ្ឋានដ៏ធំសម្បើមមួយនៅសហរដ្ឋអាមេរិក តែអាមេរិកាំងមិនសូវចូលចិត្តធ្វើទេ។ ដោយសារតែហេតុនេះហើយបានជាខ្មែរជាច្រើន ដែលមកចាប់ដីចំការ កសិកម្មថោកៗមុនគេបានក្លាយជា"មុលទិមីល្បេរាណែ"អ្នកមានច្រើនលានដុល្លារយ៉ាងឆាប់រហ័ស ដូចជាគេនិយាយពីឈ្មោះ រិទ្ធី នូវ នៅ"ផ្លរីដា"នេះជាដើម។ លទ្ធភាពជាអ្នកវិជ្ជាជីវៈជាកសិករសម័យ សុច្ចរឹតឧស្សាហ៍ ព្យាយាម អាចនឹងក្លាយទៅជាអ្នកមានសម្បត្តិច្រើន នៅមាននៅឡើយ គួរឱ្យមានការលើកទឹកចិត្តឱ្យខ្មែរៗដែលមានចិត្តចង់មកកាន់តំបន់"ហ្វ្លរីដា"ដើម្បីមកកាយយកកំណប់ធម្មជាតិដ៏សម្បូរនេះ ដោយសារសហរដ្ឋអាមេរិកនៅត្រូវការផលិតផលកសិកម្មខ្លាំងក្លានៅឡើយ ៕

# លោក ប៊ុនរិទ្ធ ឡាច ស្ថាបនិកក្រុងឡូវែលខ្មែរម្នាក់បានលាលោកទៅហើយ

## Bunrith Lach one of the figure of Lowell founder died

**ដោយ ខ្មែរផុសស.រ.អា.**

លោក ប៊ុនរិទ្ធ ឡាច បានប្រយុទ្ធជាមួយជម្ងឺមហារីកច្រើនឆ្នាំបានលាលោកយើងនេះ ដោយបានបន្សល់នូវស្នាដៃជាច្រើនក្នុងការកសាងកេរឈ្មោះគ្រួសារឱ្យមានកិត្តយសមានចំណេះ នឹងមានសម្បត្តិគ្រប់គ្រាន់គ្រប់គ្នាជាអ្នកពង្រីកទំហំនៃសហគមន៍ខ្មែរនៅឡូវែល ជាពិសេសទៅទៀត គឺបានក៏សាងទិក្រុងឡូវែលសង្កាត់លេខ ១៦ នឹងផ្តួចផ្តើមកំណើតនៃ"ក្រុងខ្មែរ" ដែលមានមុខមាត់ដូចសព្វថ្ងៃនេះ។

លោកបានចូលមរណភាពនៅថ្ងៃអាទិត្យ ទី២៤ មករា ឆ្នាំ២០១៦ ម៉ោង២:១០ នាទី រសៀល ក្នុងជន្មាយុ៦៦ឆ្នាំ នៅក្រុងឡូវែលចោលភរិយាដ៏រឹងមាំនៅថែជម្ងឺលោកជារៀងរហូតមក គឺលោកស្រី ម៉ាលី ថៃ នឹងកូនធំៗហើយ៣នាក់ គឺនឹងចៅបង្កើត... នាក់ទៀត។

រំលឹកសាវតាលោក ប៊ុនរិទ្ធ ឡាច លោកបាននិយាយប្រាប់ខ្មែរផុសស.រ.អា.ក្នុងបទសម្ភាសន៍ជាមួយ សូបិន កាលពីខែមេសាឆ្នាំ២០១៥ បានឱ្យដឹងថា: លោកជាអតីតនាយទាហ៊ានបញ្ជូនសារនៃសម័យសាធារណរដ្ឋខ្មែរពេលសាធារណរដ្ឋរលំទៅលោកនឹងគ្រួសារជាប់គុកជំនាន់ខ្មែរក្រហមជារៀងរហូតដោយសារគេសង្ស័យថា ជាទាហ៊ាន តែលោក ប៊ុនរិទ្ធ កុហកថា ជាអ្នកនៅបំរើក្នុងវត្តប្រយូវង្ស ដូច្នេះយប់គេដាក់គុកមានខ្នោះជើង ថ្ងៃឡើងគេដោះលែងឱ្យទៅធ្វើការ។ រហូតដល់ថ្ងៃវៀតណាមមករំដោះក៏ភៀសខ្លួនទាំងគ្រួសារមានកូននឹងក្មួយទៅស្រុកយួនដែលនៅមិនឆ្ងាយពីទីដែលលោករស់នៅទេ។ បន្ទាប់ពីនៅជាជនភៀសខ្លួននៅវៀតណាមមួយរយៈ គ្រួសារលោកក៏មកដល់បូស្តុនរដ្ឋម៉ាសាឈូសិតនៃសហរដ្ឋអាមេរិក នៅឆ្នាំ១៩៨១រៀនបានសញ្ញាប័ត្រខាងអេឡិចត្រូនិចរួចចូលទៅធ្វើការនៅរោងចក្រផលិតកុំព្យូទ័រឈ្មោះ"វ៉ាង"នៅឡូវែល ដែលមានបុគ្គលិកធ្វើការរាប់ម៉ឺននាក់នៅឆ្នាំ១៩៨៥ ។ ធ្វើការនៅ"វ៉ាង" បានមួយឆ្នាំ ក៏បែកគំនិតបើកហាងលក់ទំនិញ "ម្ហូបអាស៊ី" ក៏ទៅទិញហាងមួយដាក់ឈ្មោះថា "ប៉ៃលិន" ដែលឈ្មោះនេះបានរក្សារហូតមកដល់សព្វថ្ងៃនេះ។ នាឆ្នាំ១៩៨៥ នៅឡូវែលដែលមានខ្មែររស់នៅ៦-៧០០នាក់ ក៏រីកឡើងយ៉ាងឆាប់រហ័សទៅជា២ម៉ឺននាក់នៅឆ្នាំ ១៩៩០ រីឯហាងដែលបើកនៅតំបន់មាន ឈ្មោះថា "ក្រុងខ្មោច"ស្ងាត់ជ្រងំពីដំបូងក៏ក្លាយជាមានមនុស្សចេញចូលកាន់តែច្រើនឡើងដែរ តែក្រុម"ក្មេង"ទាំងខ្មែរទាំង"ក្មេង"បរទេសក៏ចេញចូលណាស់ដែរ។ ដោយសារក្រុមក្មេងទាំងនោះ ហាងលោក ប៊ុនរិទ្ធ បានត្រូវភ្លើងឆេះ២ដង ហើយនៅលើកទី២នេះ លោកសានសង់ជាថ្មីមាន២ជាន់ ហើយធ្វើពីឥដ្ឋនឹងថ្មវិញម្តង ហើយក៏មានទំហុំធំជាមុនមួយផ្នែកទៀត សង់វែងទៅដល់កន្លែងដែលហាង "កូឡាបក្រហម" សព្វថ្ងៃ។ ហាងថ្មីទាំងនោះដើរបាន៣-៤ឆ្នាំ ភាពតានតឹងរបស់សេដ្ឋកិច្ចអាមេរិកាំងក៏មកដល់បណ្តាលឱ្យលោក ប៊ុនរិទ្ធ

តទៅទំព័រទី ០៩


រូបថត ប៊ុនរិទ្ធ ឡាច ឆ្នាំ១៩៧០


លោក ប៊ុនរិទ្ធ ឡាច កាលនៅរស់


រូបថត ប៊ុនរិទ្ធ ឡាច អ្នកស្រី ម៉ាលី ថៃ


ផ្សារប៉ៃលិនបើកឡើងវិញបន្ទាប់ពីភ្លើងឆេះ



**ដំណឹងមរណភាព**

ឧបាសិកា **ថៃ ម៉ាលី** ជាភរិយា ព្រមទាំងបុត្រ **ឡាច មុនីតា ឡាច ម៉ាលីសា** លោក **អាន រ៉ាស៊ី** អ្នកស្រី **អាន ខណ្ឌារ័ត្ន** និងបុត្រ លោក **អាន រ៉ាមី** និងបុត្រ អ្នកស្រី **ឡាច ស៊ី ម៉ាន** ព្រមទាំង គ្រួសារ និងបុត្រ លោក **ឡាច ស៊ីផាន** ភរិយានិងបុត្រ អ្នកស្រី **ឡាច ថារី** លោក **ឃាង យ៉ានី** និងបុត្រ លោក **ឡាច ស៊ីថា** អ្នកស្រី **ម៉ាន់ ឆេង** និងបុត្រ មានទុក្ខជាទម្ងន់ដោយលោក **ឡាច ប៊ុនរិទ្ធ** បានទទួលមរណភាពកាលពីថ្ងៃអាទិត្យ ទី ២៤ ខែមករា ឆ្នាំ ២០១៦ វេលាម៉ោង ២:១៦នាទី រសៀល នៅមន្ទីរពេទ្យ Boston Medical Center ដោយរោគាពាធ ក្នុងជន្មាយុ ៦៣ ឆ្នាំ ។

**កម្មវិធីបុណ្យ**

**វត្តពន្លឺពុទ្ធចក្ក** GLORY BUDDHIST TEMPLE

24 Cambridge Street Lowell, MA 01851 Telephone (978) 458-0498

**ថ្ងៃព្រហស្បតិ៍ ៥រោចខែបុស្ស ឆ្នាំមមែសប្តស័ក ព.ស.២៥៥៩ ត្រូវនឹងថ្ងៃ២៨ ខែមករា ឆ្នាំ ២០១៦** Thursday January 28, 2016

ម៉ោង៩:០០ព្រឹក : វេរស្វសពមកដំកល់នៅក្នុងវត្តពន្លឺពុទ្ធចក្ក

ម៉ោង១០:០០ព្រឹក : នមស្សការព្រះរតនត្រ័យ សមាទានសីល ដាក់បាត្រ វេរភត្ត

**ម៉ោង៦:០០ល្ងាច : នមស្សការព្រះរតនត្រ័យ សមាទានសីល ចំរើនព្រះបរិត្ត ទេសនា**

**ថ្ងៃសុក្រ ៦រោចខែបុស្ស ឆ្នាំមមែសប្តស័ក ព.ស.២៥៥៩ ត្រូវនឹងថ្ងៃ២៩ ខែមករា ឆ្នាំ ២០១៦** Friday January 29, 2016

ម៉ោង៧:០០ព្រឹក : ប្រគេនយាគូដល់ព្រះសង្ឃ

ម៉ោង៧:៣០ព្រឹក : ជួបជុំបងប្អូនញាតិមិត្រជិតឆ្ងាយ និងគ្រួសារនៃសព

ម៉ោង៨:៣០ព្រឹក : ដង្ហែរសពចេញពីវត្តពន្លឺពុទ្ធចក្កឆ្ពោះទៅកាន់កន្លែងបញ្ចុះសពនៅ Fairview Cemetery 25 Main Street North Chelmsford MA 01863

ម៉ោង១០:០០ព្រឹក : នមស្សការព្រះរតនត្រ័យ សមាទានសីល ដាក់បាត្រ

ម៉ោង១១:០០ព្រឹក : វេរភត្តាហារប្រគេនព្រះសង្ឃ

ដំណឹងនេះ: ចាត់ទុកជាសេចក្តីអញ្ជើញដល់ពុទ្ធបរិស័ទ និងញាតិមិត្រជិតឆ្ងាយទាំងអស់ មេត្តាអញ្ជើញមកចូលរួមក្នុងពិធីបុណ្យសពនេះ ឲ្យបានច្រើនកុះករ ដើម្បីជួយរំលែកទុក្ខដល់យើងខ្ញុំដែលត្រូវជាក្រុមគ្រួសារនៃសព។

**បុណ្យខួប៧ថ្ងៃ**

Saturday January 30, 2016

**ប្រារព្វធ្វើនៅភោជនីយដ្ឋាន ប៉ៃលិន**

**៩:០០ព្រឹករហូត ដល់ម៉ោង ១២ ថ្ងៃត្រង់**

នមស្សការព្រះរតនត្រ័យ សមាទានសីល ដាក់បាត្រ វេរភត្តប្រគេនព្រះសង្ឃ

For more information please contact:

Rasy: (978) 319-8958 Bonieta: (978) 761-9662 Chinsan: (978) 421-6869

Malissa: (978) 596-5284

# ទស្សនសារព័ត៌មានពីថ្ងៃទី២៨វិច្ឆិកា២០១៥ ដល់ ១៥មករា២០១៦

**ដោយ ប្រាំងស្វា ប៉ុងស្លូ"បកប្រែពីភាសាបារាំងមកខ្មែរដោយខ្មែរផុសស.រ.អា."**

ភាពតឹងតែងរវាងគណបក្សដែលប្រឆាំងគ្នាចេះតែធ្លាក់ចុះបន្តិចម្តង -គេត្រូវតាមដានព្រឹត្តិ-ការណ៍នយោបាយប្រចាំខែថា ជាដំណើរយឺតៗតែច្បាស់លាស់ទៅរកការដណ្តើមអំណាចរបស់គណបក្សប្រជាជន"គ.ប.ជ."។

-ថ្ងៃ៣០វិច្ឆិកា បន្ទាប់ពីការវាយប្រហារដែលធ្វើឱ្យរងគ្រោះសមាជិសភា២រូបរបស់គណបក្សសង្គ្រោះជាតិ"គ.ស.ជ." គារទម្លាក់ដំណែង កឹម សុខា ពីដំណែងអនុប្រធានសភាជាតិនឹងថែមទាំងមានការដកអភ័យឯកសិទ្ធពី សម រង្ស៊ី មក កឹម សុខា ចាប់តាំងពីពេលនោះទៅក្លាយជាប្រមុខនៃគណបក្សប្រឆាំងបានសម្រេចឱ្យសមាជិកទាំង៥៥របស់គណបក្សសង្គ្រោះជាតិធ្វើពហិការប្រឆាំងនឹងសភាជាតិដ៏រាបណាគណបក្សប្រជាជនមិនធានាសន្តិសុខឱ្យពួកគេនឹងមិនធ្វើការធ្វើសកម្មភាពនៅក្នុងបរិយាកាសហការនៃរដ្ឋសភា"ខ.ដ.ទី២៩.១១.១៥"។ដំណាងរាស្ត្រ "គ.ស.ជ." ម្នាក់និរទេសខ្លួនដោយខ្លួនឯងទៅប្រទេសបារាំង ដើម្បីគាំទ្រ សម រង្ស៊ី "ខ.ដ.ទី០១.១២.១៥"។ យោធាពរូបបានត្រូវចោទប្រកាន់ថា ជាអ្នកផ្តើមគំនិតធ្វើអំពើហឹង្សាលើតំណាងរាស្ត្របក្សប្រឆាំង តែ សម រង្ស៊ី ចោទថា ហ៊ុន សែន ជាអ្នកផ្តើមគំនិត "ខ.ដ.ទី០៨.១២.១៥"។ មានការចាប់ខ្លួនមន្ត្រីទទួលខុសត្រូវថ្នាក់តូចនៅតាមតំបន់របស់គ.ស.ជ.ដែលត្រូវភ្ជាប់នឹងបរិយាកាសតឹងតែងរវាងគណបក្សទាំងពីរ។

-មានដីការចោទប្រកាន់៣ ស្តីពីបរិហាកេរទៅលើ សម រង្ស៊ី **ក.** ដោយបាននិយាយកាលពីឆ្នាំ២០១១ ថារដ្ឋមន្ត្រីការបរទេសសព្វថ្ងៃ គឺជាសមាជិកក្រុមខ្មែរក្រហម **ខ.**ការអនុញ្ញាត្តឱ្យប្រើទំព័រ"វេបសាយ"ដាក់ផែនទីក្លែងក្លាយរបស់ព្រឹទ្ធសមាជិក ហុង ស៊ុនហួន **គ.** ដើមបណ្តឹងដោយ ហេង សំរិន ប្រធានសភាជាតិដែលចោទប្រកាន់ថា បានសរសេរលើទំព័រ "ហ្វេសប៊ុក" ថ្ងៃទី១៧.១១ ថា "គណបក្សប្រជាជនបានកាត់ទោសប្រហារជីវិតសម្តេច ស៊ីហនុ នៅឆ្នាំ១៩៨០។ ថ្ងៃទី៩ធ្នូ ដីកាអាជ្ញាចេញឱ្យរកចាប់ខ្លួន សម រង្ស៊ី ដោយសារមិនបានមកបង្ហាញខ្លួនជាសាក្សីក្នុងករណី ហុង ស៊ុនហួន ។

-ថ្ងៃទី២ខែធ្នូ សមាជិកសភាអាមេរិកាំង១៦រូប បានផ្ញើរលិខិតទៅនាយករដ្ឋមន្ត្រី ហ៊ុន សែន សុំឱ្យបញ្ចប់ការដាក់ទោសទៅលើគណបក្សប្រឆាំង"ខ.ដ.ទី១១.១២.១៥"។

-ថ្ងៃទី៩ធ្នូ សម រង្ស៊ី បានណែនាំឱ្យតំណាងរាស្ត្រខាងខ្លួនឈប់ធ្វើពហិការលើសភាជាតិ ហើយសហការតាមករណីមួយម្តងៗជាមួយរដ្ឋាភិបាល។ មន្ត្រី"គ.ស.ជ."បានត្រឡប់ទៅទាក់ទង"គ.ប.ក." ដើម្បីពិភាក្សាច្បាប់ស្តីពីសហជីពការបង្កើតគណកម្មការថ្មីមួយសម្រាប់ចរចារពី"វប្បធម៌សន្ទនា" នឹងដើម្បីដោះស្រាយបញ្ហាផ្សេងៗ តាមវិធីប្រជា-ធិបតេយ្យ"ខ.ដ.ទី១១.១២.១៥"។

-ហ្វេសប៊ុកដែលបានធ្វើឱ្យ សម រង្ស៊ី ឈ្នះឆ្នោតកាលពីឆ្នាំ២០១៣ ឥឡូវបានត្រូវប្រើពេញទំហឹងដោយនាយករដ្ឋមន្ត្រីខ្មែរ ដែលកំពុងក្លាយទៅជា"តារានៃហ្វេសប៊ុក"នេះបើតាមសម្តី ធន់ សារ៉ាយ ប្រធាន"អាដហុក"។ លោកមានផ្សាយរូបថតដែលបង្ហាញពីរូបគាត់ជាមនុស្សធម្មតានៅជិតពលរដ្ឋងូតទឹកនៅ"កែប"នៅវិស្សមកាលដ៏ខ្លីជាមួយគ្រួសារ...។ល។ ថ្ងៃ៣១ធ្នូគាត់ទទួលបានជាង១លាន"ចូលចិត្ត"។ ជាមួយគ្នានោះការត្រួតពិនិត្យរបស់រដ្ឋាភិបាលលើ"ហ្វេសប៊ុក"ឬតែមានការគាបសង្កត់ខ្លាំងឡើង: អ្នកសរសេរដែលមានគំនិត ឬសំដី ឬរូបថតប្រឆាំងនឹងរដ្ឋាភិបាលត្រូវបានគេដាក់គុក។ "គ.ស.ជ." បានអញ្ជើញសមាជិករបស់ខ្លួនឱ្យបញ្ឈប់ការប្រមាថទៅអ្នកដែលខ្លួនប្រឆាំង"ខ.ដ.ទី៩.០១.១៦"។

-ថ្ងៃទី៩-១០មករា សមាជិក "គ.ប.ក." បានបើកសន្និបាទប្រចាំឆ្នាំមួយនៅភ្នំពេញ។ បើគេមានការពេញចិត្តនឹងកំណើនសេដ្ឋកិច្ច ហើយបោះឆ្នោតបង្កើតច្បាប់ថ្មី គឺគេនឹងដកមេរៀនពីបរាជ័យកាលពីការបោះឆ្នោតឆ្នាំ២០១៣ គឺថា: ប្រាក់ខែកម្មករ នឹងរាជការ ត្រូវតម្លើង "ពី៨០ទៅ១៤០សម្រាប់ក្រុមទី១ នឹង ពី១២០ទៅ២៥០សម្រាប់អ្នកឯទៀត" កិច្ចព្យាបាលដោយឥតគិតថ្លៃសម្រាប់អ្នកក្រ -បង្កើតប្រពន្ធសន្តិសុខសង្គម -បញ្ចុះតម្លៃភ្លើងអគ្គិសនីនឹងប្រេងសាំង ។ល។ សមាជិក"គ.ប.ក."និយាយថា "នេះគឺជាបញ្ហាអាយុជីវិត"។ គណបក្សប្រឆាំងថ្លែងសសើរពីសេចក្តីសម្រេចចិត្តដែលដកចម្លងយកពីកម្មវិធីឃោសនាបោះឆ្នោតឆ្នាំ២០១៣: តែនៅសង្ស័យនៅឡើយ ថាមនុស្សដែលនៅធ្វើការកន្លែងដដែល១-២០ឆ្នាំហើយ ទោះនឹងប្តូររបៀបធ្វើការបានដោយរបៀបណា? ជាពិសេស ថាតើនឹងមានធនធានរបៀបណា ដើម្បីទ្រទ្រង់ការផ្លាស់ប្តូរនោះ? **តទៅទំព័រទី១០**






## តមកទំព័រទី ០១ រាត្រីសម្ពោធអង្គការ"មូលនិធិភ្នំដងរែក"...

ដំណឹងថា នឹងមានព្យុះព្រិលធ្លាក់មកទៀតនារាត្រីនោះដែរ តែមិនបានឃាត់ភ្ញៀវជិតឆ្ងាយមិនឱ្យមកទេ លើកលែងតែភ្ញៀវសំខាន់ម្នាក់ឈ្មោះ"អង់ទ្រូ"មកពីកម្ពុជាបុគ្គលិកអ.ស.ប.មកខកដំណើរគួរឱ្យស្តាយជាប់នៅ"វេរ្ជីនា"ដោយយន្តហោះទាំងអស់ត្រូវផ្អាកដំណើរដោយសារធ្លាក់ព្រិលខ្លាំងពេក។

ក្រុងមុនបានចាប់ផ្តើម ហើយការិយាល័យលោកនឹងបើកចំហរជានិច្ចសម្រាប់អ្នកទាំងអស់គ្រប់ពេលដែលត្រូវការរួមគ្នានឹងក្រុមប្រឹក្សាក្រុងទាំងអស់រីករាយនឹងទទួលស្តាប់នូវគ្រប់បញ្ហាទាំងឡាយដែលសហគមន៍ខ្មែរចង់លើកយកមកឱ្យដោះស្រាយ។

លោក វណ្ណៈ ឡាញ់ ជាអនុប្រធាន "មូលនិធិភ្នំដងរែក"នឹងជានាយកគ្រប់គ្រងវិស្វកម្មខាង








ម៉ោង៧កន្លះ យប់ភ្ញៀវជាង១៥០នាក់បានមកដល់រួចជាស្រេចអនុញ្ញាត្តឱ្យពិធីករ មួង ណារ៉េត ផ្តើមកម្មវិធីដោយអញ្ជើញលោក ឈុំ ឈាង មកសម្ពោធរាត្រី "មូលនិធិភ្នំដងរែក"។ តាមរយៈសុន្ទរកថា បើកឆាកដ៏ខ្លីគេដឹងថា អង្គការមូលនិធិនេះមានបំណងរៀបចំខ្លួននឹងកម្មវិធីដើម្បីត្រឡប់ទៅជួយអភិវឌ្ឍន៍ប្រជាពលរដ្ឋខ្មែរនៅក្នុងតំបន់ខាងជើងនឹងខាងកើតកម្ពុជាដែលរងគ្រោះមិនចេះចប់ដោយសង្គ្រាមបន្តបន្ទាប់គ្រប់ជំនាន់ធ្វើឱ្យពលរដ្ឋក្លាយជាជនភៀសខ្លួនលំបាកវេទនារហូតមកដល់សព្វថ្ងៃនៅក្នុងចំណោមពលរដ្ឋទាំងនោះ ធ្លាប់មានលោក ឈុំ ឈាង នឹងមិត្តភក្រ្តរួមកាងារមូលនិធិច្រើនរូបដែរ។


Chum Cheang

ភ្ញៀវកិត្តយសបន្តរមកទៀត ឡើងមកថ្លែងសុន្ទរកថា គឺអភិបាលក្រុងថ្មីរបស់ក្រុងឡូវែល អេដវើដ ខេណ្ណឺឌី លោកមកផ្តល់កិត្តិយសនឹងសម្តែងការគាំទ្រដ៏ស្មោះស្ម័គ្រដល់សហគមន៍ខ្មែរដែលមិនភ្លេចនឹកត្រឡប់ទៅជួយកម្ពុជាវិញតំបន់ទល់ដែនដែលលោកធ្លាប់បានឃើញ ហើយលោកនិយាយបន្ថែមថា "នឹងបន្តការងារដែលអភិបាល


Mayor Ed Kennedy

សំណង់នៅ "ហ្លរីដា" លោកថ្លែងពីមូលហេតុដែលនាំឱ្យបង្កើត "មូលនិធិ"នេះ ឡើងថា អភិវឌ្ឍន៍នៅតំបន់ភ្នំដងរែកមិនអាចធ្វើទៅបានទេ ប្រសិនបើមិនមានការធ្វើឱ្យមានការផ្លាស់ប្តូរការចរន្តគំនិតរបស់ប្រជាជននោះទេ ឧប្បមាកាលពីជំនាន់មុនមិនសូវមានរថយន្តដឹកមនុស្សគេនាំគ្នាជិះរថយន្តធំៗនោះជាន់កគ្នា តែឥឡូវឡានក៏មានច្រើនការងារក៏មានធ្វើតែមនុស្សនៅតែជិះឡានជាន់កគ្នាដដែលនេះគឺការដែលមិនមានអ្វីផ្លាស់ប្តូរពីជំនាន់មួយទៅជំនាន់មួយទៀត ដូច្នេះដើម្បីជួយខ្មែរឱ្យបាន គឺជួយឱ្យមានការផ្លាស់ប្តូរការគិតរបស់ខ្មែរនៅជនបទ គឺជាការសំខាន់ណាស់...។


Vanna Lanh

បន្ទាប់មកលោក សុផារីទ្ធ ហ៊ី ជាវាគ្មិនសំខាន់ម្នាក់ទៀត មានបទពិសោធន៍៣២ឆ្នាំធ្វើការនៅអ.ស.ប. ញូយ៉ក ផ្នែកកងរក្សាសន្តិសុខនឹងផ្នែកកម្មវិធីមនុស្សធម៌ចេញទៅធ្វើការមមាញឹកនៅប្រទេសជាច្រើន ក្នុងសកលលោក លោកថ្លែងទៅកាន់ភ្ញៀវក្នុងសុន្ទរកថា ដ៏វែងមួយថា លោកមើលឃើញ ហើយបារម្ភថា នៅបន្តិចទៀតនេះ កម្ពុជានឹងបើកព្រំប្រទល់រកស៊ីជាមួយប្រទេសអាស៊ានពេលនោះខ្មែរនឹងមិនមានអ្វីចំណេញពីការចូលអាស៊ាននេះ


Sopharith Hy

ទេ ពីព្រោះប្រជាពលរដ្ឋខ្មែរតាមជនបទពុំបានទទួលការអប់រំសម្រាប់អភិវឌ្ឍន៍របៀបនេះទេ ទំនាក់ទំនងសេដ្ឋកិច្ចជាច្រើនធ្វើតែនៅទីក្រុងហើយអាជ្ញាធរមិនបានពង្រីកឱ្យទៅដល់ជនបទនៅលើយទេ ហេតុនេះ អនាគតនៃជនបទខ្មែរនៅតែលំបាកវេទនាដដែល...។

លោក រ៉តនី អេលីយ៉ុត សមាជិកក្រុមប្រឹក្សាក្រុងដ៏សំខាន់ម្នាក់សម្រាប់សហគមន៍ខ្មែរគាត់ជាអតីតអភិបាលក្រុងឡូវែល លោកបានរំលឹកពីតំបន់ព្រំប្រទល់ដែនអតីតជុំរំភៀសខ្លួនខ្មែរដែលលោកបានស្គាល់លោកសំដែងនូវការស្រឡាញ់គាំទ្រសហគមន៍ខ្មែរនៅឡូវែលដូចដែលកាលពីនៅជា អភិបាលដដែល។


Rodney Elliott

នារីពីររូបដែលដែលមានតួនាទីសំខាន់ក្នុងសហគមន៍ហើយស្ម័គ្រចិត្តបំរើនៅក្នុង"ក្រុមការងារ១៦របស់មូលនិធិ" គឺអ្នកស្រី អាណាបែល លក្ខិណាផល្លី ប្រធានក្រុងខ្មែរនៅឡូវែលនឹងអ្នកស្រី បុផ្ផាពៅជាម្ចាស់ពាណិជ្ជកម្មមួយនឹងជាអតីតប្រធានអាជ្ញាធរគ្រប់គ្រងការចែកផ្ទះដល់អ្នកមានធនធានតិចបានឡើងមកថ្លែងអំណរគុណភ្ញៀវដែលបាន


Leakhana


Bopha

ខិតខំចំណាយពេលមកចូលរួមអបអររាត្រីសម្ពោធ "មូលនិធិភ្នំដងរែក"ដ៏ថ្មីថ្មោងនេះ។

ភ្ញៀវទាំងអស់មកពីច្រើនតំបន់នៃសហរដ្ឋអាមេរិកដែលភាគច្រើនជាអតីតជនភៀសខ្លួនបានទះដៃអបអរជូនពរគណកម្មការនៃអង្គការថ្មីមួយនេះ ដែលហាក់ដូចជាសម្មិទ្ធិរបស់ខ្លួនម្នាក់ៗ រួចបន្តពិសារភោជនាហារយ៉ាងឆ្ងាញ់ពិសារនឹង


ផ្តិតរូបមុនលាគ្នា

រាំរែកជាមួយក្រុមតន្ត្រីមានឈ្មោះល្បី"បែដបួយ" ចូលរួមបន្ថែមដោយអ្នកចម្រៀង"កន្រ្ទឹម"កញ្ញាសូ សូភ័ក្រ្ត ដែលគេមិនអាចបំភ្លេចបានផង។

**កំណត់និពន្ធ:** ក្នុងពេលដែលវាគ្មិនកំពុងថ្លែងការមានអ្នកកាន់ប្រអប់មួយក្រុមដើរអង្គាសលុយតាមតុ...នៅពេលសម្រាកភ្លេងបន្តិចលោក ទូច វ៉េន ជាអនុប្រធានក្រុងខ្មែរថ្មីថ្មោង បានឡើងប្រកាសតាមមីក្រូថា "សមាគមក្រុងខ្មែរអង្គាសបានថវិការជាង៦០០ដុល្លារ" ដែលធ្វើឱ្យភ្ញៀវជាច្រើនមានការភ្ញាក់ផ្អើលនឹងខកចិត្តដោយមិនមាននរណាប្រកាសប្រាប់ឱ្យដឹងជាមុនម្ចាស់ទានទឹកថា ខ្លួនបានធ្វើអំណោយទៅមូលនិធិតែបែរជាក្រុងខ្មែរជាអ្នកទទួលទៅវិញ ៕

# ស្ត្រីឆ្នើមតៃវ៉ាន់

**បកប្រែនិងរៀបរាងដោយ៖ តារាយុទ្ធ ហង្ស**

សៃអ៊ីង-វិន Tsai Ing-wen ដែលជាអតីតសាស្ត្រាចារ្យផ្នែកច្បាប់បានបង្កើតនូវប្រវត្តិសាស្ត្រ




ដ៏អស្ចារ្យបន្ទាប់ពីបានជាប់ឈ្មោះជាប្រធានាធិបតេយ្យតៃវ៉ាន់ Taiwan ។

មុននឹងក្លាយជាប្រធានាធិបតេយ្យអ្នកស្រីធ្លាប់បំរើការជាទីប្រឹក្សាអតីតប្រធានាធិបតេយ្យលី តេងហួយ Lee Teng-hui ដោយអ្នកស្រីបានជួយធ្វើនូវសេចក្តីព្រៀងច្បាប់ទំនាក់ទំនងរដ្ឋនឹងរដ្ឋរបស់លោក តេង ហួយ ដែលគាត់ចាត់ទុកជាសេចក្តីព្រៀងទំនាក់ទំនងរវាងប៉េកាំង និងតៃប៉េក Beijing and Taipei ។ ស្ថិតក្រោមការគ្រប់គ្រងប្រធានាធិបតេយ្យបន្ទាប់ដែលមានឈ្មោះថា ឈិន សួយពាន Chen Shui-bian ទំនាក់ទំនងផ្នែកនាវាចរណ៍របស់ចិននឹងតៃវ៉ាន់ គឺកាន់តែអាក្រក់ទៅ ប៉ុន្តែអ្នកស្រីបានរកឃើញនូវវិធី



មួយក្នុងការពង្រឹងទំនាក់ទំនងផ្នែកនាវាចរណ៍ជាមួយចិនដោយបានបង្កើតនូវកម្មវិធី "ភ្ជាប់ទំនាក់ទំនងតូច Small Mini Links" ក្នុងឆ្នាំ២០០១ ដែលអនុញ្ញាតឱ្យសាឡាងដឹកជញ្ជូន នឹងធ្វើពាណិជ្ជកម្មរវាយកោះដាច់ស្រយាលរបស់តៃវ៉ាន់ជាមួយនឹងចិនដីគោក។ អ្នកស្រីក៏បានជំរុញឱ្យមានការបង្កើតការជួលនៃការហោះហើរដំបូងបង្អស់របស់ភាគតីរទាំងពីរ។ កាលពីឆ្នាំ២០០៣ ដោយមានការព្រួយបារម្ភរវាងទំនាក់ទនងចិន ហើយនឹងតៃវ៉ាន់អ្នកស្រីបានជំរុញឱ្យលោកប្រធា-នាធិបតេយ្យ ឈិន និង សមាជិកក្រុមសភាឱ្យកែប្រែនូវច្បាប់ទំនាកទំនងជាមួយចិនដោយអនុញ្ញាតអោយអ្នកជំនួញធ្វើវិនិយោគទុននៅឯចិនដីគោក។ យោងទៅតាមលោក ហូមីយូ Ho Mei-yueh ដែលជាអតីតមន្ត្រីផ្នែកសេដ្ឋកិច្ចដែលមានទំនាក់ទំនងយ៉ាងស្អិតល្មួតផ្នែកការងារជាមួយនឹងអ្នកស្រី សៃ បានឱ្យដឹងថា បើតាមទស្សនៈរបស់អ្នកស្រីការធ្វើពាណិជ្ជកម្មនឹងដឹកជញ្ជូនតាមផ្លូវទឹកបែបនេះគឺកើតឡើងដោយខុសច្បាប់ជាយូរមកហើយ ដូច្នេះអ្នកស្រីគិតថា រាជរដ្ឋាភិបាលគួរតែបង្កើតនូវច្បាប់មួយដែលអនុញ្ញាតឱ្យប្រជាជនធ្វើពាណិជ្ជកម្ម នឹងដឹកជញ្ជូនតាមផ្លូវទឹកដោយស្របច្បាប់វិញ។

ហើយនៅក្នុងសៀវភៅរបស់អ្នកស្រីក៏បានបង្ហាញនូវទស្សនៈវិជ្ជាមួយដែលដកស្រង់ចេញពីសង្គមវិទូអាឡឺម៉ង់ដែលមានឈ្មោះថា Max Weber "ពួកយើងត្រូវតែអត់ធ្មត់ នឹងធ្វើការដោយសន្សឹមៗ ដើម្បីសំរេចនូវការងារឱ្យបានល្អបំផុត។ ហើយនេះគឺជាវិធីសាស្ត្រធ្វើការរបស់ខ្ញុំ" ៕

# ពីមនុស្សដែរសង្គមស្អប់ខ្ពើម ក្លាយជាជនសប្បុរស

**ដកស្រង់នឹងរៀបរាងដោយ តារាយុទ្ធ ហង្ស**

ដោយត្រូវបានគេនិរទេសពីសហរដ្ឋអាមេរិកមកកម្ពុជា ពីព្រោះតែជាប់ពាក់ព័ន្ធបទឧក្រិដ្ឋ និងការរំលោភបំពានកាលពីឆ្នាំ២០១៤ លោក សូបិល ទុយ ជាអតីតសមាជិកក្រុមបងធំបានទទួលនូវឱកាសម្តងទៀតក្នុងការចាប់ផ្តើមនៅជីវិតថ្មី ។ នៅពេលមកដល់កម្ពុជា ជាលើកដំបូងលោកមានបំណងរស់នៅជាកសិករសាមញ្ញ ប៉ុន្តែដោយសារតែមានបំណងចង់ជួយកុមារក្រីក្រតាមរយៈសិល្បៈហ៊ីបហប (HIP HOP) សូបិល បានបង្កើតអង្គការក្រៅរដ្ឋាភិបាលមួយដែរមានឈ្មោះថា (ថាយនី ទូន Tiny Toones)។ បើយោងទៅតាមលោក ទុយ ដែលបានមានប្រសាសន៏ថា (ហីបហបគឺទំរង់សិល្បៈនៃការអប់រំមួយ ពីព្រោះបើកុមារចង់រៀនរេប (Rap) ពួកត្រូវដឹងអំពីចង្វាក់នៃភ្លេងរបស់វា។ អង្គការនេះក៏បានទាក់ទាញ និងជួយនូវចំនួនកុមារ នឹងយុវជនរាប់រយនាក់ជារៀងរាល់ថ្ងៃឱ្យចូលរៀនមិនត្រឹមតែសិល្បៈហីបហបនោះទេ ក៏នូវមុខវិជ្ជា ដូចជា គណិត កុំព្យូទ័រ អង់គ្លេស ខ្មែរ នឹងប្រវត្តិសាស្ត្រ។



បើយោងតាម សន មករា មានអាយុ២៣ឆ្នាំ ដែល ធ្លាប់ត្រូវបានលោក សូបិល ទទួលបង្រៀននឹងឱ្យស្នាក់នៅបាននិយាយថា "ខ្ញុំចាប់ផ្តើមសេពគ្រឿងញៀននឹងចាកចេញពីផ្ទះនៅអាយុ១៤ឆ្នាំ ប៉ុន្តែសំណាងល្អដែរ មានអង្គការ "Tiny Toones" ឥឡូវនេះខ្ញុំបានក្លាយជាមនុស្សធម្មតា នឹងធ្វើការជាគ្រូបង្រៀននៅឯមជ្ឈមណ្ឌលនេះ។ ហើយវាពិតជាបានផ្លាស់ប្តូរនូវជីវិតរប់សខ្ញុំមែន"។ ជារឿយៗនៅពេលដែលគាត់ចូលទៅក្លឹបកំសាន្តរាត្រីគាត់តែងតែជួបកុមារដែលគាត់ធ្លាប់បង្ហាត់បង្រៀនរាំ រេប នឹង ជាអ្នកចាក់បទចម្រៀង "ឌីជេ" ហៅឈ្មោះរបស់គាត់ដោយការដឹងគុណនឹងគោរព។ សូបិល ក៏បានមានប្រសាសន៏ថា "មិនថាក្រ ឬមានទេ អ្នកមិនគួរភ្លេចដើមកំណើតរបស់អ្នកទេ" ៕






ដំណឹងខ្លីៗ

# “ខពលស្កែរ Cuple square” ធ្វើដល់ណាហើយ?


City Manager, Kevin Murphy

**ដោយៈ ខ្មែរផុស.ស.រ.អា.**

**ឡូវែលៈ** សហគមន៍តំបន់”ខពលស្កែរ”បាន មកជួបជុំគ្នានៅភោជនីយដ្ឋាន”កាបតែន” តាម សេចក្តីអញ្ជើញរបស់”សមាគមពាណិជ្ជករខ្មែរនៅ ឡូវែល” តំណាងដោយ អាដាម ព្រិល – ចិត្ត គីម នឹង សុវណ្ណ ខុន ។ ភ្ញៀវផ្លូវការដែលអញ្ជើញមក ចូលរួមមានអភិបាលក្រុងថ្មី ខេណ្ណឌី នឹងក្រុម ប្រឹក្សាក្រុងមាននាយកសាលាក្រុង ខេវិន ម័រហ្វី មកជាមួយនឹងក្រុមបច្ចេកទេសសំណង់សាលាក្រុង ខាងតំណាងនគរបាល ។ល។ ពាណិជ្ជករនាសហគមន៍ ”ខពលស្កែរ” ប្រមានជា២០នាក់ រួមដោយទូច វ៉ែន នឹងចម្បា ប៉ាង តំណាងឱ្យ ”ក្រុងខ្មែរ” មានបំណង នឹងតាំងសំនួរ ព្រមទាំងមានសំណើរមួយចំនួន ជូនដល់ក្រុមអ្នកមានសមត្ថកិច្ច ។

លោក ខេវិន ម័រហ្វី នាយកប្រតិបត្តសាលា ក្រុងបានមកថ្លែងពន្យល់ពីការយកចិត្តទុកដាក់ របស់សាលាក្រុងដោយមានការស្តាប់សម្លេងអ្នក ទិទៀននឹងអ្នកឱ្យយោបល់ដើម្បីកែរតម្រូវតាម បំណងអ្នករស់នៅក្នុងតំបន់។ រួចមកលោក ខេវិន ខប្លិន នាយករង ក៏ឡើងថ្លែងរំលឹកពីការងារបាន ធ្វើរួចហើយ ដូចជាផ្លូវកែរថ្មី ចាក់កៅស៊ូរួច ធ្វើ ចិញ្ចើមថ្នល់រួច ហើយថែមទាំងដាក់ភ្លើងបំភ្លឺថ្នល់ ថ្មីផង ។ ម្ចាស់ពាណិជ្ជកម្មម្នាក់ស្នើសុំឱ្យប្តូរកន្លែង ”សំចតរថយន្តក្រុង” ដែលបានរំខាងដល់ភ្ញៀវត្រូវ មកទិញឥវ៉ាន់នៅហាងរបស់ខ្លួន វាគ្មិនម្នាក់ទៀត ស្នើឱ្យដាក់”បង្គោលចំណតរថយន្ត”ដែលអនុញ្ញាត ឱ្យភ្ញៀវអាចឈប់ដោយឥតយកកម្រៃចំនួន១ ម៉ោងនៅលើផ្លូវ”វ៉ែសហ្វឹត”មុននឹងបន្តគិតលុយ ”ថ្លៃសំចត” បើចតឡានលើសពី១ម៉ោង។

ខេវិន ម័រហ្វី បានកត់ត្រានូវគ្រប់សំណូមពរ ដែលទាក់ទងទៅនឹងកង្វល់ប្រជាពលរដ្ឋក្នុងតំបន់ ដើម្បីយកទៅធ្វើការពិចារណា ចំណែកឯអភិបាល ក្រុងថ្មី អេដវ៉ឺឌ ខណ្ណឌី បានមកសម្តែងនូវជំហ៊រ គាំទ្រដល់សហគមន៍ខ្មែរជាមួយនឹងក្រុមប្រឹក្សាថ្មី ក្នុងនោះក៏មាន អេលីយ៉ុត វ៉តនីយ អតីតអភិបាល ក្រុងឡូវែលដែលធ្លាប់តែផ្តល់ភាពកក់ក្តៅនឹង ភាតរភាពដល់សហគមន៍ខ្មែរ។

កិច្ចប្រជុំបានត្រូវបញ្ចប់នៅម៉ោង១១កន្លះ ក្នុងបរិយាកាសមិត្តភាពដែលម្នាក់ៗនឹកសង្ឃឹម មុននឹងបែកគ្នា ថាជាបរិយាកាសវិជ្ជមានសម្រាប់ ពាណិជ្ជករទាំងអស់នៅ”ខពលស្កែរ” ក៏ដូចជានៅ ទំបន់ឯទៀតៗ គួរតែធ្វើបន្តរទៅទៀតដែរ ៕


Mayor Edward Kennedy


Kelvin Coughlin


Adam Pril and Chet Khim



---

តមកពីទំព័រទី ០៥

## លោកប៊ុនរឹទ្ធឡាច ស្លាបនិកក្រុងឡូវែល...

នឹងអ្នកស្រី ម៉ាលី ខំប្រឹងទប់ខាងហាង ២ជាន់កុំឱ្យរលំក៏តម្រូវឱ្យរបូតហាងខាងម្ខាងទៀត ផ្នែកខាង”កូឡានក្រហម”ពីដៃទៅ ។ តែទោះជា នៅដៃអ្នកដ៏ទៃ ក៏”ប៉ៃលិនប្លហ្សា”ចេញដំណើរ ទៅហើយដែរ។

ស្របគ្នាជាមួយនឹងដំណើរការហាងលក់ទំនិញ លោក ប៊ុន រឹទ្ធ បានទៅជួយសមាគមខ្មែរបាន១៧ ឆ្នាំទៀត ក្នុងឋានៈជាលេខាក៏ដូចជាហិរញ្ញិកពេល ខ្លះជាប្រធានសមាគមផង រហូតដល់មានប្រជាប្រិយ ភាពខ្លាំង ”ខនវ៉េយ” បានប្រគល់អាគារដ៏ធំមួយ សម្រាប់ជាទីស្នាក់ការសមាគមខ្មែរ។ នាអំឡុង ពេលលោក ប៊ុនរឹទ្ធ ចូលប្រឡូកកិច្ចការសង្គម នោះ ពិធីបុណ្យចូលឆ្នាំឬក៏បុណ្យអុំទូកក្តីក៏ផ្តើម ក្លាយជាឱកាសដែលខ្មែររាប់ម៉ឺននាក់ មកពីគ្រប់ ទិសទីនៃសហរដ្ឋអាមេរិកមកជួបជុំគ្នានៅឡូវែល នេះ ហើយដំណើររបៀបនេះក៏នៅបន្តរហូតដល់ សព្វថ្ងៃនេះ ។

នៅឆ្នាំមុននេះ លោក ប៊ុនរឹទ្ធ និយាយថា នៅមានសេចក្តីស្តាយដោយឃើញសមាគមខ្មែរ ចេះតែតូចទៅ ហើយលោកចង់ចេញមកជួយ សមាគមម្តងទៀតដែរ ពាក្យផ្តាំផ្ញើរចុងក្រោយ របស់លោកថា ”សហគមន៍យើងចេះតែបែកបាក់ ពីព្រោះយើងនាំគ្នាយកនយោបាយខ្មែរមកធ្វើនៅ ស្រុកនេះ សូមទុកឱ្យគេធ្វើតែស្រុកខ្មែរទៅបាន ហើយ”។


អ្នកទី១ អ្នកស្រី មាលី ថៃ អ្នកទី២ អ្នកស្រី សុបិន្ត ភិន អ្នកទី៣ លោក ឡាច ប៊ុនរឹទ្ធ

រហូតដល់ចុងបញ្ចប់នៃជីវិត លោក ប៊ុនរឹទ្ធ បានអញ្ជើញមកចូលរួមអបអរសាទរពិធី ”ខែរំលឹករវត្តមានជនជាតិអាស៊ីនៅសហរដ្ឋអាមេរិក” រៀបចំដោយខ្មែរផុស.ស.រ.អា.កាលពីខែឧសភា ឆ្នាំ២០១៥ នៅភោជនីយដ្ឋាន”ប៉ៃលិន” ទំនងជា ឱកាសដែលលោកបានជួបជុំមិត្តភ័ក្រ្តខ្មែរនឹង អាមេរិកាំងច្រើនគ្នាជាចុងក្រោយ...ការបាត់បង់រូប លោកធ្វើឱ្យអ្នកក្រុងឡូវែលសោកស្តាយច្រើនគ្នា៕



ផ្សារប៉ៃលិននៃក្រុងខ្មែរសព្វថ្ងៃ



ផ្សារប៉ៃលិនបន្ទាប់ពីឆេះកាលពីឆ្នាំ១៩៩១



# ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

ហេតុផលរបស់អ្នកគាំទ្រនិងអ្នកប្រឆាំងថ្ងៃ៧មករា១៩៧៩

គណបក្សប្រជាជនកម្ពុជាបានពោលថា បានបង្កើតរណសិរ្សប្រឆាំងនឹងខ្មែរក្រហមប៉ុលពតដែលគណបក្សនេះពោលថា មានកងទ័ពស្ម័គ្រចិត្តវៀតណាមជួយផង បានវាយបនប្រល័យពូជសាសន៍ខ្មែរក្រហមប៉ុលពតឲ្យដួលរលំនៅថ្ងៃ៧មករា១៩៧៩។ ថ្ងៃនេះជាថ្ងៃរំដោះពលរដ្ឋខ្មែរឲ្យផុតពីស្លាប់ ជាកំណើតទី២នៃពលរដ្ឋខ្មែរ។ ការមានសន្តិភាពនិងចំរើនលូតលាស់សព្វថ្ងៃនេះ ដោយសារគុណជ័យជំនះថ្ងៃ៧មករា១៩៧៩នេះ។

គណបក្សនិងពលរដ្ឋខ្មែរដែលប្រឆាំងពោលថា ថ្ងៃ៧មករា១៩៧៩ជាថ្ងៃវៀតណាមចូលឈ្លានពានប្រទេសកម្ពុជាខុសច្បាប់ជាតិ អន្តរជាតិ។ វៀតណាមផ្តួលរំលំខ្មែរក្រហមព្រោះខ្មែរក្រហមមិនស្តាប់បង្គាប់ខ្លួនយកខ្លួនជាសត្រូវ ហើយត្រូវតែតែងតាំងរដ្ឋាភិបាលថ្មីដែលស្តាប់បង្គាប់ខ្លួនឲ្យស្របតាមផែនការសហព័ន្ធកុម្មុយនិស្តឥណ្ឌូចិនដែលមានលាវនិងខ្មែរនៅក្រោមអំណាចខ្លួន។ បន្ទាប់ពីកាន់កាប់ប្រទេសកម្ពុជា វៀតណាមឲ្យខ្មែរកាន់របបកុម្មុយនិស្តដូចប្រទេសខ្លួន សូម្បីព្រះសង្ឃឲ្យបួសពីអាយុ៥០ឆ្នាំឡើងទៅ។ បានចាប់ដាក់គុកនិងសម្លាប់ខ្មែរស្នេហាជាតិអស់ជាច្រើននាក់ ដែលប្រឆាំងនឹងខ្លួនធ្វើអាណានិគមលើប្រទេសកម្ពុជា បានសម្លាប់ពលរដ្ឋខ្មែររាប់សែននាក់ក្នុងកំណែនផែនការក៥។ល។

ដូចរៀបរាប់មកនេះ សន្និដ្ឋានថា ការគាំទ្រនិងការប្រឆាំងថ្ងៃ៧មករា១៩៧៩នេះ ពុំមែនជាបញ្ហារវាងខ្មែរនិងខ្មែរឡើយ គឺកើតឡើងពីមហិច្ឆិតារបស់វៀតណាមមកលើប្រទេសកម្ពុជា។ ចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម ខ្មែរគ្រប់គណបក្សនិងពលរដ្ឋខ្មែរទូទៅតែងតែថ្កោលទោសយ៉ាងខ្លាំងក្លា។ មានអ្នកខ្លះថា ការកាប់សម្លាប់នោះមានវៀតណាមនៅពីក្រោយ។ ការផ្តួលរំលំខ្មែរក្រហម ទោះវៀតណាមបំណងយ៉ាងណាក៏ដោយ ក៏ខ្មែរបានរួចពីការកាប់សម្លាប់ជាប្រព័ន្ធដែរ។ បើផ្តួលរំលំខ្មែរក្រហមហើយ វៀតណាមត្រឡប់ទៅស្រុកវិញ ទុកឲ្យសហប្រជាជាតិដោះស្រាយបន្ត នោះពុំមានបញ្ហារហូតជាង១០ឆ្នាំទៀតទេ។ មួយទៀត បើបក្សប្រជាជនដកខ្លួនពីវៀតណាមហើយចូលមករួបរួមជាមួយចលនាតស៊ូវិញ ខ្មែរដោះស្រាយបញ្ហាខ្លួនមិនពឹងបរទេស។ខ្មែរក្រហមមិនអាចសម្លាប់ដូចមុនឡើយ ព្រោះមានចលនាតស៊ូនៅរួមជាមួយ ហើយមានសហប្រជាជាតិជួយដោះស្រាយផង។ ពេលនេះ ត្រូវពិនិត្យឥទ្ធិពលវៀតណាម ត្រូវលុបចោលសន្ធិសញ្ញាខុសច្បាប់៕

វត្តខ្មែរកាណាដា,ថ្ងៃ៧មករា២០១៦;www.hoksavann;savannhok@yahoo.com


MARCOTTE LAW FIRM

ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- ច្បាប់ធានារ៉ាប់រង
- សំណងបុគ្គល
- ការរំលោភបទព្រហ្មទណ្ឌ
- ពិការភាពដោយសន្តិសុខសង្គម
- គ្រោះថ្នាក់ចរាចរណ៍
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- គ្រោះថ្នាក់នៅការដ្ឋាន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បំណុលអចលទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ
មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ

(978) 458-1229

www.marcottelawfirm.com


## តមកពីទំព័រទី ១៤ ទស្សនសារព័ត៌មានពីថ្ងៃទី ២៨ វិច្ឆិកា...

### ២-គណបក្សថ្មី

-ថ្ងៃទី២៤ធ្នូ ពេជ ស្រស់ អតីតអ្នកធ្វើការនៅរោងចក្រដេរកាត់ខោអាវបានបង្កើត "គណបក្សយុវជនកម្ពុជា CYP" ដើម្បីបំរើបុព្វហេតុយុវជន។ គាត់បានបញ្ចេញនូវកម្មវិធីគួរឱ្យចាប់អារម្មណ៍ដែលឆ្លើយតបនឹងសេចក្តីត្រូវការពិតប្រាកដរបស់យុវជនៈ ការងារ ប្រាក់ជំនួយពេលគ្មានការធ្វើតម្លៃខ្ពស់សម្រាប់ផលិតផលកសិកម្មប្រាក់កម្ចីគ្មានការប្រាក់"ខ.ដ.ទី១២.១២.១៥"។

ថ្ងៃទី២៨ធ្នូ យ៉ង សាំង កុមារ អ្នកបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មខ្មែរ CEDAC បានប្រកាសបង្កើត"គណបក្សប្រជាធិបតេយ្យនៅទាបនឹងដី GDP" គាត់និយាយថា "កាលនៅសេដាក់ ខ្ញុំជួយបានមនុស្សចំនួនតិចតួចបោះនៅសភាជាតិខ្ញុំអាចជួយបានច្រើនជាង""ខ.ដ.ទី២៩.១២.១៥"។

### ៣-គណកម្មការជាតិរៀបចំការបោះឆ្នោតគ.ជ.ប.

-ថ្ងៃទី២៦ធ្នូ គ.ជ.ប.បានផ្តើមទទួលបេក្ខភាពក្នុងតំណែងអគ្គលេខាធិការ នឹងអគ្គលេខារង៤រូប។ ១២៤គំរូដែលត្រូវបំពេញក្នុងរយៈពេល១០ថ្ងៃ សម្រាប់ដណ្តើមដំណែងដែលបេក្ខភាពជាច្រើនមកពីអង្គការក្រៅរដ្ឋាភិបាល។ បេក្ខជន៣រូបបានត្រូវជាជម្រើសរបស់តំណែងអគ្គលេខាធិការ នៅក្នុងនោះមានឈ្មោះ ទេព នីថា ជាអតីតអគ្គលេខាធិការគ.ជ.ប. នឹង១២រូបជាជម្រើសរបស់តំណែងលេខាធិការ។ ជម្រើសចុងក្រោយនឹងធ្វើនៅថ្ងៃទី១៥មករា"ខ.ដ.ទី០៧.០១.១៦"

-ថ្ងៃទី២៨ធ្នូ លោកនាយករដ្ឋមន្ត្រីស្នើមិនឱ្យមានអ្នកដែលមានសញ្ជាតិ២ ជាអ្នកទទួលខុសត្រូវនយោបាយ ឬជាប្រធានព្រឹទ្ធសភាប្រធានសភាជាតិ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញតុលាការកំពូលនឹងគណកម្មការប្រឆាំងពុលរលួយ ។ គម្រោងនេះសំដៅទៅ សម រង្ស៊ី មានសញ្ជាតិបារាំង នៅប្រទេសបារាំងនៅពេលមានគម្រាមគ្រោះថ្នាក់នៅកម្ពុជា។ ដោយសារគម្រោងនេះ លោកនាយករដ្ឋមន្ត្រីបានទប់ស្កាត់លោកស្រី ខេក មិនឱ្យទៅកាន់តំណែងនៅគ.ជ.ប.បាន។ ថ្ងៃទី៧មករា លោកបានប្តូរចិត្តដកគម្រោងច្បាប់នេះចេញវិញ"ខ.ដ.ទី០៨.០១.១៦"៕

### ១-នយោបាយក្រៅប្រទេស

ការធ្វើដំណើររបស់មនុស្សនឹងសម្ភារៈដោយសេរីនៅក្នុងរង្វង់ប្រទេស "អាស៊ាន" បានបាច់ផ្តើមឡើងកាលពីថ្ងៃទី៣១ធ្នូ។ ក៏ប៉ុន្តែគេត្រូវរង់ចាំជាន១០ឆ្នាំទៅមុខទៀត ទម្រាំប្រទេសមិនទាន់អភិវឌ្ឍន៍"កម្ពុជា-ឡាវ-វៀតណាម-ភូមា"អាចតម្លើងកំពស់ស្មើនឹងប្រទេសដ៏ទៃ ហើយតម្លៃពន្ធអាករធ្លាក់ចុះ "ខ.ដ.ទី៣១.១២.១៥"។ កិច្ចចរចាជាមួយប្រទេសជិតខាងទាំង២ នឹងធ្វើក្នុងរង្វង់នេះ។

-ថ្ងៃទី១៨ធ្នូ នាយករដ្ឋមន្ត្រី ហ៊ុន សែន នឹងនាយករដ្ឋមន្ត្រីថៃបានចុះហត្ថលេខាព្រមព្រៀងគ្នាចំនួន៩ស្តីអំពីអ្នកធ្វើការខ្មែរ -បញ្ហាព្រំប្រទល់ដែន នឹងសហប្រតិបត្តិការសេដ្ឋកិច្ចរវាងប្រទេសទាំង២។ ប្រទេសទាំង២សម្រេចតម្លើងពាណិជ្ជកម្មទ្វេភាគីទៅដល់១៥កោដិពីឥឡូវរហូតដល់ឆ្នាំ២០២០ គឺជាកាកើនចំនួន២០០ភាគរយ បើប្រៀបធៀបទៅឆ្នាំ២០១៥ "៥កោដិខាងខ្មែរបញ្ចេញទំនិញ៩៧១លាន"។ ផ្លូវរថភ្លើងភ្នំពេញ-បាងកក ដែលបានផ្អាកតាំងពីឆ្នាំ១៩៧០នឹងផ្តើមដំណើរការនៅឆ្នាំ២០១៦ ធ្វើដោយភាគីថៃ។ មានគម្រោងនឹងបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅតាមបណ្តោយព្រំដែនរួមនឹងមានការអនុញ្ញាតិឱ្យមនុស្សនឹងសម្ភារៈធ្វើដំណើរដោយសេរីនៅតាមតំបន់ព្រំដែននោះ។ ប្រទេសថៃធានាការអប់រំវិជ្ជាជីវៈនៃអន្តោប្រវេសន៍ខ្មែរ - បង្កើត "មន្ទីរពេទ្យបងប្អូន"នៅតាមទល់ដែន -ធ្វើការឃោសនាទេសចរ"ប្រទេស២ទិសដៅតែ១"។នៅ ឱកាសខួបទី៦៥ **តទៅលេខក្រោយ**


Ask me about our Conventional, FHA, Jumbo, VA, and USDA mortgages

HOME LOAN INVESTMENT BANK®

Kosal Suon
Mortgage Originator
NMLS # 1428419
188 Broadway #6
Methuen, MA 01844
Cell: 978-935-6884
Email: ksuon@homeloanbank.com



www.homeloanbank.com Member FDIC *subject to credit approval

- First-time homeowners can purchase a new home with only 3.5% down*
- Conventional, VA, FHA, USDA & Jumbo loans
- Refinance your existing mortgage
- Debt Consolidation
- Free Loan Consultations
- Home Improvement Loans

Fluent in Khmer and English. Call today!

LOWELL ELDER CARE
978-596-1111

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

**345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com**

## អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

## ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





## មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម ( ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ )
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន ( និងការសំណេះសំណាលគ្នា )
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

## Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**

# យើងខ្ញុំយកចិត្តទុកដាក់ដើម្បីឲ្យលោកអ្នកញញឹម។

## *លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់!*





### លោកអ្នកទទួលបានអត្ថប្រយោជន៍ទាំងអស់របស់លោកអ្នកនៅក្នុងកម្មវិធីស្តង់ដារ MassHealth និងកម្មវិធី Medicare រួមទាំងសេវាកម្មជាច្រើនទៀត។

- លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់ ដែលរួមមាន៖ *
  - **ពិគ្រោះយោបល់នៅការិយាល័យ និងសម្អាតធ្មេញ**
  - **ដាក់ក្រាសធ្មេញទាំងមូលនិងដោយផ្នែក**
  - **ប៉ះធ្មេញ**
  - **ដាំធ្មេញ**
- ចំណាយបដិភាគ $0 សម្រាប់គ្រប់សេវាកម្ម
- ប័ណ្ណ លោកអ្នកមានសុខភាពល្អ សម្រាប់ទិញទំនិញពាក់ព័ន្ធនឹងសុខភាពដែលមិនមានវេជ្ជបញ្ជា ( រហូតដល់ $140ក្នុងមួយឆ្នាំ / $35 ក្នុងមួយត្រីមាស ) *
- សេវាកម្មដឹកសមាជិកទៅកាន់និងមកពីកន្លែងណាត់ជួប *
- អាចហៅទូរស័ព្ទទៅកាន់សមាជិកក្រុមការងារនៃគម្រោង SWH បាន 24/7

SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅ:
**1-888-566-3526**( ខ្សែទូរស័ព្ទឥតគិតថ្លៃ ) **TTY/TDD:711**
**www.seniorwholehealth.com/SNP**
យើងខ្ញុំបើកដំណើរការចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ ប្រាំពីរ ( 7 ) ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើលោកអ្នកមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធីស្តង់ដារ MassHealth ក៏ប៉ុន្តែមិនមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធី Medicare ផ្នែក A និង/ឬក៏ផ្នែក B លោកអ្នកប្រហែលជា អាចចុះឈ្មោះនៅក្នុងកម្មវិធីជម្រើសថែទាំសុខភាពមនុស្សចាស់ MassHealth Senior Care Options (SCO) របស់យើងខ្ញុំបាន។
លោកអ្នកដែលឆ្លើយតបទៅនឹងលក្ខខណ្ឌខាងលើអាចចុះឈ្មោះបានគ្រប់ពេលវេលារៀងរាល់ឆ្នាំ។

* *លក្ខខណ្ឌកំណត់អាចត្រូវបានអនុវត្ត*

គម្រោងសុខភាពទាំងមូលរបស់មនុស្សចាស់ គឺជាគម្រោងថែទាំសុខភាព HMO SNP ដែលមានការសម្របសម្រួល និងកិច្ចសន្យាផ្តល់- ទទួលសេវាកម្មនៃកម្មវិធី Medicare និងកិច្ចសន្យាជាមួយ Commonwealth of Massachusetts/កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះធ្វើឡើងដោយស្ម័គ្រចិត្ត និងអាស្រ័យទៅលើការបន្តកិច្ចសន្យាប្រចាំឆ្នាំ។ ព័ត៌មានអំពីអត្ថប្រយោជន៍នៅក្នុងឯកសារនេះ គឺជាសេចក្តីសង្ខេបមួយ មិនមែនជាសេចក្តីពិពណ៌នាលម្អិតអំពីអត្ថប្រយោជន៍ទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យគម្រោង។ លក្ខខណ្ឌកំណត់ ប្រាក់បដិភាគ ឬក៏លក្ខខណ្ឌកម្រិតផ្សេងៗទៀតអាចត្រូវបានអនុវត្ត។អត្ថប្រយោជន៍ រូបមន្ត បណ្តាញអ្នកផ្តល់សេវាកម្ម និងបណ្តាញឱសថស្ថាន អាចត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករា នៃឆ្នាំនីមួយៗ។ លោកអ្នកត្រូវតែបន្តបង់បុព្វលាភផ្នែក B របស់លោកអ្នក ប្រសិនបើបុព្វលាភនោះមិនកំពុងត្រូវបានបង់ដោយភាគីណាមួយផ្សេងទៀតនៅឡើយទេ។ គម្រោងនេះត្រូវបានបង្កើតឡើងសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានជំនួយវេជ្ជសាស្ត្រដែលទទួលបានទាំងពីរដ្ឋ និងកម្មវិធី Medicare។
H2224_2015_104kh Accepted 12/7/2014

# កម្មវិធីសិក្សានៅវត្តពន្លឺពុទ្ធចក្រ

**ខ្មែរផុសស.រ.អា.**

**ឡូវែល:** ថ្ងៃអាទិត្យទី១៦ មករា ២០១៦ ម៉ោង១រសៀលធាតុអាកាសត្រជាក់ខ្លាំងក្រោមសូន្យតែកុមារខ្មែរប្រមាណ៥០-៦០នាក់អាយុពី៧-១៥ឆ្នាំ បានទៅសិក្សាអក្សរខ្មែរកកកុញនៅថ្នាក់ពាក់រឹតដំបូង នាសាលារៀបចំបន្ទាន់សម្រាប់កុមារទាំងស្រីប្រុសដែលរីករាយនឹងចង់មកជួបជុំគ្នាសិក្សានៅក្នុងវិហារធំ ដែលមានថ្នាក់សិក្សា៣នឹងថ្នាក់សិក្សាវិជ្ជាកុំព្យូទ័រមួយទៀត ធ្វើនៅក្នុងកុដិដែលគេហៅថាសាលាតូច។ គ្រូបង្រៀនបួននាក់ បានផ្តើមកម្មវិធីថ្នាក់សិក្សារនេះតាំងពី៣-៤ឆ្នាំមកហើយ ទទួលសិស្សយ៉ាងស្ទិទិស្នាលនឹងព្យាយាម។

ស្របពេលកំពុងបង្រៀនសិស្សក្មេងៗយាយតាចាស់ទុំក៏មកកាន់ទីវត្តកាន់តែច្រើនទំនងជាមានរៀបចំបុណ្យអ្វីមួយ តែរសៀលនេះមិនដូច្នោះទេ ពួកគាត់មានចំនួន៤០-៥០នាក់ ភាគច្រើនស្លៀសពាក់សំពត់ស ពួកគាត់និយាយថាមកចូលសិក្សាកម្មវិធីសមាធិដែលចាប់ផ្តើមនៅថ្ងៃនេះ ដឹកនាំដោយព្រះតេជគុណ ម៉ន នឿន។ ចាស់ទុំខ្មែរមកច្រើនយ៉ាងនេះ គឺប្រាកដជាផលចំណេញសម្រាប់សហគមន៍ ពីព្រោះ"ការចម្រើនសមាធិ" គឺជាឫសគល់គ្រឹស្តនៃព្រះពុទ្ធសាសនាសម្រាប់រម្ងាប់ចាប់តាំងពីកង្វល់កំហឹងជ្រួលច្របល់ចិត្តហឹង្សារបស់បុគ្គល ដើម្បីចាប់យកនូវសេចក្តីស្ងប់យកការគិតត្រូវសេចក្តីស្រឡាញ់សេចក្តីគោរពដល់ខ្លួនឯងនឹងអ្នកដ៏ទៃ គឺជាគុណសម្បត្តិដែលសហគមន៍ខ្មែរត្រូវការជាទីបំផុត ចាប់តាំងពីបានស្គាល់សុខសន្តិភាពនៃសង្គមជឿនលឿននៅសហរដ្ឋអាមេរិកនេះមក។


ព្រះតេជគុណ ម៉ន នឿន

លោកគ្រូ ជា គិមសាន្ត បង្រៀនថ្នាក់អក្សរខ្មែរយូរឆ្នាំជាងគេនៅសាលាតូចខាងមុខវិហារនិយាយថា "សិស្សត្រូវការរៀនអក្សរខ្មែរកាន់តែច្រើន យើងកាន់តែមានការលំបាកក្នុងរៀបចំ ពីព្រោះសិស្សចាស់រៀនបានច្រើន តែពេលអ្នកថ្មីមកដល់ផ្តើមក៏រឹតមិនស្មើរគ្នា"។ លោកគ្រូម្នាក់ទៀត ឈ្មោះ វិឆាយ សុខ ជាអ្នកបង្រៀនផង នឹងជាអ្នករៀបចំផង និយាយថា "ថ្នាក់៤ធ្វើឱ្យមានការធ្វើច្រើនមិនមានពេលជួយរៀបចំសាលាទេ ជាពិសេសបើមានគ្រូម្នាក់ឈប់យើងក៏មានបញ្ហាគ្រូអ្នកជំនួសភ្លាម"។ អ្នកគ្រូ ស៊ី បូរ៉ាន បង្រៀនថ្នាក់ខាងមុខផ្លូវចូលដែលចំនួនសិស្សឡើងជិត២០នាក់ហើយស្នើរគ្រូឯទៀតឱ្យទទួលយកសិស្សគាត់ថា "សុំជួយដាក់សិស្សឱ្យខ្ញុំតែ១២នាក់បានហើយ សិស្សច្រើនក៏រឹតចំណេះខុសគ្នាពិបាកគ្រប់គ្រងណាស់។ គ្រូខាងផ្នែកកុំព្យូទ័របង្រៀនដោយ ស ផែល នៅខាងកុដិតូចមិនមានជាបញ្ហាអ្វីទេ ដោយសិស្សមានចំនួនតិចជាង១០នាក់ ។

បើកកម្មវិធីថ្នាក់រៀននៅវត្តពន្លឺពុទ្ធិចក្រ គឺបានបង្ហាញនូវសេចក្តីសង្ឃឹមថា នឹងទទួលផលខ្ពស់ដោយភាពរីករាយរួមសម្បាច់គ្នាភាពលះបង់នឹងបំណងប្រាថ្នាបរិសុទ្ធនៃអ្នកចូលរួមតែត្រូវការគ្រប់គ្រងក៏រឹតខ្ពស់ជាងនេះ ដើម្បីគោលដៅសិក្សាអក្សរនឹងវប្បធម៌ខ្មែរឱ្យបានគង់វង្សវែងឆ្ងាយទៅអនាគតបាន។


លោកគ្រូ ជា កំសាន្ត




លោកគ្រូ ស ផែល


លោកគ្រូ វិឆាយ សុខ


អ្នកគ្រូ ស៊ី បុរាណ

ព្រះសង្ឃនឹងគ្រហស្ថនៅទីនោះ មានការរួមច្របាច់គ្នាចេះធ្វើឱ្យសហគមន៍ទាំងមូលមានការពេញចិត្តដោយសារចរិកខ្មែរដែលគេតែងពោលថា"ចូលចិត្តបែកបាក់គ្នា" ពុំបាននៅទីនោះទេ។ បន្ថែមពីនោះ វប្បធម៌នៃការសិក្សាតែងស្ថិតជាប់នៅវត្តអារាមក៏បានកកើតនៅទីនោះទៀត គួរឱ្យកោតសសើរ៕

# ឡូវែល Lowell នឹងវស់ស្ទើរ Wocester សុំនូវការបន្ធូរបន្ថយ

**រៀបរាងដោយ តារាយុទ្ធ ហង្ស**

ក្រុមមេធាវីដែលបានដាក់ពាក្យបណ្តឹងក្នុង "ការដាក់កំហិតមិនឱ្យមានអ្នកសុំទាននៅក្នុងទីក្រុងឡូវែល នឹង វស់ស្ទើរ" កំពុងសុំការបន្ធូរបន្ថយក្នុងការបង់ប្រាក់សងជម្ងឺចិត្ត ។ សហជីពសេរីភាពស៊ីវិលអាមេរិកាំងនៃរដ្ឋម៉ាសាឈូសិតនឹងក្រុមហ៊ុនច្បាប់បូស្តុន Goodwin Procter LLP បានស្នើរឱ្យចៅក្រមសហព័ន្ធផាកពិន័យទីក្រុងវស់ស្ទើរក្នុងទឹកប្រាក់ចំនួន ១ ០២៦ ២២៣ ដុល្លារ ពីព្រោះតែមានរឿងក្តីមួយដែលទាក់ទងទៅនឹងច្បាប់បំរាមមិនឱ្យមានអ្នកសុំទានដែរ ត្រូវច្រានចោលដោយចៅក្រមសហព័ន្ធ កាលពីឆ្នាំ២០១៣។ ចំណែកឯទីក្រុងឡូវែលសហជីពសេរីភាពស៊ីវិលអាមេរិកាំងនៃរដ្ឋម៉ាសាឈូសេតនឹងក្រុមហ៊ុនច្បាប់បូស្តុន Goodwin Procter LLP បានស្នើរឱ្យទីក្រុងនេះបង់ទឹកប្រាក់ពិន័យចំនួន៧៣៦៤៦៦ដុល្លារ បន្ទាប់ពីចៅក្រមសហព័ន្ធលុបចោល ច្បាប់បំរាមមិនឱ្យមានអ្នកសុំទាន កាលពីខែតុលាមុន ។ ប៉ុន្តែមេធាវីតំណាងទីក្រុងទាំងពីរមិនយល់ស្របនូវសំណើរនោះទេ ដោយថា ការផាកពិន័យបែបនេះ គឺមិនសមស្រប ពីព្រោះក្តីនេះគឺមិនធ្លាប់ត្រូវបានគេបញ្ជូនឡើងសោវនការ។ មេធាវីតំណាងទីក្រុងវស់ស្ទើរ លោកដេវីដ អេមមរ (David M.Moore) បានមានប្រសាសន៍ថា "ចំនួននៃការផាកពិន័យ គឺច្រើនជាងពីរដងនៃទឹកប្រាក់បំណាច់ឆ្នាំរបស់គាត់ដែលចំណាយលើភស្តុតាងនឹងរឿងក្តីនៅតុលាការ។ ហើយគាត់ក៏បានបន្ថែមទៀតថា "ពួកយើងនឹងដាក់ពាក្យបណ្តឹងប្រឆាំងនូវសំណើរនោះវិញនៅឯតុលាការ។ ប៉ុន្តែផ្ទុយទៅវិញមេធាវីតំណាងឱ្យសហជីពសេរីភាពស៊ីវិលអាមេរិកាំងនៃរដ្ឋម៉ាសាឈូសេតនឹងក្រុមហ៊ុនច្បាប់បូស្តុន Goodwin Procter LLP សង្ឃឹមថា នឹងមានការពិភាក្សាដោយសន្តិវិធីមួយដែលអាចជំរុញឱ្យទីក្រុងទាំងនោះដកពាក្យបណ្តឹងបែបនោះ ពីព្រោះថាបណ្តឹងបែបនេះមិនត្រូវបានគេចែងនៅក្នុងរដ្ឋធម្មនុញ្ញទេ៕








# ពិធីផ្សេងៗក្នុងបុណ្យចូលឆ្នាំថ្មីប្រពៃណីចិន

**ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីចិនក្នុងឆ្នាំ២០១៦ ប្រព្រឹត្តទៅនៅថ្ងៃទី០៧ ដល់ថ្ងៃទី១០ ខែកុម្ភៈ។ ប្រជាពលរដ្ឋមានសែស្រឡាយជាជនជាតិចិនបានរៀបចំពិធីផ្សេងៗដើម្បីទទួលឆ្នាំថ្មីរបស់ខ្លួន ។ ពិធីបុណ្យចូលឆ្នាំចិនគឺជាពិធីបុណ្យដែលមានជាយូរមកហើយ និងសំខាន់បំផុតនៅក្នុងប្រទេសចិន ។ ទាក់ទងទៅនឹងសាច់រឿងនៃពិធីផ្សេងៗទាំង១៥ថ្ងៃនោះគឺចាប់ផ្តើមពីថ្ងៃទីមួយក្នុងប្រតិទិនតាមចន្ទគតិ និងរួមមានទាំងទម្លាប់ និងប្រពៃណីជាច្រើនសតវត្សរ៍មកហើយ ។ ថ្ងៃនីមួយៗមានពិធីពិសេសផ្សេងៗពីគ្នាដែលប្រជាជនចិនភាគច្រើននាំគ្នាធ្វើ ។**



●ពិធីបុណ្យចូលឆ្នាំចិន ឬពិធីចូលឆ្នាំថ្មីតាមចន្ទគតិដែលនឹងចាប់ផ្តើមនៅថ្ងៃទី៧ ខែកុម្ភៈនេះ ។ ពិធីបុណ្យចូលឆ្នាំខ្មែរជាថ្ងៃឈប់សម្រាកដ៏សំខាន់ និងមានអត្ថន័យបំផុតក្នុងប្រទេសកម្ពុជា ។ ចំណែកឯពិធីបុណ្យចូលឆ្នាំចិន គឺជាពិធីមួយដែលប្រជាជនចិនក្នុងព្រះរាជាណាចក្រកម្ពុជាប្រារព្ធអបអរសាទរក៏ដូចជាប្រជាជននៃបណ្តាប្រទេសជិតខាងផងដែរ ។ ការអបអរសាទរមានរយៈពេល១៥ថ្ងៃ គឺចាប់ផ្តើមនៅថ្ងៃទី១ តាមប្រតិទិនបុរាណចិន ។ សម្រាប់ជនជាតិចិនពិធីនេះគឺជាពេលវេលាដែលពួកគេជួបជុំគ្រួសារ និងមិត្តភ័ក្តិបរិភោគអាហារជុំគ្នា និងជូនពរគ្នាទៅវិញទៅមកដើម្បីនាំមកនូវភាពថ្កុំថ្កើងសម្រាប់ឆ្នាំខាងមុខ ។ ការអបអរជាការបញ្ចប់ឆ្នាំចាស់ស្វាគមន៍ឆ្នាំថ្មី ហើយវាជាពេលវេលាសម្រាប់គ្រួសារមិត្តភ័ក្តិ និងប្រពៃណី ។ វប្បធម៌នៃប្រទេសជាច្រើនដែលទទួលឥទ្ធិពលពីចិនក៏បានអបអរឆ្នាំថ្មីក្នុងនោះមានជនជាតិម៉ុងហ្គោលី និងទីបេ ដែលមានប្រពៃណីប្រហាក់ប្រហែលគ្នាក៏ដូចជាប្រទេសទាំងឡាយដែលមានជនជាតិចិនរស់នៅផងដែរ ។ បើទោះបីមិនមែនជាថ្ងៃឈប់ជាផ្លូវការក៏ដោយ ក៏ប៉ុន្តែពិធីចូលឆ្នាំចិនក៏ត្រូវបានអបអរសាទរដោយជនជាតិចិនដែលបានរស់នៅក្នុងប្រទេសជាច្រើនដូចជាប្រទេសអូស្ត្រាលីសហរដ្ឋអាមេរិក និងកាណាដា ។ ឥទ្ធិពលវប្បធម៌ចិនមាននៅទូទាំងពិភពលោក ហើយការអបអរឆ្នាំថ្មីមានអាយុរាប់សតវត្សរ៍មកហើយ ហើយឥឡូវនេះការអបអរនេះបានក្លាយជាផ្នែកមួយយ៉ាងសំខាន់នៃវប្បធម៌របស់ជនជាតិចិនដែលកំពុងរស់នៅក្នុងតំបន់ប្រជុំជនជាតិចិនក្រៅប្រទេសជុំវិញសកលលោក ។ សម្លៀកបំពាក់ពណ៌ឆើតការដើរជាក្បួនសម្តែង កាំជ្រួច របាំលោត ម៉ុងសាយ និងរបាំនាគដើងមួយរយដែលធ្វើពីសរសៃសូត្រឬស្សី និងក្រដាសឃើញមានរៀបចំឡើងនៅតាមទីក្រុងធំៗទូទាំងពិភពលោក ។ នៅក្នុងស្រុកខ្មែរការអបអរពិធីចូលឆ្នាំចិនបានប្រារព្ធធ្វើឡើងដោយប្រជាជនទាំងជនជាតិចិនទាំងជនជាតិខ្មែរផងដែរ ។ ប្រជាជនកម្ពុជាចូលចិត្តចូលរួមអបអរសាទរ ចម្អិនម្ហូបអាហារជួបជុំគ្រួសារនៅផ្ទះ ឬផ្ទះញាតិចូលចិត្តទិញសម្លៀកបំពាក់ នំចំណី និងតុបតែងផ្ទះ និងការិយាល័យចំពោះអ្នកទាំងឡាយដែលមានដើមកំណើតចិន ។

ការអបអរពិធីចូលឆ្នាំចិននៅទូទាំងតំបន់មានលក្ខណៈដូចគ្នាជា ច្រើនដែលបន្សល់ទុកពីប្រពៃណីចិនគឺ :

**●មានផាវ និងពណ៌ក្រហម**

ពណ៌ក្រហមមានន័យថា ជីវិតប្រកបដោយថាមពល និងទ្រព្យ ហើយជាពណ៌សំខាន់ក្នុងរឿងព្រេងចិន ។ ចំណែកឯប្រជាជនត្រូវបានលើកទឹកចិត្តឱ្យដុតផាវ និងពាក់ពណ៌ក្រហមដើម្បីការពារការវាយប្រហារពីសត្វស៊ីសាច់មនុស្ស ។

**●របាំលោតម៉ុងសាយ**

ក្នុងសប្តាហ៍ទី១នៃពិធីចូលឆ្នាំចិន អ្នកអាចទស្សនាការសម្តែងរបាំលោតម៉ុងសាយដែលមានសម្លៀកបំពាក់ជាសត្វតោ និងមានស្គរនៅតាមដងវិថី និងហាងទំនិញ ។

**●ការជួបជុំគ្រួសារ**

ផ្លូវហាយវេជាប់ស្ទះដោយសារជនជាតិចិនវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនដើម្បីជួបជុំគ្នាបរិភោគអាហារ និងលេងល្បែងកម្សាន្ត ។

**●អាហារ :**

មានម្ហូបអាហារប្រពៃណីជាច្រើនមុខដើម្បីអបអរសាទរពិធីចូលឆ្នាំថ្មី **តទៅទំព័រទី ២៩**



ឌឹ ខេមបូឌា ដេលី The Cambodia Daily
ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# លោក ទេព នីថា នៅតែជាអគ្គលេខាធិការ គ.ជ.ប.ដដែល

**ដោយគុជ ណារ៉េន** | **January 16, 2016**

កាលពីថ្ងៃសុក្រ បន្ទាប់ពីការប្រជុំបិទទ្វាររយៈពេល៣ម៉ោងមក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានតែងតាំងលោក ទេព នីថា ជាថ្មីឱ្យធ្វើជាអគ្គលេខាធិការនៃស្ថាប័នដែលកែទម្រង់ថ្មីនេះ បើទោះជាយ៉ាងហោចណាស់មានសមាជិកម្នាក់ក្នុងចំណោមសមាជិក៩នាក់របស់ខ្លួនមិនយល់ព្រមដោយផ្ទាល់នឹងសេចក្ដីសម្រេចនេះក៏ដោយ។

ការដែលឈ្មោះរបស់លោក ទេព នីថា មានក្នុងបញ្ជីក្នុងចំណោមបេក្ខជនជ្រើសរើសសម្រាប់តំណែងអគ្គលេខាធិការនោះ បានធ្វើឱ្យមានការភ្ញាក់ផ្អើលដល់អ្នកដែលសន្មតជាមុនថា មុខមាត់ថ្មី នឹងកាន់តំណែងដ៏សំខាន់នេះ បន្ទាប់ពីមានកិច្ចព្រមព្រៀងឆ្នាំ២០១៤ដើម្បីកែទម្រង់គណៈកម្មការជាតិរៀបចំការបោះឆ្នោតនេះ។

ថ្លែងទៅកាន់អ្នកយកព័ត៌មាននៅទីស្នាក់ការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅខាងក្នុងក្រសួងមហាផ្ទៃលោក ស៊ិក ប៊ុនហុក ប្រធាន គ.ជ.ប. បានមានប្រសាសន៍ថា សេចក្ដីសម្រេចនេះមានការគាំទ្រភាគច្រើនពីគណៈកម្មាធិការនេះ។ តាមបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រធានបង្ហាញការជ្រើសរើសរបស់ខ្លួនទៅគណៈកម្មាធិការដែលត្រូវយល់ព្រមតាមសំឡេងភាគច្រើន៥០បូក១។

លោក ប៊ុនហុក ដែលបានលាលែងតំណែងជាតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាកាលពីដើមឆ្នាំមុនបាននិយាយថា "ព្រឹកនេះការជ្រើសរើសមិនបានធ្វើដោយការបោះឆ្នោតទេ ប៉ុន្តែ បានធ្វើដោយធ្វើការពិភាក្សាជាមួយសមាជិក៩រូបរបស់ គ.ជ.ប."។

បន្ទាប់ពីចំណាយពេលពេញមួយព្រឹកពិភាក្សាដ៏ហ្មត់ចត់អំពីបេក្ខជនម្នាក់ៗរួចមក គ.ជ.ប.បានយល់ស្របតាមសំណើរបស់ខ្ញុំ"។

គ។ជ។ប។ដែលកែទម្រង់គឺជាមូលដ្ឋាននៃកិច្ចព្រមព្រៀងខែកក្កដា ឆ្នាំ២០១៤ ដែលគេឃើញគណបក្សប្រឆាំងចូលរួមនឹងរដ្ឋាភិបាលបន្ទាប់ពីការធ្វើពហិការមិនចូលសភា១០ខែ ជាការឆ្លើយតបទៅនឹងការបោះឆ្នោតជាតិឆ្នាំ២០១៣ដ៏ចម្រូងចម្រាស។ នៅពេលដែលសមាសភាពដដែលពីមុនរបស់ស្ថាប័ននេះមានចំនួនលើសលប់ដោយអ្នកមានទំនាក់ទំនងជាមួយនឹងគណបក្សប្រជាជនកម្ពុជានោះស្ថាប័នថ្មីនេះមានសមាជិក៤រូបដែលជ្រើសរើសដោយគណបក្សនីមួយៗ ហើយសមាជិកទី៩"អព្យាក្រឹត្យ"។

សមាជិកនៃគណៈកម្មាធិការនេះបានបដិសេធមិនបញ្ចេញឱ្យដឹងថា នរណាក្នុងចំណោមពួកគេបានជំទាស់នឹងការតែងតាំងលោក ទេព នីថា ទេ ប៉ុន្តែយ៉ាងហោចណាស់មានសមាជិកម្នាក់បានប្រឆាំងនឹងការជ្រើសរើសនេះ។

លោក រ៉ុង ឈុន អតីតសមាជិកសហជីព និងជាអ្នកដែលគេតែងតាំងម្នាក់ក្នុងចំណោមអ្នកទទួលការតែងតាំង៤រូបរបស់គណបក្សសង្គ្រោះជាតិ បាននិយាយថា លោកមិនសប្បាយចិត្តនឹងសេចក្ដីសម្រេចនេះទេ។

លោកបាននិយាយថា "និយាយដោយស្មោះត្រង់ ខ្ញុំជាមនុស្សម្នាក់ដែលបានប្រឆាំងនឹងបេក្ខជនសម្រាប់តំណែងជាអគ្គលេខាធិការ"។

"មូលហេតុដែលខ្ញុំប្រឆាំងបេក្ខភាពរបស់គាត់ពីព្រោះខ្ញុំបានកត់សម្គាល់ឃើញថា សាធារណជនមិនគាំទ្រគាត់ទេ"។

លោក រ៉ុង ឈុន បាននិយាយថា លោកជឿថា លោក ទេព នីថា សម្បូរដោយបទពិសោធន៍ និងចំណេះដឹង ប៉ុន្តែខ្ញុំបារម្ភថាកេរ្តិ៍ឈ្មោះរបស់គាត់ជាមនុស្សម្នាក់ដែលបានមើលខុសត្រូវការបោះឆ្នោតឆ្នាំ២០០៣ ឆ្នាំ២០០៨ និងឆ្នាំ២០១៣ដ៏ចម្រូងចម្រាសនោះ អាចធ្វើឱ្យប៉ះពាល់ដល់ការយល់ឃើញជាសាធារណៈលើស្ថាប័នថ្មីនេះ។

គ.ជ.ប.ថ្មីមានភារកិច្ចមើលខុសត្រូវលើការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ និងការបោះ

**តទៅទំព័រទី ១៩**



លោក ស៊ិក ប៊ុនហុក ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្លែង ទៅកាន់អ្នកយកព័ត៌មានក្នុងក្រុងភ្នំពេញកាលពីថ្ងៃសុក្រ។ រូបថត៖ ខឹម សុវណ្ណារ៉ា

# TEP NYTHA REAPPOINTED TO NEC POST

**byKuchNaren | January 16, 2016**

After a three-hour closed-door meeting, the National Election Committee on Friday reappointed TepNytha as secretary-general of the recently revamped body-though at least one of its nine members personally disagreed with the decision.

That Mr. Nytha's name had even been listed among candidates in the open call for a replacement secretary-general surprised many who assumed a fresh face would take the key post in the wake of a 2014 agreement to reform the NEC.

National Election Committee chairman SikBunhok speaks to reporters in Phnom Penh on Friday. (KhemSovannara)

Speaking to reporters at the NEC's headquarters inside the Ministry of Interior, chairman SikBunhok said the decision had majority support from the committee. Under the NEC's governing bylaws, the chairman presents his selection to the committee, which must agree through a 50-plus-one majority.

"This morning, the selection was not made by vote, but it was made by holding discussions with the nine members of the NEC," said Mr. Bunhok, who stepped down as a CPP lawmaker early last year.

"After spending the full morning to conduct thorough discussion on each candidate, the NEC agreed with my request."

A reformed NEC was the cornerstone of the July 2014 agreement that saw the opposition join the government after a 10-month boycott of parliament in response to the contentious 2013 national election.

While the body's previous iteration was dominated by those with ties to the CPP, the new version has four members selected by each party and a ninth "neutral," tie-breaking member.

Members of the committee declined to disclose who among them objected to Mr. Nytha's appointment, but at least one fought the selection.

RongChhun, a former unionist and one of the four CNRP appointees, said he was displeased by the decision.

"Frankly speaking, I am one who opposed the candidate for the position as secretary-general," he said.

"The reason I opposed his candidacy is because I've noticed that the public does not support him."

Mr. Chhun said he believed Mr. Nytha had a wealth of experience and knowledge, but had worried that his reputation as someone who oversaw the controversial 2003, 2008 and 2013 elections could mar public perception of the new body.

The new NEC has been tasked with supervising the 2017 commune elections and the 2018 national election and has already begun carrying out key work, such as testing a voter registration system that uses biometric identification.

Mr. Chun said he had already come to accept his colleagues' decision, and hoped that the committee's proven work and strong rules governing its function would make Mr. Nytha's appointment unimportant in the grand scheme.

But while the new rules require the NEC to come to an agreement on decisions that are only then administered by the secretary-general, the CNRP said placing Mr. Nytha back in his former role undermined the body's work.

**Continued to Page**

ឌី ខេមបូឌា ដេលី The Cambodia Daily

ជំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌី ខេមបូឌា ដេលី

# សម្រាប់របៀបវារៈកំណែទម្រង់គណបក្សប្រជាជនកម្ពុជា យកគន្លឹះពីគណបក្សសង្គ្រោះជាតិ

**ដោយអេឡិក វិល្លឹមមីនស៍និងគុច ណារ៉េន** | **January 12, 2016**

ក្រោយពីការបោះឆ្នោតជាតិនាឆ្នាំ២០១៣រួចមក លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឱ្យសហសេវិករបស់លោកក្នុងជួរគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចឈរមុខកញ្ចក់ដុសក្អែលខ្លួនឯងដែលស្ទើរតែបណ្តោយឱ្យគណបក្សប្រឆាំងរួបរួមគ្នាដែលដឹកនាំដោយលោក សម រង្ស៊ី និងលោក កឹម សុខា ឡើងកាន់អំណាច។

សារដែលថ្លែងរយៈពេល៦ម៉ោងតាមកញ្ចក់ទូរទស្សន៍ គឺថាគណបក្សប្រជាជនកម្ពុជាបានទទួលនូវមេរៀនជូរចត់មួយ ប៉ុន្តែបានរើបឡើងវិញពីស្ថានការណ៍ដ៏អាក្រក់បំផុតកាលពីអតីតកាល ហើយអាចឈ្នះម្តងទៀត ប្រសិនបើខ្លួនបានកែខ្លួន។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីបានពន្យល់ប៉ុន្មានថ្ងៃបន្ទាប់ពីលទ្ធផលគួរឱ្យតក់ស្លុត ដែលធ្វើឱ្យលោក សម រង្ស៊ី ខ្វះតែ៧កៅអីទៀតប៉ុណ្ណោះអាចបណ្តេញលោក ហ៊ុន សែនចេញពីតំណែងបានថា "យើងរំពឹងថា អ្នកបោះឆ្នោតទាំងនោះនឹងវិលត្រឡប់មកវិញនៅក្នុងឆ្នាំ២០១៨"។

លោក ផៃ ស៊ីផាន បានមានប្រសាសន៍ដោយផ្តោតទៅលើសញ្ញាវិជ្ជមាននៃព្រឹត្តិការណ៍នោះថា "យើងរៀនពីប្រជាពលរដ្ឋ។ យើងរៀនពីយុទ្ធនាការនេះ ដើម្បីជំរុញឱ្យមានយុត្តិធម៌សង្គមយ៉ាងឆាប់រហ័ស ដើម្បីផ្តល់យុត្តិធម៌ល្អប្រសើរដល់ប្រជាពលរដ្ឋ"។

រយៈពេលពីរឆ្នាំកន្លះមក និងពាក់កណ្តាលផ្លូវឆ្ពោះទៅការបោះឆ្នោតជាតិនៅឆ្នាំ២០១៨ កម្មវិធីបោះឆ្នោតធ្វើដោយគណបក្សកាន់អំណាចតាមពិតទៅក្លាយជាកំណែទម្រង់ធំៗមួយចំនួន។ ភាគច្រើននៃកម្មវិធីមាននៅក្នុងគំនិតដែលធ្លាប់ស្គាល់មួយចំនួនពីឆ្នាំ២០១៣ ពោលគឺគំនិតដែលផ្តួចផ្តើមដោយគណបក្សសង្គ្រោះជាតិ។

ចាប់តាំងពីការបោះឆ្នោតចុងក្រោយមក រដ្ឋាភិបាលលោក ហ៊ុន សែន បានចាប់ផ្តើមអនុវត្តយ៉ាងហោចណាស់ចំនួនពាក់កណ្តាលនៃកម្មវិធីយុទ្ធនាការគោលនយោបាយប្រាំពីរចំណុចដ៏ប្រជានិយមនិងប្រជាប្រិយរបស់គណបក្សសង្គ្រោះជាតិកាលពីឆ្នាំ២០១៣។

លោក ធន់ សារ៉ាយ ប្រធានអង្គការសិទ្ធិមនុស្សអាដហុក បានមានប្រសាសន៍ថា "គេបានអនុវត្តតាមកម្មវិធីនយោបាយរបស់គណបក្សសង្គ្រោះជាតិកាលពីយុទ្ធនាការបោះឆ្នោតមុនគឺឧទាហរណ៍ដំឡើងប្រាក់ខែមន្ត្រីរាជការ និងប្រាក់ខែកម្មកររោងចក្រ។ វាជាកម្មវិធីរបស់គណបក្សសង្គ្រោះជាតិ។

លោក ធន់ សារ៉ាយ បានមានប្រសាសន៍បន្ថែមថា "កំណែទម្រង់ចម្បង និងសំខាន់សម្រាប់ប្រទេសជាតិដែលមានដូចជា ប្រព័ន្ធតុលាការឯករាជ្យ និងសេវាសាធារណៈគណបក្សប្រជាជនកម្ពុជានៅមិនទាន់បានធ្វើនៅឡើយទេ"។

ក្នុងពេលដែលគណបក្សសង្គ្រោះជាតិកាលពីឆ្នាំ២០១៣បានសន្យាដំឡើងប្រាក់ខែមូលដ្ឋានក្នុងវិស័យកាត់ដេរពី៨០ដុល្លារទៅដល់១៥០ដុល្លារ តាំងពីពេលនោះមក រដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជាក៏បានដំឡើងដល់១៤០ដុល្លារដែរ។

ការសន្យានាឆ្នាំ២០១៣ដាច់ដោយឡែកផ្សេងទៀតពីគណបក្សសង្គ្រោះជាតិដើម្បីដំឡើងប្រាក់ខែមូលដ្ឋានសម្រាប់មន្ត្រីរាជការពី១២០ដុល្លារក្នុងមួយខែដល់២៥០ដុល្លារ គឺស៊ីគ្នានឹងគណបក្សប្រជាជនកម្ពុជាផងដែរ ដោយលោក ហ៊ុន សែន កាលពីខែវិច្ឆិកា បានសន្យាថា ប្រាក់ខែនឹងឡើងដល់២៥០ដុល្លារនៅដើមឆ្នាំ២០១៨ ពោលគឺដល់ពេលបោះឆ្នោតតែម្តង។

ផ្ទុយទៅវិញ រយៈពេលប្រាំបួនខែមុននឹងបោះឆ្នោតលោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថានឹងមិនអាចដំឡើងប្រាក់ខែឱ្យមន្ត្រីរាជការបានទេបើមិនមានការដំឡើងពន្ធខ្ពស់សម្រាប់កសិករ។

**តទៅទំព័រទី ២០**

# FOR REFORM AGENDA, CPP TAKES CUES FROM CNRP

**ByAlex Willemyns and KuchNaren | January 12, 2016**

In the aftermath of the 2013 election, Prime Minister Hun Sen ordered his colleagues in the ruling CPP to stand before a mirror and cleanse themselves of the sins that had almost allowed a united opposition led by Sam Rainsy and Kem Sokha to sweep to power.

The message, delivered in a six-hour speech on state television, was that the CPP had been handed a harsh lesson, but had come back from worse situations in the past and could do so again if it corrected its errant ways.



Prime Minister Hun Sen speaks to reporters at a construction site for an over-pass in Phnom Penh on July 31, 2013, in what was his first public appearance after the national election days earlier. (Siv Channa/The Cambodia Daily)

**- News Analysis**

"We expect for those voters to come back in 2018," explained Council of Ministers spokesman PhaySiphan in the days after the shock result, which put Mr. Rainsy within seven seats of ousting Mr. Hun Sen.

"We learn from the people," Mr. Siphan said, casting a positive spin on the events. "We've learned from this campaign to push very quickly for social justice to provide better justice to the people."

Two and a half years on, and halfway until the 2018 national election, the electoral program pursued by the ruling party has, in fact, instituted a number of major reforms. Many of them have coalesced around a few familiar ideas from 2013-those espoused by the opposition CNRP.

Since the last election, Mr. Hun Sen's government has moved to implement at least half of the CNRP's populist-and popular-seven-point policy campaign platform from 2013.

"They have followed only the political program of the CNRP at the previous election campaign: increasing civil servants' salaries and the wages of the workers, for example. That was the program of the CNRP," said Thun Saray, head of rights group Adhoc.

"For the main and important reforms for the country, such as an independent judiciary and public services, the CPP has still not shown up," he added.

While the CNRP in 2013 pledged to increase the monthly minimum wage in the garment sector from $80 to $150, the CPP government has since brought it up to $140.

A separate 2013 pledge from the CNRP to increase the minimum wage for civil servants from $120 per month to $250 has also been matched by the CPP, with Mr. Hun Sen in November pledging that the salary would hit $250 at the start of 2018-just in time for the election.

In contrast, nine months before the election the prime minister said it would be impossible to raise civil servants' salaries without massive increases on taxes for farmers.

Free health care for the poor, the fifth of the CNRP's seven points from 2013, has also been adopted by the CPP through a new scheme of comprehensive health insurance for each formally employed worker, which was signed into law by Mr. Hun Sen last week.

The CPP has even publicly moved on CNRP promises to reduce fuel and electricity prices and lower unemployment. Only two CNRP campaign planks-a monthly pension for the elderly and a floor price for paddy rice-have not yet been implemented.

"The CNRP's success so far as opposition is getting the country to focus on and try to correct some issues that we raised during our campaign," said Kem Monovithya, the CNRP's deputy head of public affairs

**Continued to Page 20**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ផ្ទុះចលាចលពេលមន្ត្រីសាលារាជធានីធ្វើពិធីផ្តល់សំណង ផ្តាច់ព្រ័ត្រ ដើម្បីបញ្ចប់បញ្ហាបុរីកីឡា

**ដោយប៊ុត គឹមសាយ និងហ្គូច រ៉ាយត៍** | **January 20, 2016**

ពិធីមួយដែលមន្ត្រីសាលារាជធានីភ្នំពេញរៀបចំឡើងដើម្បីផ្តល់សំណងផ្តាច់ព្រ័ត្រដល់ប្រជាពលរដ្ឋរាប់រយគ្រួសារដែលបានធ្វើការតវ៉ាជាច្រើនឆ្នាំប្រឆាំងការបណ្តេញខ្លួនចេញពីសហគមន៍បុរីកីឡា បានផ្ទុះចលាចលកាលពីម្សិលមិញនៅពេលក្រុមសកម្មជនបានសម្រុកចូលពិធីជួបជុំគ្នានេះ រហូតឈានទៅដល់ការប្រវាយប្រតប់គ្នាជាមួយនគរបាល។

ប្រជាពលរដ្ឋទាំង១៥៤គ្រួសារនេះ គឺជាគ្រួសារចុងក្រោយគេដែលត្រូវទទួលបានសំណងក្នុងចំណោមប្រជាពលរដ្ឋយ៉ាងច្រើនដែលត្រូវបានក្រុមហ៊ុនផានអ៊ីម៉ិច បណ្តេញចេញ បន្ទាប់ពីក្រុមហ៊ុននេះទទួលបានសិទ្ធិអភិវឌ្ឍន៍កាលពីឆ្នាំ២០០៣។ ខណៈក្រុមហ៊ុនរួមដ៏មានឥទ្ធិពលមួយនេះទទួលបានកិច្ចសន្យាអភិវឌ្ឍន៍ក្រោមលក្ខខណ្ឌថា ខ្លួននឹងត្រូវសង់ផ្ទះល្វែងចំនួន១០អគារសម្រាប់ប្រជាពលរដ្ឋទាំងនេះនោះ ទីបំផុតខ្លួនបានសាងសង់អគារតែ៨ប៉ុណ្ណោះ ជាហេតុធ្វើឱ្យប្រជាពលរដ្ឋរាប់រយគ្រួសារធ្លាក់ខ្លួនរស់នៅក្នុងស្ថានភាពកខ្វក់ខ្លាំងគួរឱ្យបារម្ភនៅទីតាំងនេះ។

កាលពីខែកញ្ញា សាលារាជធានីប្រកាសថា សំណងនឹងត្រូវផ្តល់ជូនប្រជាពលរដ្ឋ១៥៤គ្រួសារ ក្នុងចំណោម១៨៣គ្រួសារដែលកំពុងរស់នៅលើទីតាំងនេះនៅឡើយ ដោយ៣៥គ្រួសារទទួលបានសំណងធំទី១ នោះគឺផ្ទះមួយល្វែងនៅលើដីដែលធ្លាប់ជារបស់ខ្លួន។ ៨៥គ្រួសារទៀត ត្រូវបានផ្តល់ជម្រើសឱ្យទទួលយកប្រាក់ចំនួន៥.០០០ដុល្លារ ឬដីមួយឡូតិ៍តូចនៅកន្លែងតាំងលំនៅថ្មីក្នុងភូមិឧដុង្គ ខេត្តកណ្តាល ដែលស្ថិតនៅចម្ងាយប្រហែល ៤៥គីឡូម៉ែត្រពីចំណុចកណ្តាលក្រុង ចំណែកឯ ៣៤គ្រួសារចុងក្រោយគេទទួលបានប្រាក់សំណង ៣.០០០ដុល្លារ។ ដោយឡែកការទាមទាររបស់ប្រជាពលរដ្ឋ២៩គ្រួសារផ្សេងទៀតមិនត្រូវបានរដ្ឋាភិបាលសម្រេចទទួលស្គាល់ឡើយ។

ស្ថិតនៅពីក្រោមកៅស៊ូតង់ដែលត្រូវបាន



លោក មាន ចាន់យ៉ាដា ប្រធានរដ្ឋបាលសាលារាជធានី លើកដៃប្រាប់ឱ្យប្រជាពលរដ្ឋនៅសហគមន៍បុរីកីឡាក្នុងរាជធានីភ្នំពេញ រក្សាភាពស្ងៀមស្ងាត់កាលពីម្សិលមិញ អំឡុងពិធីផ្តល់សំណងផ្តាច់ព្រ័ត្រដើម្បីបញ្ចប់បញ្ហារ៉ាំរ៉ៃនៅសហគមន៍នេះ។ រូបថត: Satoshi Takahashi

ដំឡើងលើសំរាមដែលធ្លាប់មានប្រជាពលរដ្ឋចំនួន ១.៧៧៦នាក់រស់នៅ លោក មាន ចាន់យ៉ាដា ប្រធានរដ្ឋបាលសាលារាជធានីបានមានប្រសាសន៍ថា ការផ្តល់សំណងផ្តាច់ព្រ័ត្រនេះបង្ហាញពីការបញ្ចប់ជម្លោះដ៏រ៉ាំរ៉ៃ។

"បុរីកីឡាគឺជាករណីស្មុគស្មាញ ហើយវាមានជម្លោះជាយូរមកហើយ។ ការជួបជុំគ្នានៅថ្ងៃនេះគឺជាការដោះស្រាយបញ្ចប់បញ្ហាជាលើកចុងក្រោយ" នេះជាអ្វីដែលលោក មាន ចាន់យ៉ាដា បានថ្លែងទៅកាន់ប្រជាពលរដ្ឋប្រមាណ ៧០គ្រួសារ ភាគច្រើនជាស្ត្រី និងកុមារដែលមើលទៅហាក់មិនសូវពេញចិត្ត។

**តទៅទំព័រទី ១៨**

# BOREI KEILA CEREMONYDESCENDS INTO CHAOS

**by ButhKimsay and George Wright | January 20, 2016**

A ceremony arranged by Phnom Penh officials to mark their final offers of compensation for hundreds of people who have spent years protesting their eviction from the BoreiKeila neighborhood descended into chaos on Tuesday as activists stormed the meeting, leading to scuffles with police.

The 154 families are the last to be offered compensation among a larger group of residents who were evicted by the Phanimexcompany after it was awarded development rights in 2003. While the powerful conglomerate won the contract on the condition it build 10 apartment blocks to house the residents, it ultimately constructed only eight blocks, leaving hundreds of families to squat in filthy, slum-like conditions at the site.





Protester PhorkSophan is dragged from a ceremony held on Tuesday for residents evicted from Phnom Penh's BoreiKeila neighborhood. (Siv Channa/The Cambodia Daily)

In September, City Hall announced that compensation would be offered to 154 out of the 183 families still living on the site, with 35 families being awarded what amounted to a first prize: an apartment on the land that was once theirs. Eighty-five others would be given a choice between $5,000 or a small plot at the Andong village relocation site in Kandal province, around 45 km from the city center, while the final 34 were offered $3,000. The government decided not to recognize the claims of the other 29 families.

Speaking under a marquee that was erected on rubble where the 1,776-strong community once lived, Mean Chanyada, City Hall's chief of administration, said the final compensation offers signaled the end of the long-running dispute.

"BoreiKeila is a complicated case, and it has been long disputed…. This meeting today marks the final solution of the problem," Mr. Chanyada announced to around 70 residents, most of whom were women and children looking on with disinterest.

Mr. Chanyada said all but one of the 35 families offered apartments accepted the deal, while only 40 of the 85 residents agreed to either $5,000 or a plot in Andong, and just four chose to move to the site. Of the 34 residents offered $3,000, only 16 accepted, he said.

After Mr. Chanyada concluded his speech and handed the microphone to an official who began reciting the names of those who had been offered compensation, a group of around eight women marched toward the marquee, holding banners and waving documentation in the air as they shouted.

"I won't leave BoreiKeila-the company destroyed my house to take the land, and now they've built a villa on it," shouted PhorkSophan, 43.

As a crowd of about 20 reporters surrounded the group of activists, Ms. Sophan lamented her treatment at the hands of authorities. After a few minutes, KeoSakal, chief of Prampi Makara district's **Continued to Page 19**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# លោក ចន ឃើរី សង្កត់ធ្ងន់ពីបញ្ហាសន្តិសុខ និងពាណិជ្ជកម្ម អំឡុងដំណើរទស្សនកិច្ច

**ដោយ Peter Ford និងឃី សុវុឌ្ឍី | January 27, 2016**

មានប្រសាសន៍នៅសួនច្បារនៃសណ្ឋាគារ Raffles កាលពីរសៀលម្សិលមិញ លោក ចន ឃើរី រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក បានលើកឡើងថា "បញ្ហាប្រឈមបន្ទាន់" នៃការប្រឆាំងពួកជ្រុលនិយម ការកសាងទំនាក់ទំនងពាណិជ្ជកម្ម និងការមើលឃើញប្រទេសកម្ពុជាប្រែក្លាយជាប្រទេសប្រជាធិបតេយ្យរីកចម្រើន នោះស្ថិតនៅក្នុងរបៀបវារៈសំខាន់របស់លោក អំឡុងដំណើរទស្សនកិច្ចរយៈពេល១ថ្ងៃនៅក្នុងរាជធានីភ្នំពេញ។

លោក ចន ឃើរី ដែលដំណើរទស្សនកិច្ចរបស់លោកមកកាន់កម្ពុជា ធ្វើឡើងមុនកិច្ចប្រជុំកំពូលអាមេរិក-អាស៊ាននៅខែកុម្ភៈ នៅសាន់នីលែន (Sunnylands) រដ្ឋកាលីហ្វ័រញ៉ា បានចាត់ទុកជំនួបរបស់លោកនៅពេលព្រឹកជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេសថាជាជំនួប "ដោយឥតលាក់លៀម និងក្នុងន័យស្ថាបនា"។

នៅក្នុងសុន្ទរកថាបន្ទាប់ពីការពិភាក្សារបស់លោកជាមួយលោក ហោ ណាំហុង និងជាថ្មីម្តងទៀតនៅក្នុងសុន្ទរកថា នាពេលរសៀល លោក ចន ឃើរី បានលើកឡើងថា ការចូលរួមរបស់ប្រទេសកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងរដ្ឋអ៊ិស្លាម គឺជាអាទិភាពសម្រាប់សហរដ្ឋអាមេរិក។

លោក ចន ឃើរី បានលើកឡើងនៅក្នុងសុន្ទរកថា របស់លោកនាពេលរសៀលថា "ថ្ងៃនេះខ្ញុំក៏បានពិភាក្សាជាមួយលោកនាយករដ្ឋមន្ត្រីអំពីបញ្ហាប្រឈមបន្ទាន់ជាអន្តរជាតិនៃការប្រយុទ្ធប្រឆាំងពួកជ្រុលនិយមដ៏ហិង្សាផងដែរ។ ហើយយើងបានព្រមព្រៀងថា នេះពិតជាអាទិភាពចម្បងនៅក្នុងទំនាក់ទំនងរវាងប្រទេសណាមួយនៅថ្ងៃនេះ"។

ដោយប្រើពាក្យសម្រាប់រដ្ឋអ៊ិស្លាមដែលចេញពីពាក្យអារ៉ាប់ លោក ចន ឃើរី បានថ្លែងថា "លោកនាយករដ្ឋមន្ត្រីបានសម្តែងការចាប់អារម្មណ៍យ៉ាងខ្លាំងលើប្រទេសកម្ពុជាក្នុងការធ្វើការងារជាមួយកងកម្លាំងចម្រុះប្រឆាំងពួកជ្រុលនិយម"។

លោកបានថ្លែងថា "គាត់បានសម្តែងការចាប់អារម្មណ៍លើក្រុមរបស់យើងអ្នកជំនាញរបស់យើងមកគឺដើម្បីរៀបរាប់សង្ខេប និងផ្លាស់ប្តូរយោបល់ ហើយយើងបានយល់ព្រមចំពោះរឿងនោះ"។ លោកបានបន្ថែមថា កិច្ចប្រជុំកំពូលនៅសាន់នីលែននឹងផ្តល់ឱកាសដល់មេដឹកនាំទាំងអស់ដែលមកជួបប្រជុំគ្នាមាន "ការពិភាក្សាស៊ីជម្រៅ" អំពីប្រធានបទនេះ។

អង្គការសង្គមស៊ីវិលបានផ្ញើលិខិតចំហមួយច្បាប់ជូនលោក ចន ឃើរី នៅសប្តាហ៍នេះជំរុញឱ្យ



លោកលើកឡើងអំពីការរំលោភបំពានសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា និងការវាយប្រហារកាលពីពេលថ្មីៗទៅលើគណបក្សប្រឆាំងអំឡុងជំនួបរបស់លោកជាមួយលោក ហ៊ុន សែន។



លោក ចន ឃើរី រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកថ្លែងទៅកាន់ក្រុមអ្នកយកព័ត៌មាននៅសួនច្បារសណ្ឋាគារ Raffles ក្នុងរាជធានីភ្នំពេញកាលពីម្សិលមិញ។ រូបថត: ស៊ីវ ចាន់ណា,The Cambodia Daily

លោក ចន ឃើរី បានថ្លែងថា លោកបានលើកឡើងពីបំណងរបស់លោកចង់ឃើញប្រជាជនកម្ពុជាទទួលបានប្រយោជន៍ពីប្រទេសរបស់ខ្លួនដែលក្លាយជាប្រទេសប្រជាធិបតេយ្យពហុបក្ស និងរីកចម្រើន។ **តទៅទំព័រទី ២៧**

# KERRY STRESSES SECURITY AND TRADE DURING VISIT

**by Peter Ford and KhySovuthy | January 27, 2016**

Speaking in the garden of the Raffles Hotel on Tuesday afternoon, U.S. Secretary of State John Kerry said the "urgent challenge" of countering extremism, building business ties and seeing Cambodia become a thriving democracy were at the top of his agenda during his daylong visit to Phnom Penh.

Mr. Kerry, whose trip to Cambodia comes ahead of the February U.S.-Asean summit in Sunnylands, California, described his morning meetings with Prime Minister Hun Sen and Foreign Minister Hor Namhong as being "candid and constructive."

In remarks following his talks with Mr. Namhong and again in his address in the afternoon, Mr. Kerry said that bringing Cambodia into the fold in the fight against the Islamic State group was a priority for the U.S.

"Today I also discussed with the Prime Minister the urgent challenge internationally of countering violent extremism. And we agreed that this is absolutely a top priority in the relationship between any country today," Mr. Kerry said in his afternoon address.

"The prime minister expressed a deep interest in Cambodia working with our counter-Daesh coalition," Mr. Kerry said, using a term for I.S. derived from its Arabic spelling.

"He expressed an interest in having our teams, our experts, come in order to brief and exchange ideas, and we agreed to that," he said, adding that the summit in Sunnylands would provide an opportunity for the assembled leaders to have an "in-depth dialogue" on the topic.

Civil society groups sent Mr. Kerry an open letter this week urging him to address a litany of human rights abuses in Cambodia and a recent offensive against the political opposition during his meeting with Mr. Hun Sen.

Mr. Kerry said he had stated his desire to see the Cambodian people benefit from having their country become a "thriving, multiparty democracy."

"I made it clear also in my meetings today that it is our hope-I think it's a global hope-that Cambodia will realize the full benefits of a thriving, multiparty democracy," he said.

"We care deeply about respect for human rights, universal freedoms, and good governance," he added. "And progress in each of these areas is really critical to being able to fulfill the potential of our bilateral relations but also, importantly, the full potential of the hopes and aspirations of the Cambodian people."

Cambodian state news agency AKP took a different angle to Mr. Kerry's talks with the prime minister, heralding the fact that human rights had not been raised, in an article on its website headlined "No Human Rights Issue Mentioned During Talks between Cambodian PM and U.S. Secretary of State."

In an apparent reference to the October beatings of opposition lawmakers NhayChamroeun and Kong Saphea, Mr. Kerry said ensuring the safety of lawmakers was "a fundamental responsibility" of the government.

"Democratic governments have a responsibility to ensure that all elected representatives are free to perform their responsibilities without fear of attack or arrest," he said.

Earlier in the afternoon, Mr. Kerry met with a delegation of senior opposition officials, including deputy opposition leader Kem Soha, and held a separate meeting with local civil society leaders.

"In every meeting, I made clear that we are committed-we the United States of America are committed-to the relationship between our country and Cambodia," he said.

In a message posted to Facebook, Ou Virak, founder of the Future Forum think tank, **Continued to Page 23**

តមកពីទំព័រទី ១៦
## ផ្ទះចលាចលពេលមន្ត្រីសាលារាជធានី...

លោកលើកឡើងទៀតថា ប្រជាពលរដ្ឋទាំងអស់លើកលែងតែមួយគ្រួសារនៅក្នុងចំណោម ៣៥គ្រួសារដែលត្រូវបានផ្ដល់ផ្ទះល្វែង បានទទួលយកកិច្ចព្រមព្រៀងនេះហើយមានតែ៤០គ្រួសារប៉ុណ្ណោះក្នុងចំណោម៨៥គ្រួសារដែលយល់ព្រមទទួលយកប្រាក់សំណង៥.០០០ដុល្លារ ឬដីមួយឡូតិ៍នៅឧដុង្គ ហើយមានតែបួនគ្រួសារប៉ុណ្ណោះដែលសុខចិត្តផ្លាស់ទៅតំបន់នោះ។ ក្នុងចំណោមប្រជាពលរដ្ឋ៣៤គ្រួសារដែលត្រូវបានផ្ដល់ប្រាក់សំណង៣.០០០ដុល្លារមានតែ១៦គ្រួសារប៉ុណ្ណោះដែលសុខចិត្តទទួលយក។

បន្ទាប់ពីលោក មាន ចាន់យ៉ាដា បញ្ចប់សុន្ទរកថារបស់ខ្លួន ហើយប្រគល់មីក្រូហ្វូនឱ្យទៅមន្ត្រីម្នាក់ដែលបានចាប់ផ្ដើមហៅឈ្មោះអ្នកដែលត្រូវបានផ្ដល់សំណងភ្លាម ស្រាប់តែស្ត្រីមួយក្រុមមានគ្នាប្រហែលប្រាំបីនាក់បានហែក្បួនឆ្ពោះទៅរកតង់នោះ ដោយលើកបដាគ្រវីឯកសារឡើងលើពេលពួកគាត់ស្រែក។

អ្នកស្រី ភោគ សុផាន អាយុ៤៣ឆ្នាំបានស្រែកថា "ខ្ញុំនឹងមិនចេញពីបុរីកីឡាទេ ក្រុមហ៊ុនបានកម្ទេចផ្ទះខ្ញុំដើម្បីយកដី ហើយពេលនេះពួកគេបានសង់វីឡាលើដីនេះហើយ"។

នៅពេលក្រុមអ្នកយកព័ត៌មានប្រហែល២០នាក់ព័ទ្ធជុំវិញសកម្មជនទាំងនេះ អ្នកស្រីភោគ សុផានបានសម្ដែងការខកចិត្តចំពោះអ្វីដែលអាជ្ញាធរបានធ្វើដាក់គាត់។ ប៉ុន្មាននាទីក្រោយមកលោកស្រី កែវ សាកល ចៅសង្កាត់វាលវង់ ខណ្ឌ៧មករា បានចូលទៅជិតអ្នកស្រី ភោគ សុផាន ហើយបានចាប់ឱបអ្នកស្រីហាក់ដូចជាព្យាយាមធ្វើឱ្យអ្នកស្រីរក្សាភាពស្ងាត់ស្ងៀម មុនពេលប្រគល់អ្នកស្រីភ្លាមៗឱ្យទៅនគរបាលខណ្ឌ ដែលចាប់ផ្ដើមអូសគាត់កាត់មនុស្សជាច្រើនឆ្ពោះទៅផ្លូវថ្នល់។

ពេលកំពុងផ្ទះចលាចលនេះ មន្ត្រីសាលារាជធានីមួយរូបបានពិភាក្សាជាមួយនគរបាល ហើយអ្នកស្រីក៏ត្រូវបានបញ្ជូនទៅខាងក្រោយតង់នោះជាមួយសកម្មជនរបស់គាត់ រួចពិធីនេះក៏ត្រូវបានបិទភ្លាមៗ។

ពេលត្រឡប់ទៅផ្ទះល្វែងរបស់ប្អូនប្រុសគាត់ដែលស្ថិតនៅអគារមួយក្នុងចំណោមផ្ទះល្វែងទាំងប្រាំបីអគារ អ្នកស្រី ភោគ សុផាន បាននិយាយទាំងទឹកភ្នែករលីងរលោងថា អ្នកស្រីបានសម្រេចចិត្តទៅអុកឡុកពិធីនេះបន្ទាប់ពីគ្រួសាររបស់គាត់ត្រូវបានលុបចេញពីបញ្ជីសំណងផ្ដាច់ព្រ័តនេះ។

អ្នកស្រីនិយាយថា "ធ្វើបែបនេះអយុត្តិធម៌ណាស់។ ឱ្យលោកស្រី សាកល បានប្រាប់គេឱ្យនាំខ្លួនខ្ញុំទៅសាលាខណ្ឌ តែខ្ញុំមិនខ្លាចទេ ព្រោះខ្ញុំមិនបានធ្វើខុស។ ខ្ញុំរស់នៅទីនេះតាំងពីឆ្នាំ១៩៩៦ និងមានឯកសារបញ្ជាក់"។

អ្នកស្រី អ៊ឹម ស្រីមុំ អាយុ៣៥ឆ្នាំ បាននិយាយនៅផ្លូវឡើងហែមដែលសម្បូរដោយសត្វរុយកាត់តំបន់ដែលមានប្រជាពលរដ្ឋរាប់រយនាក់កំពុងរស់នៅនេះថា អ្នកស្រីសុខចិត្តចុះចាញ់លែងប្រឆាំងសាលារាជធានី និងក្រុមហ៊ុនផានអ៊ីម៉ិចទៀតហើយ។

អ្នកស្រីបានបន្តថា "ខ្ញុំយល់ព្រមទទួលយកសំណង៥.០០០ដុល្លារ។ ខ្ញុំមិនចង់ទៅរស់នៅឧដុង្គទេ ព្រោះវាតូចពេកសម្រាប់កូន៧ខ្ញុំ។ ខ្ញុំមិនពេញចិត្តនឹងកិច្ចព្រមព្រៀងនេះទេ ប៉ុន្តែខ្ញុំគ្មានជម្រើស។ ខ្ញុំមិនអាចរស់នៅទីនេះទៀតបានទេ ខ្ញុំក៏មានអារម្មណ៍ឈឺចាប់ដែរនៅទីនេះ" ហើយថា គាត់មានគម្រោងប្រើប្រាស់លុយនេះសម្រាប់ការតាំងលំនៅថ្មីក្នុងខេត្តកោះកុង។

អ្នកស្រីបានលើកឡើងបន្ថែមទៀតថា "ខ្ញុំបានចូលរួមតវ៉ាយូរណាស់មកហើយ។ ខ្ញុំចង់តស៊ូបន្តទៀត ប៉ុន្តែខ្ញុំគ្មានជម្រើសទេ។ ខ្ញុំលែងធ្វើបែបនេះបានទៀតហើយ។ ខ្ញុំមានកូន ហើយខ្ញុំមិនអាចទំនុកបម្រុងពួកគេឱ្យបានល្អទេ បើខ្ញុំបន្តធ្វើការតវ៉ាទៀត"។

ពេលទាក់ទងបន្ទាប់ពីពិធីនេះបិទ លោកស្រី កែវ សាកល បដិសេធថាមិនបានប្រគល់ខ្លួនអ្នកស្រី ភោគ សុផាន ឱ្យទៅនគរបាលទេ ហើយបានលើកឡើងថា ការប្រតាយប្រតប់គ្នាមួយប្រាវនេះគ្រាន់តែជាការយល់ច្រឡំប៉ុណ្ណោះ។

លោកស្រីបានមានប្រសាសន៍ថា "ខ្ញុំទៅជួយគាត់ ពីព្រោះខ្ញុំចង់ឱ្យអ្នកតវ៉ានិយាយជាមួយអាជ្ញាធរ។ ខ្ញុំមិនបានប្រគល់គាត់ឱ្យទៅប៉ូលិសទេ។ ការតវ៉ានេះកើតឡើងដោយសារតែអ្នកកាសែត និងអ្នកថតជាច្រើនបាំងពួកគាត់ធ្វើឱ្យពួកគាត់ស្ដាប់មិនឮអ្វីដែលអ្នកតំណាងបានប្រកាស"។

ទោះបីជាសាលារាជធានីប្រឹងប្រែងបញ្ចប់ជម្លោះបុរីកីឡាយ៉ាងណាក្ដី ក៏អ្នកស្រី ភោគ សុផាន បានប្ដេជ្ញាធ្វើការតវ៉ាតទៅទៀត។ អ្នកស្រី និយាយថា "ខ្ញុំនឹងតវ៉ាទៀតខ្ញុំមិនឈប់ទេ"៕ **សុខុម**


**បន្ថយចំណាយថ្លៃភ្លើង និងហ្គាស**

ខែរងាមកដល់ ចំណាយថ្លៃភ្លើង និងហ្គាស និងឡើងថ្លៃគួរឱ្យបារម្ភ

-ចង់បញ្ចុះតម្លៃពី២០-៤០% សូមទូរស័ព្ទមក

**Pin Samkhon: 978-942-1641**

**Alex: 978-569-6034**





CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- រឹកខឹខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថៃឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង



Allstate. You're in good hands.



Veasna Chhay
Licensed Sales Producer
Home/Auto/Life MA & RI

Allstate Insurance Company
1535 Smith Street
North Providence, RI 02911

Phone 508-282-5820/Cell 401-588-4358
veasnachhay2@allstate.com

Personalized service.
Trusted advice.

" Also I do income tax return service for MA and RI for "Veasna Tax Preparation Serivices'."



**ការងារ ! ការងារ! ការងារ!**

ត្រូវការអ្នកបកប្រែជាភាសាខ្មែរនៅសាលារដ្ឋដែលស្ថិតនៅ Lynn និង Revere ។

ដោយចាប់ផ្ដើមដំបូងក្នុងមួយម៉ោង២០ដុល្លារ ។ ដោយមិនចាប់បាច់ត្រូវការនូវសញ្ញាប័ត្រនោះទេ ។

បើសិនជាចាប់អារម្មណ៍សូមមេត្តាទាក់ទងទៅកាន់ទូរស័ព្ទ **978-594-4695** ឬក៏ផ្ញើអ៊ីមែលទៅកាន់ **Jim@CityGateLs.com**

**JOBS! JOBS! JOBS!**

Khmer Interpreters needed for Public Schools in Lynn and Revere.

We pay $20.00 per hour to start. No certifications required.

**Please call 978-594-4695 or email jim@CityGateLS.com**

តមកទំព័រទី ១៤

## លោក ទេព នីថា នៅតែ...

ឆ្នោតជាតិឆ្នាំ២០១៨ ហើយបានចាប់ផ្តើមការងារសំខាន់ៗរួចហើយដូចជាការធ្វើតេស្តប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោតដែលប្រើអត្តសញ្ញាណកម្មជីវមាត្រជាដើម។

លោក រ៉ុង ឈុន បាននិយាយថា លោកបានទទួលយកសេចក្តីសម្រេចរបស់សហការីរបស់លោក ហើយសង្ឃឹមថា ការងារជាក់ស្តែងរបស់គណៈកម្មាធិការនេះ និងវិធានដ៏ខ្លាំងដែលគ្រប់គ្រងតួនាទីរបស់ខ្លួននឹងធ្វើឱ្យការតែងតាំងលោក ទេព នីថា មិនសំខាន់នៅក្នុងគម្រោងការងារដ៏ធំនេះទេ។

ប៉ុន្តែនៅពេលវិធានថ្មីតម្រូវឱ្យគ.ជ.ប.ព្រមព្រៀងតាមសេចក្តីសម្រេចដែលពេលនោះចាត់ចែងដោយអគ្គលេខាធិការរូបនេះ គណបក្សសង្គ្រោះជាតិបាននិយាយថា ការដាក់លោក ទេព នីថា មកវិញក្នុងតួនាទីមុនរបស់គាត់បានធ្វើឱ្យខូចកិច្ចការរបស់ស្ថាប័ននេះ។

គណបក្សប្រឆាំងនេះបាននិយាយក្នុងសេចក្តីថ្លែងការណ៍ថា "ការតែងតាំងលោក ទេព នីថា ដែលជាអគ្គលេខាធិការ គ.ជ.ប. ចាស់ឱ្យទទួលតួនាទីជាអគ្គលេខាធិការថ្មី អាចនាំឱ្យមានការមិនទុកចិត្តលើការបោះឆ្នោតនាពេលខាងមុខ។ គណបក្សសង្គ្រោះជាតិមានការសោកស្តាយនិងខកចិត្តយ៉ាងខ្លាំងចំពោះសេចក្តីសម្រេចនេះ"។

លោក គុយ ប៊ុនរឿន អនុប្រធាន គ.ជ.ប. ជាបេក្ខជនតែងតាំងដោយគណបក្សសង្គ្រោះជាតិបាននិយាយថា លោកបានដឹងអំពីការរិះគន់នេះ ប៉ុន្តែបានបញ្ជាក់ថា ការងារនេះកើតចេញពីការពិនិត្យពិច័យ និងតុល្យភាពគ្រប់គ្រាន់។

លោក គុយ ប៊ុនរឿន បាននិយាយថា "ខ្ញុំចង់បំភ្លឺសាធារណជនកុំឱ្យមានការយល់ច្រឡំដោយគិតថាការគ្រប់គ្រងអគ្គលេខាធិការដ្ឋាននេះគឺដឹកនាំដោយអគ្គលេខាធិការតែម្នាក់នោះ។ យើងត្រូវពិភាក្សាជាមួយអគ្គលេខាធិការរងបួននាក់ទៀត"។

លោក ប៊ុនហុក បានមានប្រសាសន៍បន្ទរថា "សេចក្តីសម្រេចទាំងអស់ត្រូវធ្វើឡើងដោយគ.ជ.ប. មិនមែនដោយអគ្គលេខាធិការអគ្គលេខាធិការរង ប៉ិច (គណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត) ស៊ិច (គណៈកម្មាធិការរៀបចំការបោះឆ្នោតឃុំសង្កាត់) ឬមន្ត្រីការិយាល័យបោះឆ្នោតនោះទេ"។

ក្រៅពីលោក ទេព នីថា ដែលបានឈរឈ្មោះជាមួយលោក ហេង មណីចិន្តា និងលោក យ៉ា ណាវុធ ដែលសុទ្ធតែជាស្ថាបនិកអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនោះ កាលពីថ្ងៃសុក្រគ.ជ.ប. ក៏បានជ្រើសរើសអគ្គលេខាធិការរង៤រូបរបស់ខ្លួន។

លោក នី ចរិយា ប្រធានផ្នែកសិទ្ធិមនុស្សនិងផ្នែកជំនួយច្បាប់នៃអង្គការអាដហុកត្រូវបានតែងតាំងឱ្យទទួលបន្ទុកផ្នែកសវនកម្មផ្ទៃក្នុង មេធាវី ម៉ៅ សុភារិទ្ធ អតីតសមាជិកគ.ជ.ប. នឹងគ្រប់គ្រងផ្នែកប្រតិបត្តិការ និងផ្នែកទិន្នន័យចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីអ្នកបោះឆ្នោតលោក សោម សូរីដា ក៏ជាអតីតមន្ត្រីគ.ជ.ប.ដែរ នឹងមើលខុសត្រូវផ្នែកសេវាកម្មច្បាប់ និងដោះស្រាយជម្លោះ ហើយលោក ម៉ុក ដារ៉ា ជាសាស្ត្រាចារ្យច្បាប់ និងជាប្រធានជំនួយច្បាប់នៅក្រុមឃ្លាំមើលការបោះឆ្នោតនិកហ្វិច ត្រូវកាន់ការខាងផ្នែកបណ្តុះបណ្តាល ព័តិមាន និងទំនាក់ទំនងសាធារណៈ។

លោក ហង្ស ពុទ្ធា អ្នកនាំពាក្យ គ.ជ.ប.ជាសមាជិកទី៩ "អព្យាក្រឹត" បានបដិសេធមិននិយាយ ថាតើលោកបានគាំទ្រ ឬប្រឆាំងលោក ទេព នីថា ក្នុងកិច្ចប្រជុំនោះទេ។ លោកបាននិយាយថា "មានការពិភាក្សា និងការពិគ្រោះយោបល់ ហើយទទួលបានសំឡេងភាគច្រើន៥០បូក១ ជាសំឡេងដាច់ខាត"។

លោក គុយ ប៊ុនរឿន សមាជិកតែងតាំងដោយគណបក្សប្រឆាំងក៏បានបដិសេធមិនបញ្ចេញឱ្យដឹងនូវការគិតឃើញរបស់លោកដែរ។

នៅពេលសួរដោយអ្នកយកព័តិមានម្នាក់ ថាតើលោក "សប្បាយចិត្តនឹងធ្វើការជាមួយលោក ទេព នីថា ឬទេ"? លោកបាននិយាយថា "បញ្ហាគឺត្រង់ថា គាត់អាចធ្វើការងារល្អ ឬអត់ ប្រសិនបើគាត់ធ្វើការងារល្អយើងសរសើរគាត់"៕និត

Continued from page 14

# TEP NYTHA REAPPOINTED...

"The appointment of TepNytha, the current NEC secretary-general, to assume the role as secretary-general again…could cause distrust in future elections," the opposition said in a statement.

"The CNRP is very sorry and disappointed with the decision."

The NEC's vice chairman, KuoyBunroeun, a CNRP appointee, said he was aware of the criticisms, but stressed that the job came with ample checks and balances.

"I want to clarify to the public so it does not get confused, thinking that the management of the secretariat general is just led by the secretary-general alone. He must discuss with the four deputy secretaries-general," Mr. Bunroeun said.

"All decisions are made by the NEC," echoed Mr. Bunhok. "Not by the secretary-general, deputy secretaries-general, PEC [Provincial Election Committee], CEC [Commune Election Committee] or electoral office officials," he said.

Apart from Mr. Nytha, who had been running alongside HengMonychenda and YaNavuth- both founders of local NGOs-the NEC on Friday selected its four deputy secretaries-general.

NyChakrya, head of rights group Adhoc's human rights and legal aid section, was appointed to take charge of the internal audit department; attorney Mao Sophearith, a former NEC member, will manage the operations department and department of voter registration data and voter lists; SomSorida, also a former NEC official, will oversee the legal service and dispute department; and Mok Dara, a law professor and head of legal aid at election watchdog Nicfec, is to take over the training, media and public relations department.

NEC spokesman Hang Puthea, the ninth "neutral" member, declined to say whether he had supported or opposed Mr. Nytha during the meeting.

"There was discussion and consultation, and it received 50-plus-one, an absolute majority," he said.

Mr. Bunroeun, the opposition appointee, also declined to reveal his thinking.

Asked by a reporter whether he was "happy" to be working with Mr. Nytha, he said all that "matters is whether he can perform a good job or not."

"If he does a good job, we congratulate him."

Continued from page 16

# BOREI KEILA CEREMONYDESCENDS...

Veal Vong commune, approached Ms. Sophan and briefly embraced her in what seemed to be an attempt to calm her, before abruptly handing her to district police officials, who began dragging her through the crowd toward the road.

Mean Chanyada, City Hall's chief of administration, holds up his hand to silence residents of Phnom Penh's BoreiKeila neighborhood on Tuesday. (Satoshi Takahashi)

Amid the commotion, a City Hall official conferred with the police, at which point she was returned to the back of the marquee with her fellow activists and the event was swiftly shut down.

Back at her brother's apartment, located in one of the eight apartment blocks, a tearful Ms. Sophan said she decided to gate-crash the event after her family was left off the final compensation list.

"The treatment was completely unfair. [Ms. Sakal] told them to take me to the district office, but I'm not scared because I haven't done anything wrong," Ms. Sophan said.

"I've lived here since 1996 and have the documents to prove this," she added.

Speaking in the fly-infested alleyway that weaves through the area where hundreds of residents still live, Im Sreymom, 35, said she had accepted defeat in her battle against City Hall and Phanimex.

"I agreed to take $5,000. I don't want to live in Andong because it's too small for my children. I'm not happy with the deal but I have no choice. I can't live here any longer. I feel too much hurt here after everything," Ms. Sreymom said, adding that she planned to use the money to relocate to Koh Kong province.

Members of Phnom Penh's BoreiKeila community protest near the site of a ceremony to mark final compensation offers for evicted residents on Tuesday. (Siv Channa/The Cambodia Daily)

"I've been involved with the protests for so long. I want to continue fighting but I have no choice. I can't do this anymore. I've got kids and I can't support them properly if I carry on protesting," she said.

Contacted after the event was shut down, Ms. Sakal denied handing Ms. Sophan over to police and said the brief fracas was simply a misunderstanding.

"I went to help her because I wanted the protesters to talk with authorities. I did not hand her over to the police," Ms. Sakal said.

"The protest happened because many journalists and cameramen were blocking them and that's why they could not hear what the representative announced," she said.

Despite City Hall's efforts to draw a line under the BoreiKeila dispute, Ms. Sophan vowed to keep protesting.

"I will continue to protest. I will never stop," she said.

តមកពីទំព័រទី ១៥

## សម្រាប់របៀបវារៈគណបក្សប្រជាជន...

ការគាំពារសុខភាពដោយឥតគិតថ្លៃសម្រាប់ប្រជាជនក្រីក្រ ជាចំណុចទី៥នៃចំណុចទាំងប្រាំពីររបស់គណបក្សសង្គ្រោះជាតិ កាលពីឆ្នាំ២០១៣ ក៏ត្រូវយកមកអនុវត្តដោយគណបក្សប្រជាជនកម្ពុជា តាមរយៈគម្រោងថ្មីនៃការធានាសុខភាពទូលំទូលាយសម្រាប់កម្មករដែលបម្រើការងារក្នុងប្រព័ន្ធដែលលោកនាយករដ្ឋមន្ត្រីបានចុះហត្ថលេខាឱ្យទៅជាច្បាប់កាលពីសប្តាហ៍មុន។

គណបក្សប្រជាជនកម្ពុជាថែមទាំងអនុវត្តការសន្យារបស់គណបក្សសង្គ្រោះជាសាធារណៈដើម្បីកាត់បន្ថយតម្លៃប្រេងឥន្ធនៈនិងអគ្គិសនី និងកាត់បន្ថយការអត់ការងារធ្វើ។ មានតែកម្មវិធីយុទ្ធនាការគណបក្សសង្គ្រោះជាតិពីរប៉ុណ្ណោះពោល គឺសោធននិវត្តសម្រាប់មនុស្សចាស់ និងតម្លៃស្រូវ គឺនៅមិនទាន់បានអនុវត្តនៅឡើយទេ។

កញ្ញា កឹម មនោវិទ្យា អនុប្រធានកិច្ចការសាធារណៈរបស់គណបក្សសង្គ្រោះជាតិ និងជាកូនស្រីរបស់លោក កឹម សុខា អនុប្រធានបក្សបានមានប្រសាសន៍ថា "ជោគជ័យរបស់គណបក្សសង្គ្រោះជាតិរហូតមកដល់ពេលនេះ គណបក្សប្រឆាំងកំពុងជំរុញឱ្យប្រទេសជាតិផ្តោតទៅលើនិងព្យាយាមដោះស្រាយបញ្ហាមួយចំនួនដែលយើងបានលើកឡើងពេលធ្វើយុទ្ធនាការរបស់យើង"។

កញ្ញា មនោវិទ្យា បានមានប្រសាសន៍ថា ថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិពេញចិត្តនឹងតម្លៃនៃគោលនយោបាយថ្មីសម្រាប់សាធារណជនដោយមិនព្រួយបារម្ភថា គេអាចជួយគណបក្សប្រជាជនកម្ពុជាពង្រឹងប្រជាប្រិយភាពផ្ទាល់ខ្លួនទេ ព្រោះថាកំណែទម្រង់ទូលំទូលាយមិនទាន់អនុវត្តនៅឡើយទេ"។

អនុប្រធានកិច្ចការសាធារណៈគណបក្សសង្គ្រោះជាតិរូបនេះ បានមានប្រសាសន៍ថា "កំណែទម្រង់សំខាន់បំផុតនិងចាំបាច់ គឺជាកំណែទម្រង់ផ្នែកស្ថាប័ន ហើយមិនទាន់កើតមាននៅក្នុងរដ្ឋាភិបាលនេះនៅឡើយទេ ពីព្រោះកំណែទម្រង់ស្ថាប័នបែបហ្នឹងនឹងរុះរើក្រុមផលប្រយោជន៍ដែលជាផៅសន្តានសំខាន់របស់គណបក្សប្រជាជនកម្ពុជា"។

ប៉ុន្តែ លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា សាធារណជនបានទទួលយកកិច្ចខំប្រឹងប្រែងថ្មីៗនេះរបស់លោក ហ៊ុន សែន ក្នុងការធ្វើខ្លួនលោកជាមេដឹកនាំដែលនៅកៀកនឹងថ្នាក់មូលដ្ឋាន ចាប់តាំងពីមានមេរៀនពីការបោះឆ្នោតនាឆ្នាំ២០១៣។

លោក សុខ ឥសាន បានមានប្រសាសន៍ថា "យើងបន្តអនុវត្តកំណែទម្រង់ឆ្លើយតបនឹងសេចក្តីត្រូវការប្រជាជន ព្រោះយើងមិនផ្តល់ការសន្យាខ្យល់ទេ ប៉ុន្តែយើងធ្វើឆ្លើយតបនឹងសេចក្តីត្រូវការប្រជាជន។ យើងជឿថាសាធារណជនបានឃើញរួចហើយថារដ្ឋាភិបាលបានធ្វើ ដើម្បីដោះស្រាយទុក្ខលំបាកប្រជាពលរដ្ឋ"។

លោក សុខ ឥសាន បានលើកឡើងអំពីកំណែទម្រង់អប់រំ ការកាត់បន្ថយតម្លៃអគ្គិសនីដែលប្រកាសថ្មីៗនេះ ការដំឡើងបន្តទៀតចំពោះប្រាក់ខែមូលដ្ឋានសម្រាប់មន្ត្រីរាជការ និងការលុបចោលនាពេលថ្មីៗនេះចំពោះពន្ធមួយចំនួនដែលប៉ះពាល់ដល់ប្រជាជនក្រីក្រ ក៏ស្ថិតក្នុងគោលនយោបាយថ្មីល្អបំផុតរបស់គណបក្សប្រជាជនកម្ពុជាដែរ។

លោក សុខ ឥសាន បានមានប្រសាសន៍ថា "ផ្អែកលើព័ត៌មានទទួលបានពីមន្ត្រីមូលដ្ឋានគណបក្សប្រជាជន ទើបសម្តេច ហ៊ុន សែន ក្នុងនាមជាប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីផង បានដោះស្រាយទាន់សភាពការណ៍និងទាន់ពេលវេលាតាមរយៈការពិភាក្សាហ្មត់ចត់ជាមួយមន្ត្រីគណបក្សប្រជាជនផ្សេងទៀត"។

អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជារូបនេះបានពន្យល់ថា "យើងដោះស្រាយបញ្ហាអស់ទាំងនេះ ទៅតាមយុទ្ធសាស្ត្ររបស់បក្ស ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន រួមមានសម្រាប់មន្ត្រីរាជការ កងប្រដាប់អាវុធ និងកូនចៅប្រជាជនកម្ពុជា។ គណបក្សប្រជាជនកម្ពុជាមានយុទ្ធសាស្ត្របែបហ្នឹងតាំងពីដើមមក ហើយមិនធ្វើតាមគណបក្សមួយចំនួនដែលទើបកើតពីម្សិលមិញទេ ប៉ុន្តែមកអួតខ្លួនឯងថា គណបក្សប្រជាជនកម្ពុជាធ្វើតាមគោលនយោបាយរបស់ខ្លួន"។

បន្ថែមទៅលើកំណែទម្រង់ទាំងនេះ គណបក្សប្រជាជនកម្ពុជាប្រកាន់យករបៀបឆ្លើយតបជាងមុនដោយលោក ហ៊ុន សែន និងមន្ត្រីជាច្រើនទៀតបង្កើតហ្វេសប៊ុកផ្ទាល់ខ្លួន ដែលពួកគេអាចប្រាស្រ័យទាក់ទងផ្ទាល់ជាមួយប្រជាពលរដ្ឋ។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី បានមានប្រសាសន៍ថា យុទ្ធសាស្ត្រនេះកំពុងទទួលបាននូវភាគលាភ។

លោក ផៃ ស៊ីផាន បានមានប្រសាសន៍ថា "ឥឡូវនេះ លោកនាយករដ្ឋមន្ត្រីក៏ទាក់ទងផ្ទាល់ជាមួយប្រជាពលរដ្ឋ។ ពីមុនលោកត្រូវអង្គុយអានរបាយការណ៍ ប៉ុន្តែឥឡូវនេះ លោកអាចដឹងពីប្រជាពលរដ្ឋ ហើយឆ្លើយតបភ្លាមៗចំពោះការត្អូញត្អែរ និងទុក្ខលំបាករបស់ពួកគេ ហើយធ្វើវិសោធនកម្មច្បាប់"។

អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីរូបនេះបានមានប្រសាសន៍ថា "ចំពោះខ្ញុំ ខ្ញុំឃើញហ្វេសប៊ុកលោកនាយករដ្ឋមន្ត្រីនិងប្រជាពលរដ្ឋ គេចុចឡៃច្រើនណាស់។ មនុស្សជាង១លាននាក់ចុចឡៃលើទំព័ររបស់លោក ដូច្នេះខ្ញុំគិតថា គេពេញចិត្តកិច្ចខិតខំប្រឹងប្រែងរបស់លោកនាយករដ្ឋមន្ត្រី"។

លោក ធន់ សារ៉ាយ ប្រធានអង្គការសិទ្ធិមនុស្សអាដហុកបានមានប្រសាសន៍ថា លោកមិន

តទៅទំព័រទី២១

Continued from page 15

# FOR REFORM AGENDA...

and a daughter of Mr. Sokha, the party vice president.

Ms. Monovithya said that CNRP leaders appreciated the value to the public of the new policies, and were not concerned that they could help the CPP bolster its own popularity given that broader reforms had not yet been instituted.

"The most important and necessary reform is institutional reform, and that is not happening with this government, because such institutional reforms would shake up interest groups who are core CPP patrons."

Yet CPP spokesman Sok Eysan said he believed that the public had been receptive to Mr. Hun Sen's recent efforts to recast himself as a more accessible leader since the lessons of the 2013 election.

"We have continued to implement reforms in favor of the people's needs, as we don't give insubstantial promises, but we take action in favor of people's needs. We believe the public has seen how much the government has already done to solve the people's suffering," Mr. Eysan said.

Mr. Eysan pointed to education reform, recently announced electricity price reductions, ongoing increases in the minimum wage for civil servants, and the recent scrapping of an array of unpopular taxes affecting the poor as among the CPP's best new policies.

"Based on information collected from the constituencies by the CPP's outreach officials, Hun Sen, as the CPP's president and prime minister, has solved these problems in quick time through critical discussions with other CPP officials," Mr. Eysan said.

"We do these things because they are part of the party's strategy for reduction of poverty among our population-including for the civil service, armed forces, and other Cambodians," he explained.

"The CPP has had such a strategy for a long time, and doesn't just follow this number of new parties who were just created yesterday, but boastfully allege that the CPP has been using their policies."

In addition to these reforms, the CPP has taken up a more responsive style of government, with Mr. Hun Sen and many other officials creating personal Facebook pages on which they communicate directly with citizens.

Mr. Siphan, the Council of Ministers spokesman, said that this strategy had been paying dividends.

"The prime minister now has also been communicating directly with the people. Before, he had to sit down and read reports, but now he can learn from the people and immediately reply to their complaints and grievances, and amend the law," Mr. Siphan said.

"For myself, I see the prime minister's Facebook, and the people, they click 'like' a lot. More than a million people have liked his page. So I think they appreciate the prime minister's efforts," he added.

Mr. Saray of Adhoc said he was unsure if such a strategy of piecemeal reform and social media outreach would be effective, but said the 2017 commune council elections would likely reveal the answer to the question.

"Normally in a democratic society, they do polls of the opinions of the people, but now we cannot know what is the effect of these kinds of policies and tactics of Hun Sen to get popularity," Mr. Saray said.

"We will see in 2017 what happens. If they win in 2017, they will continue on until the 2018 national election, but if they do not win in 2017, there could be some problems for the 2018 election," he explained.

"We don't know whether the 2018 election will go ahead smoothly. That is the concern we have."

Either way, But Buntenh, a well-known Buddhist monk who leads the Independent Monk Network for Social Justice, said that he believed it was too late for the CPP to convince people its reforms would be meaningful.

"In terms of regime survival, they have to reform but I don't think they can reform because they have the same people. Through my observations, the CPP uses the word 'reform,' but it's a diversion," the monk said.

"The Cambodian people are beating the drum-'boom, boom, boom'-but Hun Sen's group are sleeping. It's going 'Boom, boom, boom: We need democracy,' but they are all still asleep," he said.

willemyns@cambodiadaily.com, naren@cambodiadaily.com

## តមកពីទំព័រទី ២០ សម្រាប់របៀបវារៈគណបក្សប្រជាជន...

ដឹងច្បាស់ថាតើយុទ្ធសាស្ត្រនៃកំណែទម្រង់បន្តិចម្ដងៗ និងការទាក់ទងតាមបណ្ដាញទំនាក់ទំនងសង្គមមានប្រសិទ្ធភាពឬយ៉ាងណាទេ ប៉ុន្តែបានមានប្រសាសន៍ថា ការបោះឆ្នោតឃុំសង្កាត់នាឆ្នាំ២០១៧ទំនងជាលាតត្រដាងនូវចម្លើយទៅនឹងសំណួរនោះ។

លោក ធន់ សារ៉ាយ បានមានប្រសាសន៍ថា "តាមធម្មតានៅក្នុងសង្គមប្រជាធិបតេយ្យ គេស្ទង់មតិប្រជាពលរដ្ឋ ប៉ុន្តែឥឡូវនេះគេមិនអាចដឹងថា តើមានប្រសិទ្ធភាពដូចម្ដេចចំពោះគោលនយោបាយ និងយុទ្ធវិធីរបស់ ហ៊ុន សែន ដើម្បីទទួលបានប្រជាប្រិយភាពនោះទេ"។

ប្រធានអង្គការសិទ្ធិមនុស្សរូបនេះបានពន្យល់ថា "យើងនឹងឃើញក្នុងឆ្នាំ២០១៧ថា អ្វីនឹងកើតឡើង។ ប្រសិនបើគេឈ្នះឆ្នោតក្នុងឆ្នាំ២០១៧ គេនឹងបន្តរហូតដល់ការបោះឆ្នោតជាតិឆ្នាំ២០១៨ ប៉ុន្តែប្រសិនបើគេមិនឈ្នះឆ្នោតក្នុងឆ្នាំ២០១៧ទេ អាចនឹងមានបញ្ហាខ្លះសម្រាប់ការបោះឆ្នោតនាឆ្នាំ២០១៨។ យើងមិនដឹងថា តើការបោះឆ្នោតនាឆ្នាំ២០១៨ នឹងមានដំណើរការទៅដោយស្រួលបួល ឬយ៉ាងណាទេ។ នោះជាកង្វល់ដែលយើងមាន"។

ទោះជាយ៉ាងនេះក្ដី ព្រះតេជគុណ ប៊ុត ប៊ុនទិញ ដែលដឹកនាំបណ្ដាញព្រះសង្ឃឯករាជ្យដើម្បីយុត្តិធម៌សង្គម បានមានសង្ឃដីកាថា ព្រះតេជគុណជឿជាក់ថា វាជ្រុលពេលទៅហើយសម្រាប់គណបក្សប្រជាជនកម្ពុជាមិនអាចបញ្ចុះបញ្ចូលប្រជាពលរដ្ឋឱ្យជឿថា កំណែទម្រង់របស់ខ្លួនមានន័យនោះទេ។

ព្រះតេជគុណ ប៊ុត ប៊ុនទិញ បានមានសង្ឃដីកាថា "ទាក់ទងនឹងការរស់រានរបស់របបនេះ គេត្រូវកែទម្រង់ ប៉ុន្តែអាត្មាមិនគិតថា គេអាចកែទម្រង់បានទេ ពីព្រោះគេមានមនុស្សដដែលៗ។ តាមរយៈការអង្កេតរបស់អាត្មាគណបក្សប្រជាជនកម្ពុជាប្រើពាក្យកំណែទម្រង់ ប៉ុន្តែជាការបង្វែរទៅវិញ"។

ព្រះតេជគុណអង្គនេះបានមានសង្ឃដីកាថា "ប្រជាពលរដ្ឋខ្មែរកំពុងតែវាយស្គរ ទូង ទូង ទូង! ប៉ុន្តែក្រុម ហ៊ុន សែន កំពុងតែដេកលង់លក់។ ទូង ទូង ទូង! យើងត្រូវការលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែពួកគេនៅតែដេកលង់លក់ដដែល"៕ **រីន**




Continued from page 17

## KERRY STRESSES SECURITY AND...

who at- tended the meeting with Mr. Kerry, said the discussion was longer than he expected, "but still very short and also short on substance."

Mr. Kerry's Twitter account kept a running diary of his events during the day, including a morning visit to the National Museum, but notably omitted his meeting with opposition officials. In his meeting with government leaders, he wrote that he "Discussed economic & ASEAN issues, strengthening democracy & bilateral relationship."

The secretary of state, who visited Cambodia numerous times as a U.S. senator in the 1990s, noted during his afternoon address the country's rapid development since he was last here and the desire of the U.S. to strengthen economic relations.

"The progress you have made in Cambodia is quite remarkable," he said. "When I first came here, this was a city of 350,000 people and a very war-torn econo my, [and it] is now a city of 2.2 million people with a very modern hospital, sky-scrapers, enormous energy and many, many tourists."

Mr. Kerry said it was "actually quite remarkable" that the U.S. remained Cambodia's top export market.

"And we will continue to explore ways to deepen our trade and investment relationship including by helping to tackle corruption and exploring ways to strengthen Cambodia's legal institutions," he said.

Unlike former U.S. Secretary of State Hillary Clinton, who hosted a pub-lic discussion with hundreds of students during her visit to Cambodia in 2010, Mr. Kerry did not avail himself to any public questions, and his meetings were closed to the press.

Mr. Namhong, the foreign minister, also highlighted the importance of coop-eration in the fight against I.S. in remarks following his meeting with Mr. Kerry.

"I do not believe that clearing I.S. can be done by one country or one country's military," he said. "Because of the cruel action of the [I.S.], it is not a threat for only Iraq and Syria, but it is in Africa and Asia, too."

And despite the tension between the U.S. and China over claims in the South China Sea, and wider competition between the superpowers for influence in the region, Mr. Namhong said Mr. Kerry did not push Cambodia on issues related to China.

"His Excellency John Kerry also said that he did not ask Cambodia to support America or support China," he said. "I explained to him that in fact, Cambodia is a small country and it is [a] poor country, but we are independent."

Cambodia has come under heavy criticism for being perceived as siding with China in its territorial disputes with a number of Asean countries in the South China Sea.

During Mr. Kerry's discussion with Mr. Hun Sen, the prime minister requested continued U.S. support in the "health sector, education section, mine clearing," according to his personal assistant, Eang Sophalleth, who briefed reporters after the meeting.

Mr. Hun Sen also expressed his desire for the U.S. to consider "letting Cambodia export goods to the U.S. with-out quotas or tax, factors that will help to push Cambodia's development," Mr. Sophalleth said.

## តមកពីទំព័រទី ០២ វេទិកាអាជីវកម្មខ្នាតតូចសហគមន៍

នៅមុននឹងបិទបញ្ចប់វេទិកានេះ អ្នកសម្របសម្រួលបានជូនដំណឹងអំពីវេទិកាប្រកួតគំនិតអាជីវកម្ម ឬ Pitch Contest ដែលនឹងធ្វើឡើងនៅថ្ងៃពុធ ទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ នៅឯភោជនីយដ្ឋាន សាន់នីដា វេលាម៉ោង៦ ដល់៨ យប់។ វេទិកាប្រកួតគំនិតអាជីវកម្មនេះ រៀបចំឡើងដោយសមាគមខ្មែរ និងអង្គការ EforAll។ នៅក្នុងវេទិកានោះនឹងមានចៅក្រមចំនួនប្រាំរូបដើម្បីផ្ដល់ពិន្ទុដល់បេក្ខជនដែលមានបំណងប្រកួតគំនិតអាជីវកម្មរបស់ខ្លួន។ បេក្ខជនដែលធ្វើបានល្អនឹងទទួលបានប្រាក់រង្វាន់ភ្លាមៗរហូតដល់១,៥០០ដុល្លារ។ ដើម្បីជ្រាបបន្ថែមអំពីលក្ខខណ្ឌនៃការចូលរួមប្រកួត និងរបៀបបំពេញពាក្យ សូមទូរស័ព្ទទៅសមាគមខ្មែរតាមរយៈលេខ ៩៧៨-៤៥៤-៦២០០ លេខបន្ត១០១៨ រៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃ ចន្ទ ដល់ ថ្ងៃ សុក្រ ម៉ោង ៩ព្រឹក ដល់ម៉ោង ៥ ល្ងាច ឬ សរសេរអ៊ីម៉ែលទៅកាន់ nmuong@cmaalowell.org។



BBB

# ToyStore AUTO SALES

67 South Broadway, Salem, NH 03079
Tel: (603) 893 – 2253 | Fax: (603) 893 - 5324
Exit 1 OFF 93, left onto Rte 28 North. ¼ mile on left.

To view our entire Inventory visit us at www.ToyStoreAutoSales.net
Buy-Sell-Repair



1) 2009 Subaru Impreza WRX five-speed in rare pearl white please call for details
2) 2012 Acura TL SH-AWD with Tech Package, excellent condition, heated leather, Navigation, fully loaded with options, $22,995
3) 2009 Toyota Rav4 Limited, 4x4, Heated leather seats, JBL stereo, low miles $17,995
4) 2011 Honda Civic Si Sedan, 6 speed manual, Sunroof, alloys, 2 to choose from starting at $12,995

**Family own since 1958**
**Financing for everybody**

**Hours of Operation:**

| | |
|---|---|
| MON-THURS: | 9am till 7pm |
| FRIDAY: | 9am till 6pm |
| SATURDAY: | 9am till 6pm |
| SUNDAY | 10am till 5pm |

# SAVINGS WITH MASS APPEAL

DRIVERS WHO SWITCHED SAVED
$498
NATIONAL ANNUAL AVERAGE

**Want to save on car insurance? Call me first.**

It's time Massachusetts drivers had a better car insurance experience. I'll help you get the coverage that's right for you and the discounts you deserve. Call me today.



**Vanessa Dinh**
**781-547-6522**
665 Main Street
Waltham
vanessadinh@allstate.com

Allstate. You're in good hands.

Savings based on national customer-reported data for new policies in 2012. Actual savings vary. Allstate Insurance Co. Northbrook, IL. © 2013 Allstate Insurance Co.

# AccuCare Home Care Agency

Group Adults Foster Care Program

## កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិន ចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។

ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :
- រស់នៅផ្ទះរដ្ឋ
  អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

ផលប្រយោជន៍ទទួលបាន :
- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

***To be eligibled for GAFC you must:***
- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***
- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed**
**for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

## NOTICE OF PUBLIC MEETING

The Northern Middlesex Metropolitan Planning Organization (NMMPO) will meet at 2:30 P.M.on Wednesday January 27th, 2016 at the Northern Middlesex Council of Governments office, 40 Church Street, Suite 200, in Lowell. The NMMPO will discussand vote to release several amendments to the FFY 2016-2019 Transportation Improvement Program (TIP)for 30 day public comment.

Notice: This location is accessible to people with disabilities and is near public transportation. NMCOG offers secure bicycle parking on the second floor. The NMMPO provides reasonable accommodations and/or language assistance, free of charge, upon request (including, but not limited to, interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext 121 or at jhoward@nmcog.org . Requests should be made as soon as possible for services requiring advanced arrangements, including sign-language, CART or language translation or interpretation.

## ជូនដំណឹងសាធារណៈ ពីកិច្ចប្រជុំ

អង្គការផែនការទីក្រុងនៃសង្កាត់មីឌុលសិចខាងជើង (The Northern Middlesex Metropolitan Planning Organization ) នឹងជួបប្រជុំនៅម៉ោង២:៣០នាទីថ្ងៃត្រង់ ចំថ្ងៃពុធ ទី២៧ ខែមករា ឆ្នាំ២០១៦ នៅឯការិយាល័យក្រុមប្រឹក្សារដ្ឋាភិបាលមិឌុលសិចខាងជើង Northern Middlesex Council of Governments office ដែលមានអាស័យដ្ឋាននៅ ផ្លូវ៤០ឈើច៤0 Church Street បន្ទប់២00 នៅក្នុងទីក្រុងឡូវែល។ អង្គការ នឹងពិភាក្សានឹងអនុម័តបញ្ចេញនូវវិសោធនកម្មមួយចំនួនធធូ២០១៦-១៩ស្តីអំពី "កម្មវិធីបង្កើនគុណភាពដឹកជញ្ជូនពង្រឹងមានរយៈពេល៣០ថ្ងៃ។ ដែលមានពេល៣០ថ្ងៃសម្រាប់ប្រជាពលរដ្ឋធ្វើអត្ថាធិប្បាយ។

**កំណត់ចំណាំ:** ទីតាំងនោះ គឺមានភាពងាយស្រួលសំរាប់ជនពិការ ជាពិសេសគឺវាស្ថិតនៅជិតយានដឹកអ្នកដំនើរសាធារណ:។ ការិយាល័យក្រុមប្រឹក្សារដ្ឋាភិបាល (NMCOG) ក៏មានផ្តល់នូវចំណតកង់ដ៏មានសុវត្ថិភាពមួយនៅឯជាន់ទីពីរ។ ចំណែកឯអង្គការផែនការទីក្រុងមីឌុលរទមួងសិចខាងជើង (NMMPO) គឺផ្តល់នូវកន្លែងស្នាក់អាស្រ័យដ៏សមរម្យនឹងជំនួយការផ្ទែកភាសាដោយមិនគិតថ្លៃ(រួមបញ្ចូល ប៉ុន្តែមិនមានកំណត់ចំពោះតែអ្នកបកប្រែភាសាកាយវិការជាភាសាអាមេរិកាំងនឹងភាសាកាយវិការផ្សេងៗទៀត ហើយ និងមានការបើក រឺក៏បិទនូវចំណងជើងសម្រាប់វីដេអូរបស់ជំនួយការស្តាប់ និងសម្ភារ:ជំនួសផ្សេងៗទៀត) យោងទៅតាមការស្នើរសុំដែលអាចធ្វើបាន។ បើសិនជាត្រូវការជំនួយសូមមេត្តាទាក់ទងលោកចស់ស្ទីនហូរវដ (Justin Howard) តាមរយៈលេខទូរស័ព្ទ 978 454 8021 ខេត 121 រឺក៏តាមរយ:អ៊ីម៉ែល jhoward@nmcog.org។ ការស្នើរសុំគួរតែស្នើរកាន់តែឆាប់កាន់តែល្អពីព្រោះសេវាកម្មត្រូវការពេលរៀបចំទុកជាមុនដូចជាភាសាកាយវិការ រទេះរុញ ការបកប្រែជាលាយលក្ខអក្សរ ឬក៏ការបកប្រែផ្ទាល់មាត់៕

# ខេមរា ខៃ រៃអង្គាសលុយបោះឆ្នោត

**ដោយៈខ្មែរផុសស.រ.អា.**

ភ្ញៀវប្រមាណ១៥០នាក់ បានអញ្ជើញមកចូលរួម"រាត្រីរអង្គាស" រកថវិការទៅបោះឆ្នោតតំណាងរដ្ឋដែលនឹងប្រព្រឹត្តទៅនៅចុងឆ្នាំ២០១៦នេះ។ បេក្ខជងខ្មែរជាច្រើនបានចេញមកឈរឈ្មោះជាតំណាងសហគមន៍ខ្លួន នា២-៣ឆ្នាំចុងក្រោយនេះ តែមិនមាននរណាបានជាប់ឈ្មោះក្រៅពីលោក រ៉ាឌី ម៉ម កាលពីឆ្នាំមុននោះទេ ។ មុននេះបន្តិច មានលោក វ៉ាស្នា នួន បានជាប់ជាសមាជិកក្រុមប្រឹក្សាក្រុង បានមួយអាណត្តិដែរ។

ដោយសារលោក រ៉ាឌី ម៉ម បានភ្លាត់ស្នៀតនៅពេលលោកជាប់ឆ្នោតហើយចេញទៅគួរសមជាមួយរដ្ឋាភិបាលភ្នំពេញលោកក៏បានទទួលនូវការទិទានដ៏សន្ធឹកសន្ធាប់ពីម្ចាស់ឆ្នោត ហេតុដូច្នេះហើយ លោក ខេមារា ខៃ មកពីគណបក្សសាធារណរដ្ឋមានសង្ឃឹមច្រើននឹងប្រកួតជាមួយសមាជិកគណបក្សប្រជាធិបតេយ្យក្នុងតំបន់ឡូវែលនេះបាន។

ក្នុងពេលផ្តើមរៃអង្គាសរកធនធានសម្រាប់ធ្វើការឃោសនានៅមណ្ឌល"មីឌុលសិក១៨" ដែលមានខ្មែរច្រើនរស់នៅគេមិនទាន់ដឹងនៅឡើយថា នឹងមានបេក្ខជនខ្មែរឬសាស្ត្រដ៏ទៃទៀតចេញមកប្រកួតប្រជែងយ៉ាងណានៅឡើយទេ តែប្រាកដជានឹងមានព្រឹត្តិការណ៍គួរឱ្យចង់តាមដានការប្រកួតប្រជែងជាមិនខានឡើយ៕


ខេមារា ខៃ


វាសនា នួន ខេមារា ខៃ រិទ្ធី អ៊ុង




ក្រុមគ្រួសារ លោក ខេមារា ខៃ



# ឧទ្យានជាតិ ភ្នំគូលែន





ឧទ្យានជាតិភ្នំគូលែនស្ថិតនៅប៉ែកខាងជើងឆៀងខាងកើតទីរួមខេត្តសៀមរាបមានចំងាយ៥៣គីឡូម៉ែត្រពីទីរួមខេត្តភ្នំនេះមានរយៈកំពស់៤៩២ម៉ែត្រ គេអាចឡើងទៅលើភ្នំបានយ៉ាងងាយតាមរថយន្ត រឺថ្មើរជើងពេលទៅដល់ជើងភ្នំយើងសង្កេតឃើញផ្ទាំងថ្មធំ ហាក់ដូចជាជញ្ជាំងនៃនាវាដ៏ធំមួយនៅកណ្តាលទីស្មសានរំលេចដោយសំរស់ស្រស់ត្រកាល និងបង្កប់នូវអាថិកំបាំងដ៏សន្ធឹកសន្ធាប់នាអតីតកាលសម័យអង្គរដែលជារមណីយដ្ឋានមួយក្នុងចំណោមរមណីយដ្ឋានជាច្រើននៅ ខេត្តសៀមរាប។ ជួរភ្នំនេះចែក ជាពីរ ៖

□ប៉ែកខាងកើតនិងខាងត្បូងហៅថាភ្នំគូលែន។

□ប៉ែកខាងជើងនិង ខាងលិចហៅថាភ្នំហាប់។ រមណីយដ្ឋានភ្នំគូលែនស្ថិតនៅ ឃុំខ្នងភ្នំ ស្រុកស្វាយលើខេត្តសៀមរាប។

បច្ចុប្បន្នដោយប្រទេសជាតិទទួលបាននូវសន្តិភាព ស្ថេរភាព និង សន្តិសុខគ្រប់គ្រាន់ ហើយនោះ រមណីយដ្ឋានភ្នំគូលែនបានទទួលស្វាគមន៏ភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើន ជារៀងរាល់ថ្ងៃ និងមានប្រជាពលរដ្ឋមកពីទីជិតទីឆ្ងាយៗ តាំងលំនៅដ្ឋានប្រកបអាជីវកម្មកសិកម្មយ៉ាងច្រើនកុះករ។

ភ្នំគូលែនមានរមណីយដ្ឋានធម្មជាតិ និងប្រវត្តិសាស្ត្រជាច្រើនដូចជា៖ តំបន់ទឹកធ្លាក់, ព្រះអង្គធំ,វាលស្តេចលំគង់,វាលព្រះសព,ព្រះក្រាល,សំពៅធ្លុយ និងមានប្រាសាទតូចៗ ធ្វើអំពីឥដ្ឋជាច្រើនទៀតដែលជាកេរ្តិ៍តំណែលស្នាព្រះហស្តព្រះបាទជ័យវរ្ម័ទី២បានកសាងឡើង។

តំបន់ភ្នំគូលែនមិនត្រឹមតែជាតំបន់ទេសចរតែប៉ុណ្ណោះទេគឺជាតំបន់កសិកម្មដីមានជីវជាតិអាចដាំដំណាំបានគ្រប់ប្រភេទដូចជា៖ ចេក- ខ្នុរ- ដំឡូង- ត្រាវ។ល។ ប្រកបដោយផលិតផលខ្ពស់។ ក្នុងភូមិសាស្ត្រតំបន់ភ្នំគូលែននៅមានប្រាសាទជាច្រើនទៀតជា ប្រាសាទតូចៗ ធ្វើអំពីឥដ្ឋព្រោះទីនោះនាអតីតកាលមានស្តេចមួយអង្គព្រះនាម ជ័យវរ្ម័ទី២ បាននៅតាំងធានីនៅ ហើយបានបន្សល់ទុកកេរ្តិ៍តំណែលដ៏ច្រើនរហូតមកដល់សព្វថ្ងៃ។

រមណីដ្ឋានធម្មជាតិប្រកបដោយកេរ្តិ៍តំណែលដ៏ត្រកាលនេះ បានទាក់ទាញ និងប្រែក្លាយជាតំបន់ទេសចរណ៏មួយដ៏ប្រណិតរបស់ខេត្តសៀមរាប។ ដោយហេតុថា ភ្នំនេះ សំបូរដោយដើមគូលែន នោះទើបភ្នំនេះគេឱ្យឈ្មោះថា "ភ្នំគូលែន" ៕

អត្ថបទដកស្រង់ពី :CEN













# ទូលព្រះបង្គំមិនហ៊ានរាយការណ៍ទេ ទាន ! (ភាគ៦)

**តពីលេខមុន**

ម៉េចក៏ទូលបង្គំថ្លើមធំហ៊ានពោលថា ទូលបង្គំដឹងច្បាស់ថាព្រះអង្គមិនបានទ្រង់ជ្រាបនូវរឿងរ៉ាវទាំងឡាយដែលទូលបង្គំដឹង ព្រោះព្រះអង្គធ្លាប់តែទ្រង់ជ្រាបថា ព្រះអង្គបានជ្រាបនូវរឿងរ៉ាវទាំងឡាយដែលយើងខ្ញុំនឹងសត្វនិករទាំងឡាយមិបានដឹង។ ដំបូងព្រះអង្គចង់កាត់ក្បាលទូលបង្គំដោយទូលបង្គំហ៊ាននិយាយរឿងពីតថា ព្រះអង្គមិនបានជ្រាបនូវរឿងដែលទូលបង្គំដឹងនោះជាការព្រហឹន,ប្រមាទព្រះចេស្តារ...សូមព្រះអង្គទ្រង់ជ្រាបថា នេះជារឿងដែលព្រះអង្គមិនបានទ្រង់ជ្រាបមួយស្រេចទៅហើយ!...ព្រោះព្រះអង្គអើយ! នៅឯភពផែនដីគេឈប់ឱ្យមានទម្ងន់ទោសកាត់កប្រហារជីវិតនេះសឹងគ្រប់នគរទៅហើយ, ព្រះអង្គទ្រង់ជ្រាបទេថា នគរគោគធ្លកជាប្រទេសមួយដែលគេតិះដៀលថាជាប្រទេសខ្វះសេរីភាព, គ្មានប្រជាធិបតេយ្យ,រំលោភសិទ្ធិមនុស្ស។ល។ ក៏គេគង់មានច្បាប់អប់រំមនុស្សមិនឱ្យមានទម្ងន់ទោសដល់ថ្នាក់ប្រហាជីវិតទៅហើយ! បើត្រូវសម្លាប់ គឺរដ្ឋាភិបាលគេលួចចាប់ទៅសម្លាប់ចោលស្ងាត់ៗតែម្តងមិនចាំបាច់កាត់ទោស,នាំអស់សោហ៊ុយជួលតុលាការ ឬក៏គេបាញ់ចោលត្រង់ៗតែម្តងមិនបាច់ជាប់ពាក្យថាតុលាការកាត់ទោសប្រហាជីវិតដូចជាក្នុងបាតុកម្មគេបាញ់កម្មករវាយក្បាលលោកសង្ឃជាដើម តើព្រះអង្គទ្រង់ជ្រាបរឿងទាំងនេះទេ?... តើព្រះអង្គទ្រង់ទតឃើញទេនឹងជ្រាបថាហេតុអីទូលបង្គំហ៊ានមកសារណាការជាមួយព្រះសក្កទេវរាជដោយគ្មានសុព័បាទទាំងគូហើយស្លៀកដណ្តប់ដោយសំពត់អាវស្បែកញ្ញាស់ព្រមទាំងមានស្នាមប៉ះនេះឬទេ? ទូលបង្គំជឿជាក់ក្នុងចិត្តថា ព្រះអង្គមិនទ្រង់ជ្រាបឡើយថាហេតុអីទេវតាឯទៀតសុទ្ធតែគ្របដណ្តប់ដោយសំពត់អាវស្បែភ្លឺចាំងផ្លេកៗបន្ទេចដោយពេជ្រដោយនិលសុព័របាតសុទ្ធតែមាស ដាំពេជ្រ, ដាំត្បូង ឯទូលបង្គំគ្មានទាំងសុព័របាតផង ហ៊ានទិញសំបុត្រយានអាវកាសតាមតម្លៃម៉ាក្សេណ្ឌរមក ធ្វើអីនឹងគេដែរ? ព្រះអង្គទ្រង់មានចម្ងល់ឬទេ?"។

ទេពអគ្គលេខាធិការទតសង្កេតយ៉ាងយកព្រះទ័យទុកដាក់ចំពោះទេវតាអង្គនេះជាលើកដំបូងដែលព្រះង្គហាក់មិនដែលធ្លាប់សង្កេតពិនិត្យយ៉ាងនេះម្តងណាសោះឡើយ។ ក្នុងដួងហឬទ័យរបស់ព្រះអង្គកំពុងតែនឹកឃើញរឿងអ្វីមួយស្រពេចស្រពិលមិនច្បាស់ទេវតាអង្គនេះជាទេវតាតំណាងមកពីក្រុងទេពមហាណាក់ខនទៅវិញ ហើយមកតាំងទីនៅប្រាសាទព្រះវិហាដើម្បីអភិរក្សប្រាសាទនានាលើប្រទៃប្រទេសនៃនគរគោកធ្លកទៅវិញ? វាម៉េចចឹងទៅវិញ? ធម្មតាត្រូវតាំងទីនៅឯរាជធានីអង្គរ ឬយ៉ាងហោចណាស់ក៏ត្រូវនៅឯក្រុងចតុមុខទើបត្រូវ។ ព្រះអង្គមិនព្រមចោទសួរទេវតាអង្គនេះឱ្យបកស្រាយនូវចំងល់នេះថ្វាយព្រះអង្គទេ ព្រោះហាក់ដូចមានរឿងអ្វីអាថិកំបាំងផ្សេងទៀតបង្កប់នៅក្នុងទេវតាអង្គនេះ។ គេនេះជានរណាឱ្យពិតប្រាកដទៅអេះ? អាត្មាអញហាក់ដូចចាំច្បាស់ថា គេនេះធ្លាប់មានរូបរាងសង្ហា, ឬកពាអង់អាច, ហានក្លា, ភ្នែកមុត, សំដីម៉ឺងម៉ាត់តែពីរោះពេលបញ្ចេញវាចារម្តងៗអង្គប្រជុំតែងស្ងាត់ជ្រាប...។ ឥឡូវនេះគេមែនជាទេវតាអង្គណឹងឬទេ? ម៉េចក៏ឬកពារខាងក្រៅមិនដូចពីមុនសោះអញ្ចឹង? ការស្លៀកពាក់គ្របដណ្តប់សំពត់អាវស្បែដូចជាទេវតាជាប់ពិរុទ្ធះពិរុទ្ធជនទេវះឬយ៉ាងណាអញ្ចេះ?...ជាទេវតាបែបជា...ដោយខំកកាយរក, ត្រិះរិះក្នុងខួរក្បាលសឹងតែហុយផ្សែងព្រះអង្គកាត់មិនយល់សោះក៏ទ្រង់យាងចេញពីអាសនៈ ហើយចុះមកកាន់ទេវតាទាំងឡាយនោះដោយព្រះនេត្រទាំងគូរបស់ទ្រង់សម្លឹងចំទៅរកគ្រប់ទេវតាទាំងឡាយម្តងមួយព្រះអង្គៗ។



**តទៅលេខក្រោយ**

# ត្រីអាចជួយបន្ថយ ហានិភ័យ នៃជំងឺភ្លេចភ្លាំង



តាមការស្រាវជ្រាវថ្មីចុងក្រោយមួយលើកឡើងថា ទទួលទានសាច់ត្រី ក៏ដូចជាអាហារផ្សេងទៀតដែលមានផ្ទុកសារធាតុអាស៊ីដខ្លាញ់អូមេហ្គាពអាចជួយកាត់បន្ថយការប្រឈមនឹងការកើតជំងឺភ្លេចភ្លាំងបាន ។

អ្នកវិទ្យាសាស្ត្របានពិសោធន៍ឃើញថា សារធាតុខ្លាញ់នោះដែលប្រឆាំងនឹងការរលាកមានសមត្ថភាពកាត់បន្ថយកម្រិតប្រូតេអ៊ីនក្នុងឈាមមួយប្រភេទដែលបង្កទៅជាជំងឺភ្លេចភ្លាំង ។ ក្នុងការស្រាវជ្រាវលើកនេះអ្នកវិទ្យាសាស្ត្រអាមេរិកបានពិសោធន៏លើមនុស្សវ័យ៦៥ឆ្នាំចំនួន១២១៩នាក់ ។ ជាលទ្ធផលបានបង្ហាញថាកម្រិតប្រូតេអ៊ីនធ្វើឱ្យមនុស្សភ្លេចភ្លាំងឈ្មោះ Beta-amyloid នៅក្នុងខួរក្បាលរបស់ពួកគេបានថយចុះគួរឱ្យកត់សម្គាល់នៅពេលមានការប្រើប្រាស់អាហារដែលមានផ្ទុកអាស៊ីដខ្លាញ់អូមេហ្គាពច្រើន ។ តាមការពិសោធន៍បើប្រើប្រាស់អាស៊ីដខ្លាញ់អូមេហ្គាពប្រចាំថ្ងៃចំនួន១ក្រាមអាចកាត់បន្ថយប្រូតេអ៊ីន Beta-amyloid បានពី ២០ ទៅ៣០ភាគរយ ។

អ្នកដឹកនាំការស្រាវជ្រាវវេជ្ជបណ្ឌិតនីកូឡូស ស្កាមៀស មកពីសាកលវិទ្យាល័យសុខាភិបាលកូឡុំប៊ីនៅទីក្រុងញូវយ៉កសហរដ្ឋ-អាមេរិកបាននិយាយថា ខណៈវាមិនងាយស្រួលក្នុងការវាស់កម្រិតប្រូតេអ៊ីន Beta-amyloid ក្នុងខួរក្បាលតែវាងាយស្រួលក្នុងការវាស់កម្រិតរបស់វានៅក្នុងឈាម ។ លទ្ធផលនៃការរកឃើញលើកនេះអាចពង្រឹងជាកម្លាំងដល់ជំនឿចិត្តរបស់យើងលើប្រសិទ្ធភាពអាហារប្រចាំថ្ងៃដែលអាចទប់ស្កាត់ជំងឺភ្លេចភ្លាំង ។

នៅក្នុងការពិសោធន៍សារធាតុចិញ្ចឹមផ្សេងទៀតក្រៅពីអាស៊ីដអូមេហ្គាពមិនជាប់ទាក់ទងគ្នាជាមួយនឹងកម្រិតខុសៗគ្នានៃប្រូតេអ៊ីន Beta-amyloid ក្នុងឈាមទេ ។ សារធាតុអាស៊ីដខ្លាញ់អូមេហ្គាពមានច្រើនបំផុតនៅក្នុងត្រីដែលសំបូរខ្លាញ់តួយ៉ាង ដូចជាត្រី សូម៉ុង ត្រីសាឌីនធំ និងត្រីស្បែកាជាដើម ។ ចំណែកនៅក្នុងពពួកសណ្តែក និងបន្លែមួយចំនួនដូចជា ស្ពៃក្តោបតូច ស្ពៃក្តោបម្យ៉ាង ក៏មានដែរ តែក្នុងបរិមាណតិចតួច ៕



# ស្ងោរមាន់ទឹកដូង

**+គ្រឿងផ្សំ**

- មាន់
- ដូងទុំ
- ការ៉ុត
- អំបិល ស្ករ ប៊ីចេង ជុំស៊ុបខ្នរ

**+វិធីធ្វើ**

មុនដំបូងលោកអ្នកគ្រាន់តែយកមាន់មកលាងឱ្យស្អាត ដាក់ស្រុះក្នុងទឹកក្តៅ ហើយកោសសម្បកការ៉ុតចេញ លាងទឹកឱ្យស្អាតកាត់ជាដុំធំៗ និងយកសាច់ដូងទុំហាន់ជាបន្ទះធំៗទុក ។ បន្ទាប់មកដាំទឹកឱ្យពុះ រួចដាក់គ្រឿងផ្សំចូលទាំងអស់ ហើយស្ងោររំងាស់ទាល់តែពុះ ទើបបន្ថយភ្លើង និងស្ងោររំងាស់បន្ថែមរយៈពេល៣ម៉ោង ទើបចាក់គ្រឿងផ្សំរសជាតិចូលជាការស្រេច ។

## តមកពីទំព័រទី ១៧ លោក ចន ឃើរី សង្កត់ធ្ងន់លើបញ្ហា...

លោកបានថ្លែងថា "ខ្ញុំបានបញ្ជាក់យ៉ាងច្បាស់ផងដែរ នៅក្នុងជំនួបរបស់ខ្ញុំនៅថ្ងៃនេះថា វាជាក្តីសង្ឃឹមរបស់យើង ហើយខ្ញុំគិតថា វាជាក្តីសង្ឃឹមរបស់ពិភពលោកដែលប្រទេសកម្ពុជានឹងដឹងច្បាស់ពីផលប្រយោជន៍ពេញលេញនៃប្រទេសប្រជាធិបតេយ្យពហុបក្សនិងរីកចម្រើន" ។

លោកបានបន្ថែមថា "យើងយកចិត្តទុកដាក់យ៉ាងខ្លាំងអំពីការគោរពសិទ្ធិមនុស្សសេរីភាពជាសាកល និងអភិបាលកិច្ចល្អ។ ហើយវឌ្ឍនភាពនៅក្នុងវិស័យនីមួយៗក្នុងចំណោមវិស័យទាំងនេះពិតជាសំខាន់ក្នុងការអាចបំពេញតាមសក្តានុពលនៃទំនាក់ទំនងទ្វេភាគីរបស់យើង ប៉ុន្តែសំខាន់ដែរនោះ សក្តានុពលពេញលេញនៃក្តីសង្ឃឹម និងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា" ។

ទីភ្នាក់ងារព័ត៌មានរដ្ឋរបស់កម្ពុជា AKP បានដកស្រង់ចំណុចផ្សេងៗគ្នានៃការពិភាក្សារបស់លោក ចន ឃើរី ជាមួយលោកនាយករដ្ឋមន្ត្រីដោយលើកឡើងជាសាធារណៈអំពីការពិតដែលថា សិទ្ធិមនុស្សមិនត្រូវបានលើកឡើងនៅក្នុងអត្ថបទមួយចុះផ្សាយនៅក្នុងគេហទំព័ររបស់ខ្លួនដែលមានចំណងជើងថា "មិនមានការលើកឡើងពីបញ្ហាសិទ្ធិមនុស្សអំឡុងការពិភាក្សារវាងនាយករដ្ឋមន្ត្រីកម្ពុជា និងរដ្ឋមន្ត្រីការបរទេសអាមេរិក" ។

នៅក្នុងការសំដៅចំៗដល់ការវាយដំលើតំណាងរាស្ត្រគណបក្សប្រឆាំងកាលពីខែតុលា



គឺលោក ញូយ ចំរើន និងលោក គង់ សភា លោក ចន ឃើរី បានថ្លែងថា ការធានាសុវត្ថិភាពរបស់តំណាងរាស្ត្រជា "ការទទួលខុសត្រូវសំខាន់" របស់រដ្ឋាភិបាល។

លោកបានថ្លែងថា "រដ្ឋាភិបាលប្រជាធិបតេយ្យមានការទទួលខុសត្រូវធានាថា តំណាងរាស្ត្រជាប់ឆ្នោតទាំងអស់មានសេរីភាពក្នុងការបំពេញការងាររបស់ខ្លួនដោយគ្មានការភ័យខ្លាចពីការវាយប្រហារ ឬការចាប់ខ្លួន" ។

នៅពេលរសៀលផងដែរ លោក ចន ឃើរី បានជួបជាមួយគណៈប្រតិភូមន្ត្រីជាន់ខ្ពស់គណបក្សប្រឆាំងរួមមានលោក កឹម សុខា អនុប្រធានគណបក្សប្រឆាំង ហើយមានជំនួបដាច់ដោយឡែកជាមួយមេដឹកនាំសង្គមស៊ីវិលផងដែរ ។

លោកបានថ្លែងថា "នៅគ្រប់ជំនួបទាំងនោះ ខ្ញុំបានបញ្ជាក់ច្បាស់ថា យើងមានការប្តេជ្ញាចិត្ត យើងសហរដ្ឋអាមេរិកមានការប្តេជ្ញាចិត្តចំពោះទំនាក់ទំនងរវាងប្រទេសរបស់យើង និងប្រទេសកម្ពុជា" ។

នៅក្នុងសារបង្ហោះក្នុងទំព័រហ្វេសប៊ុក លោក អ៊ូ វីរៈ ស្ថាបនិកវេទិកាអនាគតដែលបានចូលរួមក្នុងជំនួបជាមួយលោក ចន ឃើរី ដែរ បានមានប្រសាសន៍ថា ការពិភាក្សាយូរជាងការរំពឹងទុករបស់លោក ប៉ុន្តែមានការពិភាក្សាពីខ្លឹមសារខ្លីៗប៉ុណ្ណោះ" ។

គណនីទ្វីតទ័ររបស់លោក ចន ឃើរី បានរៀបរាប់ពីកំណត់ប្រចាំថ្ងៃនៃព្រឹត្តិការណ៍របស់លោកអំឡុងថ្ងៃនោះ រួមទាំងដំណើរទស្សនកិច្ចនៅពេលព្រឹកទៅកាន់សារមន្ទីរជាតិផងដែរ ប៉ុន្តែគួរឱ្យកត់សម្គាល់មិនបានរាប់បញ្ចូលជំនួបរបស់លោកជាមួយមន្ត្រីគណបក្សប្រឆាំងទេ។ នៅក្នុងជំនួបជាមួយមេដឹកនាំរដ្ឋាភិបាលលោកបានសរសេរថា លោកបាន "ពិភាក្សាអំពីបញ្ហាសេដ្ឋកិច្ច និងបញ្ហាអាស៊ានការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងទំនាក់ទំនងទ្វេភាគី" ។

រដ្ឋមន្ត្រីការបរទេសរូបនេះដែលបានមកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជាជាច្រើនលើកក្នុងនាមជាសមាជិកព្រឹទ្ធសភាអាមេរិកក្នុងទសវត្សរ៍ឆ្នាំ១៩៩០នោះ បានកត់សម្គាល់អំឡុងសុន្ទរកថា

តទៅទំព័រទី ៣០

តមកពីទំព័រទី ០១

## ទេព នីថា បានជាប់ជា អគ្គលេខា...

ដែលអព្យាក្រឹតពិតប្រាកដ។ ទេព និថា ជាប់ឈ្មោះតែងតាំងក្នុងគ.ជ.ប.ថ្មីនេះ បានឱ្យសញ្ញាថា គ.ជ.ប.អនាគត នឹងមានបញ្ហាថមថយទំនុកចិត្តទាំងស្រុងពីសំណាក់ម្ចាស់ឆ្នោតនៅកម្ពុជានឹងជាពិសេសពីសំណាក់អ្នកគាំទ្រគណបក្សសង្គ្រោះជាតិដែលបានបោះឆ្នោតឱ្យខ្លួនកាលពីឆ្នាំ២០១៣។ តើគួរឱ្យសាធារណជនយល់យ៉ាងណា?

មនុស្ស៩នាក់ជាអ្នកសម្រេចវាស្នាដំណែងអគ្គលេខាធិការគ.ជ.ប.ថ្មីមួយនេះ ដែលសមាសភាពមាន៤នាក់មកពីគណបក្សសង្គ្រោះជាតិដែលគេសង្ឃឹមថា"ប្រឆាំងនឹង ទេព នីថា" -៤នាក់ទៀតមកពីគណបក្សប្រជាជនដែលគេយល់ថា ច្បាស់ជាមានទំនោរ"ចង់បាន ទេព នីថា" -នៅសល់សមាជិកម្នាក់ទៀត ដែលគេសន្មតថាអព្យាក្រឹត្យមុខជានឹងចង់បានគ.ជ.ប.បរិសុទ្ធ ដូច្នេះត្រូវជម្រុះលម្អៀលអាក្រក់ឱ្យអស់ចេញ បើយ៉ាងនេះ ទេព នីថា នឹង "មិនជាប់ជាជម្រើស"របស់ម្នាក់នេះទេ... តែផ្ទុយទៅវិញ ទេព នីថា បានជាប់ឆ្នោត ដែលជាទី"គាប់ចិត្តរបស់គណបក្សប្រជាជនកម្ពុជា"ដដែល ។

ក្នុងរូបភាពនៃលទ្ធផលរបៀបនេះ គឺជាការទទួលខុសត្រូវរបស់សមាជិកអព្យាក្រឹតតែម្នាក់ឯង -ប៉ុន្តែប្រធានគ.ជ.ប. បានប្រកាសថា លទ្ធផលនៃការជ្រើសរើសនេះ គឺជា "កិច្ចព្រមព្រៀងគ្នារវាងអ្នកទាំង៩រូប" បានសេចក្តីថា សមាជិកគ.ជ.ប. ដែលអព្យាក្រឹតនោះ"មិននៅក្នុងការទទួលខុសត្រូវទៀតទេ" ដូច្នេះសួរថា "តើគេព្រមព្រៀងគ្នាលើអ្វីខ្លះ?" បានជាអាចប្តូរទស្សនៈនៃការបង្កើតអង្គភាពគ.ជ.ប.នេះ ពី"បរិសុទ្ធ"ទៅជា"ក្រខ្វក់" បាន? តើការព្រមព្រៀងនេះ មានន័យថា "ស៊ុំគ្រលុំ" ឬក៏"ចាញ់ប្រាជ្ញា"ហើយគណបក្សធំទាំង២ឯណោះទេ ដែលទទួលខុសត្រូវទៅវិញ។

**១-**គណបក្សប្រជាជនចង់បានការទ្រទ្រង់បន្តអំណាចនឹងការដឹកនាំនយោបាយសព្វថ្ងៃ ចម្រូងចម្រាស់ដោយមានបញ្ហាបូរណភាពដែលដីខ្មែរក្រោមវៀតណាម បញ្ហាបក្សពួកនិយម ពុករលួយ អយុត្តិធម៌... ដែលគ្មានលំនឹងឱ្យនៅគង់វង្ស ។

**២-**គណបក្សសង្គ្រោះជាតិចង់រំដោះប្រទេសចេញពីអំណាចសព្វថ្ងៃ ហើយកាន់អំណាចខ្លួនឯង តែកំពុងមានបញ្ហាគ្មានអំណាច"ការពារសមាជិកខ្លួនឯងមិនបាន-ប្រធានខ្មាតចេញទៅក្រៅចូលស្រុកមិនបាន-ចង់គាំទ្រសង្គមស៊ីវិល ឬសហជីពក៏ធ្វើមិនបាន-ចង់ត្រឡប់ទៅរកវប្បធម៌សន្ទនាជាមួយនឹងបក្សប្រជាជន ដូចកាលពីពាក់កណ្តាលឆ្នាំមុននោះវិញក៏ធ្វើមិនបាន-មើលឃើញប្រជាប្រិយភាពរបស់



ទេព នីថា

ខ្លួនចុះទៅៗ" ។

ទិសដៅនៃការដោះស្រាយចំណោង គឺទំនងជានឹងដើរទៅរក"បក្សសង្គ្រោះជាតិត្រូវធ្វើសម្បទានអ្វីថ្មីមួយទៀត"ដែល"សំខាន់" ដើម្បីសម្រួលសន្តិសុខនឹងសន្តិភាពក្នុងការរស់នៅក្នុងអំណាចរបស់ក្រុមខ្លួនបានខ្លះ ដោយសុខចិត្ត "លះបង់ឧត្តមគតិ"ថ្មីខ្លះទៀត ទៅឱ្យគណបក្សប្រជាជន។

ការជាប់ឆ្នោតរបស់ ទេព នីថា គឺជាសញ្ញានៃ"ផលចំណេញដ៏ធំ"របស់បក្សប្រជាជនទៅលើគណបក្សសង្គ្រោះជាតិនឹងអាចជាដំណើរទៅរកសន្លឹកឆ្នោតស្រដៀងគ្នានឹងការបោះឆ្នោតលើកមុនៗបាន... ប៉ុន្តែសមាជិកគ.ជ.ប.ខាងអ្នកឯករាជ្យនឹងខាងគណបក្សសង្គ្រោះជាតិបានធានាថា គ.ជ.ប. លើកនេះ នឹងគ្រប់គ្រងមិនដូចគ.ជ.ប.ពីលើកមុនទេ។

តើការធានានេះ នឹងមានប្រសិទ្ធិភាពលើលទ្ធផលនៃការបោះឆ្នោតលើកក្រោយបានដែរឬទេ? យើងចាំមើលស្នាដៃ"សន្យាថ្មីទៀត" តើវាខុសអ្វីពីលើកនេះ?






# វិធីងាយៗជួយឲ្យសម្រស់ក្មេងជាងវ័យ



មនុស្សគ្រប់រូបតែងតែមានការខ្វាយខ្វល់ និងមានអារម្មណ៏ថា មិនសប្បាយចិត្តនៅពេលមើលឃើញខ្លួនឯងមានស្នាមជ្រីវជ្រួញមិនស្រស់ថ្លា ។ ដូច្នេះអត្ថបទមួយនេះ នឹងបង្ហាញអ្នកអំពីវិធី ដើម្បីជួយធ្វើឱ្យសម្រស់របស់អ្នកក្មេងជាងវ័យ ។

-អ្នកគួរតែរកពេលនិយាយ ឬជជែកលេងជាមួយមិត្តភក្តិ ឬអ្នកជិតខាងរបស់អ្នកយ៉ាងហោចណាស់ឱ្យបាន១០នាទីក្នុងមួយថ្ងៃ ។

-សើចឱ្យបានញឹកញាប់ ព្រោះការសើចអាចជួយបន្ថែមបរិមាណអ័រម៉ូនដល់សាច់ថ្លាល់ដែលជាប្រយោជន៏ជួយផ្តល់ភាពរឹងមាំដល់រាងកាយ ។

-ឧស្សាហ៏សសេរ ឬកត់សំគាល់នូវទង្វើប្រចាំថ្ងៃរបស់ខ្លួន ។ អ្នកដែលឧស្សាហ៏សសេរ និងកត់សម្គាល់នូវអ្វីដែលខ្លួនឯងបានធ្វើ និងជួបប្រទះរាល់ថ្ងៃបានសេចក្តីថា អ្នកនោះបានបញ្ចេញ និងបន្ធូរបន្ថយនូវភាពតានតឹង និងភាពសោកសៅនៅលើទំព័រសៀវភៅអស់ទៅហើយ ។

-ការមើលទូរទស្សន៏នៅកន្លែងដេករបស់អ្នកជាឧបសគ្គមួយចំពោះការដេករបស់អ្នក ពីព្រោះការដាក់តាំងទទូរទស្សន៏ដោយមិនបានយកក្រណាត់ ឬអ្វីគ្របអាចធ្វើឱ្យរលកម៉ាញេទិច (ជាតិមេដែក) ពីទូរទស្សន៏មករំខានដល់ការដេក និងស្រូបយកកម្លាំងក្នុងរាងកាយរបស់លោកអ្នកបានទៀតផង ។





-ហាត់ធ្វើសមាធិយ៉ាងហោចណាស់ ឱ្យបាន៥នាទីក្នុងមួយថ្ងៃ ។ សមាធិជាកត្តាសំខាន់ក្នុងការប្រឆាំងនឹងអារម្មណ៏ពីខាងក្រៅមិនតែប៉ុណ្ណោះសមាធិអាចជួយសម្រួលដល់ដំណើរការ និងសង្វាក់បេះដូងបានល្អជាប្រក្រតី ។

-ឧស្សាហ៏យកសរសៃខ្សែតូចៗដុសខាត់ធ្មេញឱ្យបានរៀងរាល់ថ្ងៃ ដើម្បីកម្ចាត់អាហារដែលសេសសល់ពីការដុសនឹងច្រាស ព្រោះកម្ទេចអាហារទាំងនេះជាប្រភពនៃជំងឺរលាកអញ្ចាញធ្មេញ និងពុកធ្មេញ ហើយធ្វើឱ្យមាត់ មានក្លិនស្អុយទៀតផង ។

-លើកជើងមកដាក់ស្មើនឹងដើមទ្រូងរាល់ថ្ងៃមុនពេលចូលគេង ដើម្បីជួយសម្រួលដល់ប្រព័ន្ធឈាមរត់បានស្រួល និងស្មើល្អ ៕

តមកទំព័រទី ១៣ ពិធីផ្សេងៗក្នុងបុណ្យចូលឆ្នាំថ្មី....

ដូចជាទាខ្វៃប៉េកាំង និងក្រូចចិនបាយដំណើប និងអយស្ទ័រងៀត ។ វាជាពិធីសម្បូរជនជាតិវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនដើម្បីជួបជុំគ្រួសារ និងបរិភោគអាហារជាមួយពួកគេ ។

**●ថ្ងៃទីមួយ**

ថ្ងៃទីមួយនឹងចាប់ផ្តើមនៅពាក់កណ្តាលថ្ងៃប្រជាជនស្វាគមន៏ព្រះឋានសួគ៌ និងធរណី ។ នៅថ្ងៃនោះជាពិសេសក្នុងចំណោមប្រជាជនអ្នកកាន់សាសនាព្រះពុទ្ធត្រូវហូបអាហារបួស ពីព្រោះពួកគេជឿថា នឹងបង្កើនអាយុរបស់ពួកគេ ។ ប្រជាជនមិននាំគ្នាចម្អិននោះទេនៅថ្ងៃនេះ ដើម្បីចៀសពីទុក្ខទោសណាមួយដែលអាចបង្កឡើងដោយសារកាំបិត និងវត្ថុមុតៗដទៃទៀត ។ ពួកគេភាគច្រើនទៅលេង និងសួរសុខទុក្ខចាស់ទុំរបស់ក្រុមគ្រួសារពួកគេ ព្រមទាំងគោរពចាស់ទុំទាំងនោះ ។ ពួកគេឱ្យអាន់ប៉ាវគ្នាទៅវិញទៅមក ហើយក្នុងអាន់ប៉ាវនោះមានប្រាក់ ហើយបន្ទាប់មកពួកគេសប្បាយរីករាយជាមួយគ្នាដោយការដុតផាវ និងកាំជ្រួច ។

**●ថ្ងៃទីពីរ**

ប្រជាជនធ្វើការបន់ស្រន់ទៅបុព្វការីជនរបស់ពួកគេ និងព្រះនានាដើម្បីសុំឱ្យមានសំណាងល្អ និងភាពរុងរឿងនៅឆ្នាំថ្មី ។ ស្ត្រីទើបរៀបការហើយនឹងទៅលេងផ្ទះរបស់ខ្លួននៅថ្ងៃទីពីរនេះ ដែលត្រូវបានគេចាត់ទុកថា ជាថ្ងៃខួបកំណើតរបស់សត្វឆ្កែទាំងអស់ ដូច្នេះប្រជាជនធ្វើល្អចំពោះសត្វឆ្កែ ហើយដាក់ចំណីឱ្យវា ។

**●ថ្ងៃទីបី និងថ្ងៃទី៤**

ថ្ងៃទាំងពីរនេះត្រូវបានចាត់ទុកថាជាថ្ងៃកូនប្រសាប្រុសគោរពឪពុកម្តាយក្មេករបស់ពួកគេ ។ ប្រជាជនមួយចំនួនក៏ចាត់ទុកថ្ងៃនេះថា ជាថ្ងៃសមស្របដើម្បីទៅលេងផ្ទះជូនតាផងដែរ ។ ពួកគេជឿថា ការទៅលេងផ្ទះកំណើតមិនគួរទៅលេងនោះទេ នៅថ្ងៃទាំងពីរនេះ ពីព្រោះថាអាចនឹងកើតមានរឿងជម្លោះឈ្លោះប្រកែកគ្នា ហើយនៅថ្ងៃនេះពួកគេជឿថា ប្រជាជននឹងទៅលេងផ្ទះអ្នកជាទីស្រឡាញ់របស់ពួកគេដែលទទួលមរណកាលក្នុងអំឡុងបីឆ្នាំមុន ។

**●ថ្ងៃទីប្រាំ**

ថ្ងៃនេះ ត្រូវបានគេហៅថា ពូវូ ជាថ្ងៃដែលប្រជាជននាំគ្នាស្វាគមន៏ "ព្រះទ្រព្យសម្បត្តិ" ដែលស្ថិតនៅក្នុងផ្ទះរបស់ពួកគេ ។ ថ្ងៃនេះត្រូវបានគេចាត់ទុកថា ជាថ្ងៃខួបកំណើតរបស់ "ព្រះទ្រព្យសម្បត្តិ" ។ ប្រជាជនមិនទៅលេងផ្ទះអ្នកដទៃនោះទេ ពីព្រោះពួកគេជឿថា នឹងនាំមកនូវសំណាងអាក្រក់ ។ ប្រជាជនតែងតែងតែបើកអាជីវកម្មរបស់ពួកគេឡើងវិញនៅថ្ងៃនេះដើម្បីនាំមកនូវសំណាងល្អដល់អាជីវកម្មរបស់ពួកគេ ។ ថ្ងៃនេះក៏នឹងមានការបាញ់កាំជ្រួចផងដែរ ដើម្បីស្វាគមន៏ព្រះទ្រព្យសម្បត្តិ ។

**●ថ្ងៃទីប្រាំមួយ**

ថ្ងៃនេះជាថ្ងៃត្រូវទៅលេងអ្នកជាទីស្រឡាញ់សាច់ញាតិ និងមិត្តភ័ក្តិជាជាងសមាជិកគ្រួសារជិតដិត ។ ប្រជាជនបន់ស្រន់ទៅព្រះដើម្បីសុំសំណាងល្អ និងសេចក្តីសុខនៅថ្ងៃនេះ ។

**●ថ្ងៃទីប្រាំពីរ**

នៅថ្ងៃនេះប្រជាជនប្រារព្ធពិធីខួបកំណើតនៃមនុស្សជាតិ ។ ពួកគេគិតថា ខ្លួនមានអាយុមួយឆ្នាំចាស់ឡើងទៀតហើយនៅថ្ងៃនេះ ។ ពួកគេទទួលទានគុយទាវដើម្បីបង្កើនអាយុយឺនយូរ និងត្រីដើម្បីទទួលបានភាពជោគជ័យ ។ វាជាថ្ងៃរបស់កសិករដើម្បីតាំងបង្ហាញអំពីផលដំណាំរបស់ពួកគេដោយធ្វើភេសជ្ជៈចំនួនប្រាំពីរមុខចេញពីបន្លែចំនួន៧មុខ ។

**●ថ្ងៃទីប្រាំបី**

ថ្ងៃនេះគឺជាថ្ងៃហូបអាហារពេលល្ងាចជួបជុំគ្រួសារដើម្បីប្រារព្ធពិធីមួយថ្ងៃមុនថ្ងៃខួបកំណើតរបស់រាជាធិរាជ Jade មែផរៀវហើយចាប់ពីថ្ងៃទីប្រាំបីនេះតទៅប្រជាជននាំគ្នាចាប់ផ្តើមត្រឡប់ចូលធ្វើការងារវិញ ។

**●ថ្ងៃទីប្រាំបួន និងថ្ងៃទី១០**

ថ្ងៃនេះគឺជាខួបកំណើតអ្នកគ្រប់គ្រងឋានសួគ៌រាជាធិរាជ Jade Emperor និងជាពេលដើម្បីអញ្ជើញមិត្តភ័ក្តិ ឬសាច់ញាតិមកទទួលទានអាហារពេលល្ងាចជុំគ្នា ។

**●ថ្ងៃទីដប់មួយ និងទីដប់ពីរ**

ពួកគេបន្តហូបអាហារពេលល្ងាចទៀត ។

**●ថ្ងៃទីដប់បី**

ថ្ងៃនេះគឺជាថ្ងៃដែលប្រជាជនទទួលទានតែអាហារបួសដើម្បីសម្អាតប្រព័ន្ធក្នុងខ្លួនរបស់ពួកគេដោយសារតែការហូបអាហារច្រើនពេកក្នុងអំឡុងពីរសប្តាហ៏មុន ។ ថ្ងៃនេះគឺជាថ្ងៃមួយដែលត្រូវឧទ្ទិសទៅព្រះ Guan Yu ដែលជាព្រះសង្គ្រាម ។ ពាណិជ្ជករបន់ស្រន់ទៅព្រះនេះដើម្បីឈ្នះនូវរាល់ការលំបាកនានានៅក្នុងវិថីអាជីវកម្មរបស់ពួកគេ ។

**●ថ្ងៃទីដប់បួន :**

ថ្ងៃនេះគឺជាថ្ងៃរៀបចំចង្កៀងគោមដែលនឹងត្រូវប្រារព្ធនៅថ្ងៃបន្ទាប់ ។

**●ថ្ងៃទីដប់ប្រាំ :**

នៅថ្ងៃនេះប្រជាជននាំគ្នាដុតទាន និងដើរលេងតាមផ្លូវដើម្បីនាំមកនូវសំណាងល្អ ។ ពួកគេនាំគ្នាហូបនំចាំងនៅថ្ងៃនេះ ។ ថ្ងៃនេះគឺជាថ្ងៃបញ្ចប់ពិធីបុណ្យចូលឆ្នាំចិន ៕



# ថែរក្សាស្បែកដោយពោត

ពោតក៏មានសារធាតុជំនួយដល់ស្បែកដែលអាចយកមកប្រើក្នុងការថែរក្សាស្បែករបស់អ្នកបានជាច្រើនដូចជា៖

**+រូបមន្តឡេបន្ថយស្នាមអុជខ្មៅ**

ចំពោះអ្នកដែលមានបញ្ហាស្នាមអុជខ្មៅ កែមិនបាត់ សូមណែនាំតិចនិកថែរក្សាស្បែកឱ្យស្អាតដោយមានសមាសធាតុផ្សំពីធម្មជាតិសុទ្ធសាធដោយយកគ្រាប់ពោតមួយពែងរួមជាមួយទឹកឆ្អិន១.៣ពែងមកកិនឱ្យម៉ដ្ឋច្រោះយកតែជាតិទឹកយកមកលាយជាមួយនឹងក្រូចឆ្មារ២ស្លាបព្រាកាហ្វេ និងទឹកឃ្មុំ២ស្លាបព្រាកូរឱ្យចូលគ្នា បន្ទាប់មកយកមកលាបលើផ្ទៃមុខទុកចោលប្រមាណ២០នាទី សឹមលាបម្តងទៀតឱ្យសព្វលើផ្ទៃមុខទុក១៥នាទីទៀត សឹមលាងជម្រះដោយទឹកត្រជាក់ជាការស្រេច ។ ធ្វើបែបនេះជាប្រចាំ និងជួយឱ្យបញ្ហាស្នាមអុជខ្មៅ ឬស្នាមអាចម៍រុយនៅលើមុខបានជាមិនខាន ។

**+រូបមន្តក្រែមធ្វើឱ្យមុខស និងបន្តឹងស្បែកមុខ**

ចំពោះអ្នកដែលពុំមានបញ្ហាមុនច្រើនពេកទេ តែចង់ឱ្យមុខស និងចង់បង្រួមរន្ធរោម សូមណែនាំឱ្យកិនគ្រាប់ពោត១ពែងជាមួយនឹងទឹកឆ្អិន២ស្លាបព្រាបាយកិនរហូតឃើញល្បាយជាសាច់ក្រែម រួចដាក់ទឹក៣ស្លាបព្រាកាហ្វេស៊ុតសមួយគ្រាប់កិនចូលគ្នាក្លាយទៅជាសាច់មួយ ។ យកក្រែមនេះមកលាបលើផ្ទៃមុខប្រើចុងម្រាមលាបស្រាលៗ និងអង្អែលទៅមកផ្តោតលើបរិមាណថ្ងាសច្រមុះ និងចង្កាប្រមាណ១០នាទីលើស្បែកមុខរួចលាងជម្រះនឹងទឹកក្តៅជាការស្រេច ៕

## តមកទំព័រទី ២៧ លោក ចន ឃើរី សង្កត់ធ្ងន់លើបញ្ហា...

នាពេលរសៀលរបស់លោកថា ប្រទេសកម្ពុជា មានការអភិវឌ្ឍឆាប់រហ័សចាប់តាំងពីលោកមកកាន់ទីនេះកាលពីលើកមុន និងបំណងប្រាថ្នា របស់សហរដ្ឋអាមេរិកដើម្បីពង្រឹងទំនាក់ទំនងសេដ្ឋកិច្ច ។

លោកបានថ្លែងថា "ការរីកចម្រើនដែលអ្នកបានធ្វើនៅក្នុងប្រទេសកម្ពុជាគួរឱ្យកត់សម្គាល់បំផុត ។ នៅពេលខ្ញុំមកទីនេះដំបូងទីក្រុងមានប្រជាជនតែ៣៥០.០០០នាក់ប៉ុណ្ណោះ ហើយសេដ្ឋកិច្ចដុនដាបមែនទែន ហើយឥឡូវនេះទីក្រុងមានប្រជាជនដល់ទៅ២.២លាននាក់ ដោយមានមន្ទីរពេទ្យទំនើបៗអគារខ្ពស់ៗមានថាមពល និងមានភ្ញៀវទេសចរដ៏ច្រើន។ លោក ចន ឃើរី បានលើកឡើងថា វាពិត "ជាគួរឱ្យកត់សម្គាល់បំផុត" ដែលអាមេរិកនៅតែជាទីផ្សារនាំចេញដ៏សំខាន់របស់ប្រទេសកម្ពុជា" ។

លោកបានថ្លែងថា "ហើយយើងនឹងបន្តរិះរកមធ្យោបាយដើម្បីបង្កើនពាណិជ្ជកម្ម និងទំនាក់ទំនងវិនិយោគរួមទាំងការជួយដោះស្រាយអំពើពុករលួយ និងការស្វែងរកមធ្យោបាយ ដើម្បីពង្រឹងស្ថាប័នច្បាប់នៅក្នុងប្រទេសកម្ពុជាជាដើម។ មិនដូចលោកស្រី ហ៊ីឡារី គ្លីនតុន អតីតរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកដែលបានធ្វើការពិភាក្សាជាសាធារណៈជាមួយនិស្សិតរាប់រយនាក់ អំឡុងដំណើរទស្សនកិច្ចរបស់លោកស្រីមកកាន់ប្រទេសកម្ពុជាកាលពីឆ្នាំ២០១០ លោក ចន ឃើរី មិនមានពេលឱ្យមានការចោទសួរជាសាធារណៈណាមួយទេ ហើយជំនួបរបស់លោក គឺជាជំនួបបិទទ្វារមិនឱ្យអ្នកសារព័ត៌មានចូល។

លោក ហោ ណាំហុង រដ្ឋមន្ត្រីការបរទេសក៏បានលើកឡើងអំពីសារៈសំខាន់នៃកិច្ចសហ-ប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងរដ្ឋអ៊ីស្លាមនៅក្នុងសុន្ទរកថាបន្ទាប់ពីជំនួបរបស់លោកជាមួយលោក ចន ឃើរី ផងដែរ។

លោកបានថ្លែងថា "ខ្ញុំមិនជឿថា ការបោសសម្អាតក្រុម I.S អាចធ្វើបានដោយប្រទេសមួយ ឬយោធារបស់ប្រទេសមួយនោះទេ។ ពីព្រោះទង្វើឃោរឃៅរបស់រដ្ឋអ៊ិស្លាម វាមិនមែនជាការគំរាមកំហែងសម្រាប់ប្រទេស អ៊ីរ៉ាក់ និងប្រទេសស៊ីរីប៉ុណ្ណោះទេ វាគំរាមកំហែងដល់តំបន់អាហ្វ្រិក និងអាស៊ីផងដែរ"។

បើទោះជាមានភាពតានតឹងរវាងអាមេរិក និងចិនជុំវិញការអះអាងការកាន់កាប់សមុទ្រចិនខាងត្បូង និងការប្រកួតប្រជែងកាន់តែខ្លាំងឡើងរវាងប្រទេសមហាអំណាចចំពោះឥទ្ធិពលនៅក្នុងតំបន់ក៏ដោយ ក៏លោក ហោ ណាំហុង បានថ្លែងថា លោក ចន ឃើរី មិនបានជំរុញប្រទេសកម្ពុជាស្តីពីបញ្ហានេះពាក់ព័ន្ធប្រទេសចិនឡើយ។

លោកបានថ្លែងថា "ឯកឧត្តម ចន ឃើរី ក៏បានលើកឡើងផងដែរថា លោកមិនបានស្នើឱ្យប្រទេសកម្ពុជាគាំទ្រអាមេរិក ឬគាំទ្រចិនឡើយ។ ខ្ញុំបានពន្យល់ប្រាប់លោកថា ការពិតកម្ពុជា ជាប្រទេសតូចមួយ និងជាប្រទេសក្រីក្រ ប៉ុន្តែយើងឯករាជ្យ"។



ប្រទេសកម្ពុជាបានរងការរិះគន់យ៉ាងខ្លាំងថាបានគាំទ្រប្រទេសចិននៅក្នុងជម្លោះអធិបតេយ្យរបស់ខ្លួនជាមួយប្រទេសអាស៊ានមួយចំនួនទាក់ទិនសមុទ្រចិនខាងត្បូង។

អំឡុងការពិភាក្សារបស់លោក ចន ឃើរី ជាមួយលោក ហ៊ុន សែន លោកនាយករដ្ឋមន្ត្រីក៏បានស្នើឱ្យអាមេរិកបន្តគាំទ្រក្នុង "វិស័យសុខាភិបាល អប់រំ និងការបោសសម្អាត មីន" នេះបើយោងតាមលោក អៀង សុផាល្លែត ជំនួយការផ្ទាល់របស់លោកដែលបាននិយាយទៅកាន់អ្នកយកព័ត៌មានបន្ទាប់ពីជំនួប។

លោក អៀង សុផាល្លែត បានថ្លែងថា លោក ហ៊ុន សែន ក៏បានសម្តែងពីបំណងប្រាថ្នារបស់លោកសុំឱ្យសហរដ្ឋអាមេរិកពិចារណា "អនុញ្ញាតឱ្យប្រទេសកម្ពុជានាំចេញទំនិញទៅកាន់សហរដ្ឋអាមេរិកដោយគ្មានកូតា ឬការលើកលែងពន្ធជាកត្តាដែលនឹងជួយជំរុញឱ្យមានការអភិវឌ្ឍរបស់ប្រទេសកម្ពុជា" ៕ **សារុន**

# 2016 Print Schedules and Ad Rates

KhmerPost USA is the only Cambodian newspaper that has the highest circulation and is most read in the Cambodian communities in the Greater Merrimack Valley, Boston and beyond. It provides important news and information to a market that is often isolated from the larger community due to a language barrier. This includes the national and international news, and the practical local information concerning health, education, politics, businesses and community involvement.

## Publication Frequency

24 times a year. Prints on every other Friday

## General Information

Circulations: 12,000 free copies per month.

Distributions:

- 70+ locations in Lowell, MA (5,000 copies per issue)
- 25 locations in Lynn and Revere, MA (500 copies per issue)
- 25 locations in Cranston and Providence, RI (1,000 copies per issue)

## 2016 Publication Dates

- January 8th & 22nd, 2016
- February 5th & 19th, 2016
- March 4th & 18th, 2016
- April 8th & 22nd, 2016
- May 6th & 20th, 2016
- June 3rd & 17th, 2016
- July 8th & 22nd, 2016
- August 5th & 19th, 2016
- September 9th & 23rd, 2016
- October 7th & 21st, 2016
- November 4th & 18th, 2016
- December 2nd & 16th, 2016

* all ad materials are due one due one week prior to the publishing date.


KHMERPOST USA
Issue 189 Nov.28th. to Dec.07th. 2015
Page.1
Free
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641
Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852
Miss Massachusetts USA & Miss Massachusetts Teen USA

## Advertising Rates

| Ad Size | 1 issue | 3 month<br>5% off | 6 month<br>7,5% off | 12 month<br>10% off |
|---|---|---|---|---|
| full | 460.00 | 874.00 | 851.00 | 828.00 |
| 1/2 | 310.00 | 589.00 | 573.50 | 558.00 |
| 1/4 | 165.00 | 313.50 | 305.25 | 297.00 |
| 1/8 | 90.00 | 171.00 | 166.50 | 162.00 |

## Ads Sizes & Dimensions

| | |
|---|---|
| 1 Full page inside | (13"x10") |
| 1/2 page color | (6.5"x10") |
| 1/4 page color | (6.5"x5") |
| 1/8 page color | (3.25"x5") |

**Office:** 45 Merrimack Street. Suite 218A. Lowell, MA 01852
**Tel:** 978.677.7163. **Cell:** 978. 656.8141. Fax: 978.677.7092
Email: sobenpin@khmerpost.us | www.khmerpost.us




វាជាពេលបើកឲ្យចុះឈ្មោះនៅ Massachusetts Health Connector ជាទីដែលអ្នកអាចស្វែងរកគម្រោងថែទាំមាត់ធ្មេញនិងសុខភាព ដែលមានគុណភាពខ្ពស់ពីបណ្ដាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេ។ មនុស្សម្នាភាគច្រើនដែលចុះឈ្មោះ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលជំនួយបង់ថ្លៃធានារ៉ាប់រងរបស់ពួកគេរាល់ខែ។

**ចុះឈ្មោះសម្រាប់គម្រោងណាមួយតាមអ៊ិនធើណេតនៅ MAhealthconnector.org ឬទទួលការជួយចុះឈ្មោះដោយផ្ទាល់ឥតគិតថ្លៃពីអ្នកជំនាញណាម្នាក់របស់ពួកយើង។**

ដើម្បីស្វែងរកជំនួយក្នុងសង្កាត់របស់អ្នក សូមទៅកាន់ **MAhealthconnector.org** ហើយចុចលើ **"Help Center"** (មជ្ឈមណ្ឌលជំនួយ) នៅខាងលើបំផុតនៃគេហទំព័រ។

កន្លែងដើម្បីទទួលជំនួយ៖

**Lowell**

**Lowell Community Health Center**
161 Jackson Street
978-937-9700

**Cambodian Mutual Assistance Association**
120 Cross Street
978-454-6200

**Lowell General Hospital**
295 Varnum Avenue
978-937-6000

**Lawrence Cavanaugh, Independent Broker**
978 Boylston Street
978-332-6904

**Chibueze Chikere, Independent Broker**
29 Manchester Street
617-922-6499

**Lynn**

**Lynn Community Health Center**
269 Union Street
781-581-3900

MASSACHUSETTS HEALTH CONNECTOR
*the right place for the right plan*